ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កម្រង
# ឯកសារគតិយុត្តសម្រាប់ការគ្រប់គ្រងរមណីយដ្ឋាន
# ប្រាសាទកោះកេរ និងប្រាសាទព្រះវិហារ
# របស់អាជ្ញាធរជាតិព្រះវិហារ



អាជ្ញាធរជាតិព្រះវិហារ
២០២៣

គាំទ្រដោយ ៖

United Nations
Educational, Scientific and
Cultural Organization

គណៈកម្មការជាតិយូណេស្កូកម្ពុជា
Cambodian National Commission
for UNESCO
Commission Nationale Du Cambodge
pour l'UNESCO

កម្មវិធីចូលរួមរបស់អង្គការយូណេស្កូ លេខ ២២៤០១១៤០៦៦
ឆ្នាំ២០២២-២០២៣

រៀបចំដោយនាយកដ្ឋានគ្រប់គ្រងដីធ្លី នគរូបនីយកម្ម និងអភិវឌ្ឍន៍សហគមន៍
អាជ្ញាធរជាតិព្រះវិហារ

# កម្រង
# ឯកសារគតិយុត្តសម្រាប់ការគ្រប់គ្រងរមណីយដ្ឋាន
# ប្រាសាទកោះកេរ និងប្រាសាទព្រះវិហារ
# របស់អាជ្ញាធរជាតិព្រះវិហារ

គាំទ្រដោយ ៖

UNESCO
United Nations
Educational, Scientific and
Cultural Organization

គណៈកម្មការជាតិយូណេស្កូកម្ពុជា
Cambodian National Commission
for UNESCO
Commission Nationale Du Cambodge
pour l'UNESCO

កម្មវិធីចូលរួមរបស់អង្គការយូណេស្កូ លេខ ២២៤០១១៤០៦៦ ឆ្នាំ២០២២-២០២៣

ប្រាសាទកោះកេរ, ខេត្តព្រះវិហារ
២០២៣

# បុព្វបទ

អាជ្ញាធរជាតិព្រះវិហារត្រូវបានបង្កើតឡើងកាលពីថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៦ ហើយក្រោយមកត្រូវបានប្រែក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាធរជាតិព្រះវិហារ មានបេសកកម្មគ្រប់គ្រង ថែរក្សា អភិរក្ស និងអភិវឌ្ឍតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារនិងរមណីយដ្ឋានប្រាសាទកោះកេរ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូ កាលពីថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៨ និងថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២៣ បន្តបន្ទាប់គ្នា។

ជាមួយនឹងការរៀបចំស្ថាប័នអាជ្ញាធរជាតិព្រះវិហារនេះឡើង រាជរដ្ឋាភិបាលក៏បានអនុម័តនូវឯកសារសំខាន់ៗមួយចំនួនដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍន៍ដោយចីរភាពនៃរមណីយដ្ឋានទាំងពីរ។ ជាមួយបទដ្ឋានគតិយុត្តនេះ អាជ្ញាធរជាតិព្រះវិហារ ក៏បានសហការជាមួយអាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន និងមន្ទីរជំនាញពាក់ព័ន្ធ ចុះស្រង់យកព័ត៌មានសំខាន់ៗមួយចំនួនទៀតដូចជា សម្រង់ការប្រើប្រាស់ដីធ្លី សម្រង់ដីលំនៅដ្ឋាន សម្រង់ស្ថិតិគ្រួសារ និងចំនួនប្រជាជននៅក្នុងតំបន់ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងការធ្វើផែនការស្របតាមបេសកកម្មដែលរាជរដ្ឋាភិបាលប្រគល់ជូន។

អាជ្ញាធរជាតិព្រះវិហារ រៀបចំចងក្រងឯកសារនេះឡើងដើម្បីប្រមូលផ្តុំនូវលិខិតបទដ្ឋានគតិយុត្តនានាដែលរាជរដ្ឋាភិបាលបានអនុម័ត រួមជាមួយឯកសារសម្រង់ទិន្នន័យផ្សេងទៀតដើម្បីផ្សព្វផ្សាយជូនដល់អង្គភាពពាក់ព័ន្ធនានា និងសាធារណៈជនសម្រាប់ការចូលរួមគ្នាការពារ អភិរក្ស បេតិកភណ្ឌពិភពលោកទាំងពីរនៅក្នុងទឹកដីខេត្តព្រះវិហារនេះសម្រាប់ជាកេរមរតកកូនចៅជំនាន់ក្រោយៗទៀត។

ជាមួយគ្នានេះ អាជ្ញាធរជាតិព្រះវិហារ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការជាតិយូណេស្កូកម្ពុជា ដែលបានគាំទ្រតាមរយៈកម្មវិធីរបស់អង្គការយូណេស្កូ លេខ ២២៤០១១៤០៦៦ (២០២២-២០២៣) លើគម្រោងចងក្រង និងផ្សព្វផ្សាយឯកសារគតិយុត្តនេះ។

ប្រាសាទព្រះវិហារ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**អគ្គនាយក**

**គង់ ពុទ្ធិការ**

# មាតិកា


បុព្វបទ ........................................................................................................i

ព្រះរាជក្រឹត្យស្ដីពី ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍ
រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ...................................................... 1

ព្រះរាជក្រឹត្យស្ដីពីការបង្កើតអាជ្ញាធរជាតិព្រះវិហារជាគ្រឹះស្ថានសាធារណៈរដ្ឋបាល.......... 9

អនុក្រឹត្យស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរជាតិព្រះវិហារ ................................ 33

ព្រះរាជក្រឹត្យស្ដីពីការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរឲ្យស្ថិតនៅក្រោម
ការគ្រប់គ្រងរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌
ធម្មជាតិនៃប្រាសាទព្រះវិហារ ............................................................................ 53

ព្រះរាជក្រឹត្យស្ដីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ................................ 57

ព្រះរាជក្រឹត្យស្ដីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ...................................... 67

ព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់ច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ................. 77

អនុក្រឹត្យស្ដីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌............................................. 99

ព្រះរាជក្រមប្រកាសឲ្យប្រើប្រាស់ច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ .............................. 125

# ព្រះរាជក្រឹត្យស្តីពី
# ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និង
# អភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ
# នៃប្រាសាទព្រះវិហារ

នស/រកត/០៦០៦/២៤៨

# ព្រះរាជក្រឹត្យ
## ស្តីពី
## ការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋារាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ត្រូវបានបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ហៅកាត់ "អ.ជ.ព.វ" ដែលជាគ្រឹះស្ថានសាធារណៈមួយប្រកបដោយបុគ្គលភាពគតិយុត្ត មានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ ។

គ្រឹះស្ថានសាធារណៈនេះ ស្ថិតនៅក្រោមអាណាព្យាបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២.-

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារមានបេសកកម្មគិតគូរ ដឹកនាំ ការងាររៀបចំ និងអភិវឌ្ឍទេសចរណ៍ នៃតំបន់ចំនួន៤ (បួន)ដែលកំណត់នៅក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/ ១៨៣ ចុះថ្ងៃ ទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ។

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារព្រមជាមួយក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវធ្វើជាអាណាព្យាបាលរួមលើគ្រឹះស្ថាន និងទាយកដ្ឋានទាំងឡាយ ដែលមានភារកិច្ចទទួលខុសត្រូវជាក់ស្តែង ក្នុងការគ្រប់គ្រងរមណីយដ្ឋានប្រាសាទព្រះវិហារ ។

មាត្រា ៣.-

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ឱ្យមាន សៀវភៅបន្ទុកសម្រាប់អង្គការនានា ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងរមណីយដ្ឋាន និងការរៀបចំតំបន់ប្រាសាទព្រះវិហារ ។ ក្នុងន័យនេះ អាជ្ញាធរជាតិអាច :

- ចុះកិច្ចសន្យា អំពីកម្មវិធីប្រចាំឆ្នាំជាមួយអង្គការជាតិ និងអន្តរជាតិនានា
- ចុះកិច្ចសន្យា ជាមួយអាជ្ញាធរខេត្តដែលមានបំណងធ្វើការរៀបចំនគរូបនីយកម្ម ការអភិវឌ្ឍជនបទ និង ការផ្តល់សេវាផ្សេងៗជាយថាហេតុ
- សហការជាមួយគ្រប់វិទ្យាស្ថាន គ្រប់អង្គការផ្សេងៗ គ្រប់មូលនិធិ និងសហគមន៍ជាតិ និងអន្តរជាតិ ដែលដើរ តាមទិសដៅ ឆ្លើយតបនឹងសមត្ថកិច្ចអាជ្ញាធរជាតិ ។

មាត្រា ៤.-

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវធ្វើរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំ អំពីសកម្មភាពការងារ ការវិនិយោគ និងសេចក្តីអនុញ្ញាតផ្សេងៗ ដែលត្រូវបាន សម្រេចហើយ ជូនប្រមុខរាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ក្រុមប្រឹក្សាភិបាល

មាត្រា ៥.-

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវបានដឹកនាំដោយ ក្រុមប្រឹក្សាភិបាលមួយ ដែលមានសមាសភាពដូចតទៅ :

- ឥស្សរជនមួយរូប ប្រធាន
- អភិបាលខេត្តព្រះវិហារ សមាជិក
- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក

- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ សមាជិក និងលេខាធិការ។

សមាសភាពក្រុមប្រឹក្សាភិបាល ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៦.-**

ក្រុមប្រឹក្សាភិបាល មានភារកិច្ចដឹកនាំអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងមានសិទ្ធិអនុម័ត :

- ការតម្រង់ទិសរាល់សកម្មភាពរបស់អាជ្ញាធរជាតិ
- ការអនុញ្ញាតឱ្យប្រធានអាជ្ញាធរជាតិ ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាអន្តរជាតិទាំងឡាយ ស្របតាមនីតិវិធីជាធរមាន
- បទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរជាតិ
- របាយការណ៍ប្រចាំឆ្នាំ ដែលប្រធានអាជ្ញាធរជាតិបានដាក់ជូន
- ចំនួនទឹកប្រាក់ ថ្លៃឈ្នួលផ្សេងៗ និងចំណូលគ្រប់បែបយ៉ាងដែលអាជ្ញាធរប្រមូលបាន
- ចំនួនទឹកប្រាក់ និងលក្ខខណ្ឌនៃការខ្ចីបុល
- រាល់វិធានការ ដំណោះស្រាយបញ្ហាដែលប្រធានអាជ្ញាធរជាតិ ដាក់ជូនពិនិត្យ ។

**មាត្រា ៧.-**

ក្រុមប្រឹក្សាភិបាល ត្រូវប្រជុំសាមញ្ញយ៉ាងតិច ២ (ពីរ) ដង ក្នុងមួយឆ្នាំ តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល និងអាចប្រជុំវិសាមញ្ញតាមការចាំបាច់ ក្នុងករណីមានការស្នើសុំពីប្រធាន ឬសមាជិកចំនួន ១/៤ ។

ប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជន ឬអ្នកជំនាញ និងតំណាងក្រសួង ស្ថាប័ន ជាលក្ខណៈពិគ្រោះយោបល់មកចូលរួមបានក្នុងអង្គប្រជុំ បានតាមការចាំបាច់ដើម្បីផលប្រយោជន៍សម្រាប់អាជ្ញាធរជាតិនេះ ។

**មាត្រា ៨.-**

អាណត្តិសមាជិកក្រុមប្រឹក្សាភិបាល មានរយៈពេល ៣ (បី) ឆ្នាំ ហើយអាចបន្តសាជាថ្មីបាន។ ការបញ្ចប់អាណត្តិសមាជិកណាម្នាក់ ត្រូវធ្វើឡើងតាមសំណើរបស់ក្រសួងសាមី ។

**មាត្រា ៩.-**

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីអាណាព្យាបាល តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

## ជំពូកទី ៣
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ១០.-**

ប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ គឺជាប្រធានអាជ្ញាធរជាតិនេះ ដែលមានសិទ្ធិអំណាចដូចមានចែងនៅក្នុងមាត្រា១២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងមានតួនាទី និងភារកិច្ចបន្ថែម ដូចតទៅ ៖

- ជាតំណាងឱ្យរាជរដ្ឋាភិបាលក្នុងគ្រប់កិច្ចប្រជុំ ពិធី និងការចរចាដែលពាក់ព័ន្ធនឹងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ចុះហត្ថលេខាលើកិច្ចព្រមព្រៀង ពិធីសារ និងកិច្ចសន្យាទាំងឡាយដែលទាក់ទងនឹងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- ទទួលរ៉ាប់រងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងចាត់វិធានការគ្រប់គ្រងក្នុងដំណើរការរបស់អាជ្ញាធរជាតិ
- ជាអាណាប័កដើមខ្សែនៃអាជ្ញាធរជាតិ ដែលមានតួនាទីត្រួតពិនិត្យចំណូល និងបញ្ជាចំណាយផ្សេងៗ
- តែងតាំង និងដំឡើងឋានន្តរស័ក្តិភ្នាក់ងារ និងបុគ្គលិក បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល
- ដឹកនាំ គ្រប់គ្រងជាប្រចាំលើសកម្មភាពការងាររបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ ។

**មាត្រា ១១.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានអគ្គនាយកដ្ឋានមួយជាសេនាធិការ ដែលត្រូវបានដឹកនាំ គ្រប់គ្រង ដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងមួយចំនួនតាមការចាំបាច់។ អគ្គនាយក និងអគ្គនាយករងនៃអគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិនេះ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១២.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ទទួលបន្ទុកការពារ អភិរក្ស និងគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវធ្វើសកម្មភាពឱ្យស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា៥ នៃព្រះរាជក្រមលេខ នស/រកម/ ០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ និងព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ ព្រមទាំងកាតព្វកិច្ចអន្តរជាតិ ។

អាជ្ញាធរជាតិនេះ មានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់ សម្រាប់ការស្ថាបនាទាំងឡាយក្នុងរង្វង់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ។ ការអនុញ្ញាតសាងសង់ដែលចេញដោយអាជ្ញាធរផ្សេងក្រៅពីអាជ្ញាធរជាតិនេះ ទាក់ទងទៅនឹងសំណង់នៅក្នុងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារត្រូវចាត់ទុកជាមោឃៈ ។ សំណង់កសាងរួចហើយក្នុងតំបន់ការពារដែលគ្មានច្បាប់អនុញ្ញាត ត្រូវរុះរើចេញដោយម្ចាស់សំណង់ដោយគ្មានលក្ខខណ្ឌ ក្នុងរយៈពេល ៤៥ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃជូនដំណឹង ។

អាជ្ញាធរជាតិនេះត្រូវទទួលភារកិច្ចផ្តាច់មុខ ជាអ្នកចាត់ចែងគ្រប់ការងារទាំងអស់ក្នុងបរិវេណរមណីយដ្ឋាននេះ លើកលែងតែកិច្ចការណាដែលទាក់ទងនឹងបញ្ហាព្រំដែន ។

## ជំពូកទី ៤
## វិសមិតភាព

**មាត្រា ១៣.-**

ប្រធាន សមាជិកទាំងអស់ និងនាយកហិរញ្ញកិច្ច និងគណនេយ្យ នៃក្រុមប្រឹក្សាភិបាលរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ ពុំអាចទទួលផលប្រយោជន៍អ្វី ដោយផ្ទាល់ ឬតាមរយៈស្វាមី ឬភរិយា ឬកូនរបស់ខ្លួននៅក្នុងសហគ្រាសឯកជនណាមួយ ដែលធ្វើអាជីវកម្មក្រោមសមត្ថកិច្ចអាជ្ញាធរជាតិនេះឡើយ ។

ក្នុងករណីមិនគោរពកាតព្វកិច្ចនេះ ក្រុមប្រឹក្សាភិបាលត្រូវធ្វើកំណត់ហេតុស្តីពីវិសមិតភាពការងាររបស់សាមីជន ហើយប្រកាសឱ្យលាលែងពីមុខតំណែងតែម្តង ។

## ជំពូកទី ៥
## ប្រភពធនធាន

**មាត្រា ១៤.-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានធនធានជា :

- វិភាគទានពីរដ្ឋ និងពីឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង
- អំណោយ និងវិភាគទានអន្តរជាតិ ដោយមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិនេះ
- ចំណូលបានមកពីសកម្មភាពផ្ទាល់របស់អាជ្ញាធរជាតិ ដូចជាបំណុល ថ្លៃឈ្នួល បានមកពីការចេញច្បាប់កាន់កាប់ផ្សេងៗ
- ប្រាក់កម្រៃបានមកពីប្រភពសេវាកម្មផ្សេងៗ ផ្តល់មកពីអង្គការសាធារណៈ ឬឯកជន
- កម្ចីដែលធ្វើឡើងតាមការយល់ព្រមពីក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិ
- ចលនវត្ថុ និងអចលនវត្ថុ ដែលសប្បុរសជន អង្គការជាតិ និងអន្តរជាតិប្រគល់ឱ្យ ។

**ត្រា ១៥.-**

គម្រោងចំណូល និងចំណាយសម្រាប់ឆ្នាំបន្ទាប់ ត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តយ៉ាងយូរបំផុតនៅថ្ងៃទី ០១ ខែតុលា ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែមិថុនា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៦០៦.៤៥៩

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

ហត្ថលេខា

សុខ អាន

លេខ : ២៤០ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**

# ព្រះរាជក្រឹត្យស្ដីពី
# ការបង្កើតអាជ្ញាធរជាតិព្រះវិហារ
# ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

# ព្រះរាជក្រឹត្យ

នស/រកត/០២២០/៤០៤

## ស្តីពី

## ការបង្កើតអាជ្ញាធរជាតិព្រះវិហារជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ

ROYAUME DU CAMBODGE

- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋាន ប្រាសាទកោះកែរ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៦ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការប្រគល់រមណីយដ្ឋាន ប្រាសាទកោះកែរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យស្ថិតនៅក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួន នៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្ត នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

ត្រូវបានបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានឈ្មោះថាអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិតំបន់ព្រះវិហារ សរសេរកាត់ជាភាសាខ្មែរ “**អ.ជ.ព.វ.**” ហៅកាត់ថា “**អាជ្ញាធរជាតិព្រះវិហារ**” និងជាភាសាអង់គ្លេស “National Authority for Preah Vihear” ហៅកាត់ថា

"NAPV" ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា២.–**

អាជ្ញាធរជាតិព្រះវិហារ គឺជានីតិបុគ្គលនៃនីតិសាធារណៈ និងមានថវិកាស្វយ័ត ដែលត្រូវឆ្លុះបញ្ចាំងជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

អាជ្ញាធរជាតិព្រះវិហារ មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅផ្លូវជាតិលេខ៦២ ភូមិធម្មជាតិសម្តេចតេជោ ឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ។

**មាត្រា៣.–**

អាជ្ញាធរជាតិព្រះវិហារ មានភារកិច្ចដូចខាងក្រោម ÷

- ការពារ ថែរក្សា អភិរក្ស គ្រប់គ្រង និងលើកតម្លៃបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទព្រះវិហារនិងប្រាសាទកោះកែរ ព្រមទាំងរមណីយដ្ឋានផ្សេងទៀតដែលត្រូវបានប្រគល់ជូន
- សិក្សារៀបចំ និងគ្រប់គ្រងធនធានធម្មជាតិដែលចាំបាច់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងរក្សាតុល្យភាពបរិស្ថាន ទឹក ព្រៃឈើ ដីធ្លី និងគុណភាពដី
- សិក្សាលើកតម្លៃ និងដាក់ឱ្យដំណើរការនូវគោលការណ៍ប្រតិបត្តិ រមណីយដ្ឋានប្រាសាទព្រះវិហារ ប្រាសាទកោះកែរ និងហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធទឹកបុរាណ ផ្លូវបុរាណ និងបេតិកភណ្ឌបុរាណ
- សិក្សារៀបចំអនុវត្តឱ្យបានសម្រេចនូវរាល់ផែនការសកម្មភាពរួមមាន កម្មវិធីនៃការរៀបចំមូលដ្ឋាននានាសម្រាប់ការអភិវឌ្ឍ និងកម្មវិធីអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ ដែលមានកំណត់នៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារនិងប្រាសាទកោះកែរ ដូចជាការគ្រប់គ្រងភ្ញៀវទេសចរ ពង្រឹងគុណភាពសេវាកម្មទេសចរណ៍ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងឧបរិរចនាសម្ព័ន្ធទេសចរណ៍ចាំបាច់នានាសម្រាប់បម្រើដល់សេវាកម្មទេសចរណ៍
- សិក្សារៀបចំនិងអភិវឌ្ឍសារមន្ទីរធម្មជាតិសកលសម្តេចតេជោ ហ៊ុន សែន ព្រះវិហារ ប្រកបដោយចីរភាព
- កំណត់ឱ្យមានសៀវភៅបន្ទុកសម្រាប់អង្គការ និងក្រុមហ៊ុននានា
- ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមដំណាក់កាលនីមួយៗ ដើម្បីធ្វើឱ្យបានសម្រេចនូវរាល់ការងារដែលបានដាក់ចេញដូចជា កម្មវិធីនៃការរៀបចំមូលដ្ឋាននានាសម្រាប់ការអភិវឌ្ឍ និងកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ដូចរៀបរាប់ខាងលើ

ROYAUME DU CAMBODGE * LE M... ROYAL *

- ប្រមូលចំណូលបានពីការអភិរក្ស និងការអភិវឌ្ឍរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកែរ និងតំបន់ផ្សេងៗទៀតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារនិងប្រាសាទកោះកែរ ជាពិសេសរៀបចំនិងអនុវត្តឱ្យបានសម្រេចនូវគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ច
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្តល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងទាំងឡាយដែលទាក់ទងនឹងបេសកម្មរបស់អាជ្ញាធរជាតិព្រះវិហារ ដើម្បីការការពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រាសាទព្រះវិហារនិងប្រាសាទកោះកែរ និងតំបន់ផ្សេងៗទៀតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារស្របតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន
- ប្រមូលចំណូលបានមកពីរាល់ព្រឹត្តិការណ៍ អាជីវកម្ម ពាណិជ្ជកម្មនៅរមណីយដ្ឋានប្រាសាទព្រះវិហារនិងប្រាសាទកោះកែរ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន
- សហការជាមួយអាជ្ញាធរខេត្ត មន្ទីរ/ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់វិទ្យាស្ថាន មូលនិធិ អង្គការជាតិនិងអន្តរជាតិនានា ដែលមានគោលបំណងស្របទៅនឹងទិសដៅរបស់អាជ្ញាធរជាតិព្រះវិហារ
- ដឹកនាំ សម្របសម្រួល សហការជាមួយនឹងអង្គភាពនានា ដែលបំពេញភារកិច្ចក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារនិងប្រាសាទកោះកែរ ចំពោះកិច្ចការពារបេតិកភណ្ឌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងការផ្តល់សេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកែរនិងតំបន់ពាក់ព័ន្ធផ្សេងៗទៀត ។

## ជំពូកទី២
## ការដឹកនាំ និងការគ្រប់គ្រង
### ផ្នែកទី១
### ក្រុមប្រឹក្សាភិបាលរបស់អាជ្ញាធរជាតិព្រះវិហារ

**មាត្រា៤.-**

អាជ្ញាធរជាតិព្រះវិហារ ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលជាអង្គការដឹកនាំខ្ពស់បំផុត និងមានបេសកកម្មតម្រង់ទិសការអនុវត្ត និងត្រួតពិនិត្យសកម្មភាពការងាររបស់អាជ្ញាធរជាតិព្រះវិហារ ក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៥.–**

អាជ្ញាធរជាតិព្រះវិហារ មានសមាជិកក្រុមប្រឹក្សាភិបាល ០៩ (ប្រាំបួន) រូប ដែលមានសមាសភាពដូចតទៅ ÷

- រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាងក្រសួងទេសចរណ៍ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- អភិបាលខេត្តព្រះវិហារ សមាជិក
- អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ សមាជិក
- តំណាងបុគ្គលិកនៃអាជ្ញាធរជាតិព្រះវិហារ សមាជិកស្វ័យប្រវត្តិ ។

ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិព្រះវិហារត្រូវបង្កើតក្នុងរយៈពេលយ៉ាងយូរ ១ (មួយ)ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតអាជ្ញាធរជាតិព្រះវិហារ ។

**មាត្រា៦.–**

តំណាងបុគ្គលិកនៃអាជ្ញាធរជាតិព្រះវិហារ ១ (មួយ) រូប គឺជាសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ ដែលត្រូវបានជ្រើសរើសដោយការបោះឆ្នោតក្នុងចំណោមបុគ្គលិកសម្រាប់អាណត្តិ ៣ (បី) ឆ្នាំ ។ តំណាងបុគ្គលិកត្រូវក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលចាប់ពីថ្ងៃជាប់ឆ្នោត ដោយមិនចាំបាច់មានការតែងតាំងឡើយ ។ នៅពេលចប់អាណត្តិ ឬលាឈប់ពីការងារ តំណាងបុគ្គលិកនេះ ត្រូវបាត់បង់សមាជិកភាពក្រុមប្រឹក្សាភិបាលដោយស្វ័យប្រវត្តិ ។

តំណាងបុគ្គលិកត្រូវជ្រើសរើសដោយការបោះឆ្នោតដែលប្រព្រឹត្តទៅតាមលក្ខណៈប្រជាធិបតេយ្យ ។ អ្នកមានសិទ្ធិបោះឆ្នោតសម្រាប់ ÷

ក. អាណត្តិដំបូងនៃក្រុមប្រឹក្សាភិបាលជាបុគ្គលិកអចិន្ត្រៃយ៍ ។

ខ. អាណត្តិនៃក្រុមប្រឹក្សាបន្តបន្ទាប់ទៀត ជាបុគ្គលិកទាំងអស់ដែលមានសិទ្ធិបោះឆ្នោតតាមការសម្រេចរបស់អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ។

តំណាងនេះ ត្រូវជ្រើសរើសពីក្នុងចំណោមបុគ្គលិកអចិន្ត្រៃយ៍ ដោយសំឡេងគាំទ្រភាគច្រើនដាច់ខាតស្របតាមលក្ខខណ្ឌវិនិច្ឆ័យ ដូចខាងក្រោម ÷

- មានសញ្ជាតិខ្មែរ មានអាយុយ៉ាងតិច ២៥ (ម្ភៃប្រាំ) ឆ្នាំ និងយ៉ាងច្រើន ៥៥ (ហាសិបប្រាំ) ឆ្នាំ

- បម្រើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ដោយយកចិត្តទុកដាក់ក្នុងការការពារផលប្រយោជន៍ឱ្យបុគ្គលិកទាំងអស់ និងអាជ្ញាធរជាតិព្រះវិហារ
- មានកិរិយាមារយាទល្អ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាព និងបទពិសោធន៍វិជ្ជាជីវៈគ្រប់គ្រាន់តាមសំណូមពរ និងលក្ខខណ្ឌនៃការងាររបស់អាជ្ញាធរជាតិព្រះវិហារ ។

នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសរើសតំណាងបុគ្គលិកជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិនីមួយៗ នៃអាជ្ញាធរជាតិព្រះវិហារ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ។

ក្រៅពីសមាជិកក្រុមប្រឹក្សាភិបាលស្វ័យប្រវត្តិ សមាជិកក្រុមប្រឹក្សាភិបាលដទៃទៀត ត្រូវមានអាណត្តិ ៣ (បី) ឆ្នាំ ដែលត្រូវបានតែងតាំង និងបញ្ចប់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ស្ថាប័ន ដែលសមាជិកនោះតំណាងឱ្យ ។ អាណត្តិនេះអាចបន្តសាជាថ្មីទៀតបានដោយអនុក្រឹត្យ ប៉ុន្តែមិនត្រូវលើសពី ២ (ពីរ) អាណត្តិឡើយ ។

**មាត្រា៧.-**

បេក្ខភាពជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការ ឬឥស្សរជនដែលមានលក្ខណសម្បត្តិ និងបទពិសោធន៍ ដូចខាងក្រោម÷

- មានសញ្ជាតិខ្មែរ
- បម្រើការងារយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ
- ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិម ឬបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងទំនុកចិត្ត និងសមត្ថភាពប្រកបវិជ្ជាជីវៈ
- មានសមត្ថភាពជំនាញនៅក្នុងវិស័យពាក់ព័ន្ធ ជាអាទិ៍ រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស ។

**មាត្រា៨.-**

សមាជិកភាពក្រុមប្រឹក្សាភិបាល អាចត្រូវបានបញ្ចប់មុនអាណត្តិតាមសំណើក្រសួង ស្ថាប័នតំណាង ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះជាអាទិ៍ បាត់បង់ភាពស្របច្បាប់ជាតំណាងក្រសួង ស្ថាប័នតំណាងបុគ្គលិករបស់គ្រឹះស្ថានទទួលមរណភាព សុំលាឈប់ជាលាយលក្ខណ៍អក្សរ បាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច និងត្រូវបានផ្តន្ទាទោសឱ្យជាប់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម

ក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួនរហូតដល់មានការតែងតាំងក្រុមប្រឹក្សាភិបាលថ្មី ។ ក្រុមប្រឹក្សាភិបាលអាណត្តិថ្មី ត្រូវតែងតាំងយ៉ាងយូរបំផុត ០១ (មួយ) ខែ ក្រោយការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាលចាស់ ។ មុនការបញ្ចប់អាណត្តិក្រុមប្រឹក្សាភិបាល ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវរៀបចំសំណើទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីចាត់បញ្ជូនបេក្ខភាពសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិថ្មី ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវទទួលខុសត្រូវលើភាពយឺតយ៉ាវនៃការស្នើតែងតាំងក្រុមប្រឹក្សាភិបាល ។ ការតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលនីមួយៗ ត្រូវមានបញ្ជាក់អំពីអាណត្តិដែលសមាជិកនោះត្រូវទទួល ។

សមាជិកក្រុមប្រឹក្សាភិបាលថ្មី ដែលត្រូវបានតែងតាំងជំនួសកន្លែងទំនេរ ស្របតាមលក្ខខណ្ឌខាងលើ មានអាណត្តិត្រឹមអាណត្តិដែលនៅសល់របស់សមាជិកក្រុមប្រឹក្សាភិបាល ។

មុខងារជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិព្រះវិហារ មានវិសមិតភាពជាមួយមុខងារជាអគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ។

លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាល មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា ។

ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ក្នុងក្របខ័ណ្ឌនៃការអនុវត្តមុខងារជាសមាជិកក្រុមប្រឹក្សាភិបាល ត្រូវជាបន្ទុករបស់អាជ្ញាធរជាតិព្រះវិហារ លើកលែងតែករណីដែលសមាជិកនោះបានប្រព្រឹត្តកំហុសដោយចេតនា ឬដោយធ្វេសប្រហែសធ្ងន់ធ្ងរ ។

សមាជិកនីមួយៗនៃក្រុមប្រឹក្សាភិបាល ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ។

សមាជិកក្រុមប្រឹក្សាភិបាល មានកាតព្វកិច្ចចូលរួមប្រជុំតាមការអញ្ជើញ ប្រកាន់ខ្ជាប់នូវគោលជំហរ រាយការណ៍ជាប្រចាំពីសកម្មភាពការងារក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចរបស់ខ្លួនជូនក្រសួង ស្ថាប័នដែលខ្លួនតំណាងឱ្យ គោរពក្រមសីលធម៌វិជ្ជាជីវៈ គោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរជាតិព្រះវិហារ ។

**មាត្រា៩.-**

សមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូបទទួលបានលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់ជាធរមាន ។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិព្រះវិហារ ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

ROYAUME DU CAMBODGE * LE ... ROYAL *

ការផ្ដល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗខាងលើ អាចត្រូវបានផ្អាកដោយក្រសួង ស្ថាប័ន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ ក្នុងករណីដែលសមាជិកក្រុមប្រឹក្សាភិបាលនោះ ពុំគោរពអាណត្តិកិច្ចរបស់ខ្លួន ដែលមានជាអាទិ៍ ÷

១. ការគោរពក្រមសីលធម៌វិជ្ជាជីវៈ និងមនសិការវិជ្ជាជីវៈ

២. ការគោរពបទបញ្ជា និងបទប្បញ្ញត្តិរបស់អាជ្ញាធរជាតិព្រះវិហារ

៣. ការបំពេញតួនាទី និងភារកិច្ចនៅក្នុងក្រុមប្រឹក្សាភិបាល

៤. ការអនុវត្តកាតព្វកិច្ចរាយការណ៍ពីសកម្មភាពការងាររបស់ខ្លួនជូនក្រសួង ស្ថាប័ន ដែលសមាជិកក្រុមប្រឹក្សាភិបាលនោះតំណាងឱ្យ ។

ប្រធានក្រុមប្រឹក្សាភិបាលអាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធន៍លើវិស័យពាក់ព័ន្ធ ដូចជា រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ និងបច្ចេកទេស និងតំណាងដៃគូអភិវឌ្ឍន៍ ឱ្យចូលរួមក្នុងអង្គប្រជុំក្រុមប្រឹក្សាភិបាលបាន ។ ឥស្សរជនទាំងនោះមានសិទ្ធិផ្ដល់មតិតែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ ។

**មាត្រា១០.-**

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំ តម្រង់ទិសការអនុវត្តសកម្មភាពការងារ និងត្រួតពិនិត្យលើដំណើរការរបស់អាជ្ញាធរជាតិព្រះវិហារ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ ÷

- ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍របស់អាជ្ញាធរជាតិព្រះវិហារសម្រាប់រយៈពេលខ្លី មធ្យម និងវែង
- ពិនិត្យ និងអនុម័តគម្រោងថវិកា និងផែនការលទ្ធកម្មប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ
- ពិនិត្យ និងអនុម័តរបាយការណ៍គ្រប់គ្រងអាជ្ញាធរជាតិព្រះវិហារ របាយការណ៍ហិរញ្ញវត្ថុ របាយ-ការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះអាជ្ញាធរជាតិព្រះវិហារ
- ជំរុញដំណើរការរបស់គណៈកម្មាធិការ និងគណៈកម្មការដែលបង្កើតឡើងដោយព្រះរាជក្រឹត្យនេះ ព្រមទាំងបង្កើតគណៈកម្មាធិការ និងគណៈកម្មការនានាតាមការចាំបាច់
- កំណត់នូវនីតិវិធីនៃការជ្រើសរើសបុគ្គលិក ការដំឡើងឋានន្តរស័ក្តិ ឬការផ្ដល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- ពិនិត្យ និងអនុម័តលើសំណើសុំកំណត់ក្របខ័ណ្ឌ និងចំនួនបុគ្គលិកប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ

ROYAUME DU CAMBODGE

- ធ្វើការវាយតម្លៃលើលទ្ធផលសម្រេចបានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងលើកវិធានការកែតម្រូវសម្រាប់អនុវត្តបន្ត ។

**មាត្រា១១.-**

យ៉ាងយូរ ០១ ខែ ក្រោយការបង្កើតក្រុមប្រឹក្សាភិបាល ប្រធានក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលលើកដំបូង ដែលរបៀបវារៈសំខាន់គឺ ការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិព្រះវិហារ ដែលក្នុងនោះត្រូវបញ្ជាក់ពីរចនាសម្ព័ន្ធ និងភារកិច្ចទូទៅរបស់អង្គភាពចំណុះនោះ ។

ក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិព្រះវិហារមានរបបប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំវិសាមញ្ញ តាមគំនិតផ្តួចផ្តើមរបស់ប្រធានក្រុមប្រឹក្សាភិបាល ឬតាមការស្នើសុំពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន ២ ភាគ ៣ ឬពីអគ្គនាយកអាជ្ញាធរជាតិព្រះវិហារតាមការចាំបាច់ ។

សម្រាប់ការប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ចាំបាច់ត្រូវដាក់បញ្ចូលរបៀបវារៈទាក់ទងនឹងការអនុវត្តថវិកា ការពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ។

អគ្គនាយកអាជ្ញាធរជាតិព្រះវិហារត្រូវចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយត្រូវជ្រើសរើសមន្ត្រីម្នាក់ជាលេខាធិការនៃអង្គប្រជុំ។ លេខាធិការនេះពុំមានសិទ្ធិបោះឆ្នោតទេ ។

ក្រុមប្រឹក្សាភិបាលធ្វើការពិភាក្សាលើរបៀបវារៈដែលបានគ្រោង ។ របៀបវារៈត្រូវបានជូនដំណឹងមុនយ៉ាងតិច ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការងារ ដល់គ្រប់សមាជិកក្រុមប្រឹក្សាភិបាល និងសមាជិកពាក់ព័ន្ធដទៃផ្សេងទៀត ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងមាត្រា៣៥ នៃព្រះរាជក្រឹត្យនេះ ត្រូវចូលរួមក្នុងសម័យប្រជុំរបស់ក្រុមប្រឹក្សាភិបាល តែមិនមានសិទ្ធិបោះឆ្នោត ។

ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានការចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលលើសពី ៥០ (ហាសិប) ភាគរយ ។ សមាជិករបស់ក្រុមប្រឹក្សាភិបាលអវត្តមានពុំអាចឱ្យគេជំនួសបានឡើយ ។

ប្រសិនបើកូរ៉ុមពុំបានគ្រប់គ្រាន់ នោះប្រធានក្រុមប្រឹក្សាភិបាលអាចកោះអញ្ជើញប្រជុំជាថ្មី ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃក្រោយ ។ ការប្រជុំលើកក្រោយនេះមិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈដែលខកខានពុំបានប្រជុំតាមការអញ្ជើញលើកទី ១ (មួយ) ប៉ុណ្ណោះ ។

សមាជិកដែលចូលរួមប្រជុំត្រូវចុះហត្ថលេខាលើបញ្ជីវត្តមាន ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានអនុម័តតាមមតិភាគច្រើននៃសមាជិកវត្តមាន ។ ក្នុងករណីមានសំឡេងស្មើគ្នា សំឡេងប្រធានក្រុមប្រឹក្សាភិបាលមានឧត្តមានុភាព ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយមានចុះហត្ថលេខារបស់ប្រធាន និងរក្សាទុកនៅទីស្នាក់ការរបស់អាជ្ញាធរជាតិព្រះវិហារ ។

កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុ ។ កំណត់ហេតុត្រូវឆ្លុះបញ្ចាំងពីភាពពិតនៃការពិភាក្សារបស់អង្គប្រជុំ ។ លេខាធិការនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ត្រូវរៀបចំ និងផ្ញើសេចក្តីព្រាងកំណត់ហេតុជូនសមាជិកក្រុមប្រឹក្សាភិបាលក្នុងរយៈពេល ០២ (ពីរ) ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំនីមួយៗ ។ សមាជិកក្រុមប្រឹក្សាភិបាលមានរយៈពេល ០៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលបានកំណត់ហេតុប្រជុំ ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ ឬផ្តល់មតិកែសម្រួលលើកំណត់ហេតុ ។ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទនៃកិច្ចប្រជុំ ប្រធានក្រុមប្រឹក្សាភិបាលចុះហត្ថលេខាលើកំណត់ហេតុ ដែលទទួលបានការកែតម្រូវ ឬការយល់ព្រមពីសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ ។

កំណត់ហេតុអង្គប្រជុំក្រុមប្រឹក្សាភិបាល និងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលខាងលើ ត្រូវបញ្ជូនក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយកាលបរិច្ឆេទនៃកិច្ចប្រជុំ ជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងជូនសមាជិកអង្គប្រជុំ ។

ការប្រជុំសាមញ្ញប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំត្រូវធ្វើឡើងជាចាំបាច់ ដោយមិនត្រូវឆ្លងខែបន្ទាប់នៃដំណាច់ត្រីមាស ឆមាស និងឆ្នាំ ។ ការខកខានមិនបានប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ គឺជាការទទួលខុសត្រូវផ្ទាល់របស់ប្រធានក្រុមប្រឹក្សាភិបាល ។

## ផ្នែកទី២
## អគ្គនាយកប្រតិបត្តិរបស់អាជ្ញាធរជាតិព្រះវិហារ

**មាត្រា១២.-**

អាជ្ញាធរជាតិព្រះវិហារ ត្រូវគ្រប់គ្រងដោយអគ្គនាយក ១ (មួយ) រូប ដែលត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។ អគ្គនាយកអាជ្ញាធរជាតិព្រះវិហារមានតួនាទីជានាយកប្រតិបត្តិ ។ ការតែងតាំងអគ្គនាយកត្រូវធ្វើឡើងយ៉ាងយូរ ០១ (មួយ) ខែ ក្រោយពីការចូលជាធរមាននៃព្រះរាជក្រឹត្យនេះ ។

មុខងារជាអគ្គនាយកអាជ្ញាធរជាតិព្រះវិហារ មានវិសមិតភាពជាមួយមុខងារជាសមាជិករាជរដ្ឋាភិបាល សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា និងជាមួយមុខងារជាប្រធានក្រុមប្រឹក្សាភិបាល ។

យ៉ាងយូរ ០១ (មួយ) ខែ ក្រោយការតែងតាំង អគ្គនាយកអាជ្ញាធរជាតិព្រះវិហារត្រូវចាត់ចែងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើក

ROYAUME DU CAMBODGE

**មាត្រា១៣.-**

អគ្គនាយកអាជ្ញាធរជាតិព្រះវិហារជាតំណាងរបស់អាជ្ញាធរជាតិព្រះវិហារក្នុងទំនាក់ទំនងជាមួយតតិយជន ។ អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ មានមុខងារ និងភារកិច្ចដូចតទៅ÷

- រៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល់និងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍អាជ្ញាធរជាតិព្រះវិហារ ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍គ្រប់គ្រងអាជ្ញាធរជាតិព្រះវិហារ របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងរបាយការណ៍លទ្ធកម្មសាធារណៈ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលស្ថិតក្រោមការកាន់កាប់ និងប្រើប្រាស់របស់អាជ្ញាធរជាតិព្រះវិហារ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- បញ្ជូនបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតម្កល់ទុក និងធ្វើការពិនិត្យតាមដាន ព្រមទាំងរាយការណ៍ជារៀងរាល់ឆ្នាំនូវលទ្ធផលនៃការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ នូវភារកិច្ចរបស់អង្គភាពចំណុះនានានៃអាជ្ញាធរជាតិព្រះវិហារ
- លើកសំណើរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការកំណត់មុខងារ ក្របខ័ណ្ឌ និងចំនួនមន្ត្រីរាជការនិងបុគ្គលិករបស់អាជ្ញាធរជាតិព្រះវិហារជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- គ្រប់គ្រង និងអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន
- បំពេញមុខងាររដ្ឋបាល និងគ្រប់គ្រងទាំងឡាយដទៃទៀត ដែលត្រូវបានប្រគល់ឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ មានសិទ្ធិស្នើទៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សុំតែងតាំងអគ្គនាយករង ០១ (មួយ) រូប ឬច្រើនរូបជាជំនួយការតាមការចាំបាច់ ។ អគ្គនាយករងត្រូវតែងតាំង និងបញ្ចប់

មុខងារដោយព្រះរាជក្រឹត្យ។ អគ្គនាយករង ត្រូវមានចំណេះដឹងលើផ្នែកបច្ចេកទេសតាមវិស័យនីមួយៗ ដែលត្រូវទទួលគ្រប់គ្រង ។

## ផ្នែកទី៣
## បុគ្គលិករបស់អាជ្ញាធរជាតិព្រះវិហារ

**មាត្រា១៤.-**

បុគ្គលិកអចិន្ត្រៃយ៍របស់អាជ្ញាធរជាតិព្រះវិហារ គឺជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានតែងតាំងឱ្យបម្រើការងារនៅអាជ្ញាធរជាតិព្រះវិហារ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

អាជ្ញាធរជាតិព្រះវិហារ អាចត្រូវអនុញ្ញាតឱ្យជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាដើម្បីបំពេញការងារតាមតម្រូវការចាំបាច់របស់ខ្លួន ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

បុគ្គលិករបស់អាជ្ញាធរជាតិព្រះវិហារ ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជាផ្ទៃក្នុង ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល ។

ចំពោះមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ បទបញ្ជាផ្ទៃក្នុងស្តីពីបុគ្គលិក ត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដទៃទៀតរបស់មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ។

មន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបំពេញភារកិច្ចនៅអាជ្ញាធរជាតិព្រះវិហារ ទទួលបានការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ពីថវិការដ្ឋស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ ក្រៅពីថវិការដ្ឋ ជូនបុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកជាប់កិច្ចសន្យានៃអាជ្ញាធរជាតិព្រះវិហារ ត្រូវសម្រេចជាគោលការណ៍ដោយរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ បន្ទាប់ពីមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល ។

## ផ្នែកទី៤
## ទ្រព្យសម្បត្តិរបស់អាជ្ញាធរជាតិព្រះវិហារ

**មាត្រា១៥.-**

អាជ្ញាធរជាតិព្រះវិហារ ត្រូវទទួលខុសត្រូវគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមលក្ខខណ្ឌកំណត់ដោយច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

អាជ្ញាធរជាតិព្រះវិហារមានទ្រព្យសម្បត្តិ ដែលរួមមាន÷

ROYAUME DU CAMBODGE

ក. ធនធានគ្រាដំបូងទទួលបានពីរដ្ឋ ដែលមានបញ្ជាក់ក្នុងតារាងតុល្យការភ្ជាប់ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិព្រះវិហារនេះ ។ តារាងតុល្យការនៃធនធានគ្រាដំបូងនេះ ត្រូវរៀបចំដោយគណៈកម្មការអន្តរក្រសួង រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងទទួលបានការឯកភាពពីអាណាព្យាបាលទាំងពីរ ។ តារាងតុល្យការត្រូវមានភ្ជាប់បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរួមជាមួយនឹងតារាងឧបសម្ព័ន្ធពាក់ព័ន្ធនានា ។

ខ. ទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែលអាចរកបានក្រោយថ្ងៃបង្កើតអាជ្ញាធរជាតិព្រះវិហារ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

អាជ្ញាធរជាតិព្រះវិហារត្រូវបង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌដើម្បីរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់អាជ្ញាធរជាតិព្រះវិហារ ។ អគ្គនាយកដែលជាប្រធាន និងសមាជិកដទៃទៀតនៃគណៈកម្មការនេះ ត្រូវទទួលខុសត្រូវ និងចុះហត្ថលេខាលើបញ្ជីសារពើភណ្ឌដែលបានរៀបចំរួច ។ ការរៀបចំបញ្ជីសារពើភណ្ឌ ត្រូវបំពេញទិន្នន័យរបស់ទ្រព្យសម្បត្តិនីមួយៗ ឱ្យបានពេញលេញ និងគ្រប់ជ្រុងជ្រោយ ដោយអនុលោមទៅតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អាជ្ញាធរជាតិព្រះវិហារ មានកាតព្វកិច្ចរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ កើនឡើង និងថយចុះប្រចាំឆ្នាំនីមួយៗឱ្យបានត្រឹមត្រូវ ដោយយកបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ភ្ជាប់នឹងតារាងតុល្យការនៃធនធានគ្រាដំបូងជាគោល រួចហើយត្រូវផ្ញើមកអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋយ៉ាងយូរ នៅចុងត្រីមាសទី១នៃឆ្នាំបន្ទាប់ ។

អាជ្ញាធរជាតិព្រះវិហារ អាចធ្វើការទិញ-លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីចលនទ្រព្យ និងអចលនទ្រព្យ លុះត្រាតែទ្រព្យសម្បត្តិទាំងនោះត្រូវបានចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋ ។ លក្ខខណ្ឌនិងនីតិវិធីនៃការទិញ- លក់ ដូរ ជួល ផ្ទេរ និងធ្វើការជម្រះបញ្ជីនូវទ្រព្យសម្បត្តិរដ្ឋទាំងនោះ ត្រូវស្របតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ ហើយត្រូវស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ។

ក្នុងករណីដែលអាជ្ញាធរជាតិព្រះវិហារត្រូវធ្វើការរំលាយ លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយព្រះរាជក្រឹត្យ ទ្រព្យសកម្មដែលជាចលនទ្រព្យ និងអចលនទ្រព្យរបស់អាជ្ញាធរជាតិព្រះវិហារ ត្រូវបង្វិលចូលជាកម្មសិទ្ធិរបស់រដ្ឋវិញ ក្រោយពីការជម្រះបញ្ជីតាមនីតិវិធីជាធរមាន ។ ចំពោះទ្រព្យសកម្មជារូបិយវត្ថុ ត្រូវបង់ចូលគណនីទោលរបស់រតនាគារជាតិ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

## ផ្នែកទី៥
## ការគ្រប់គ្រងហិរញ្ញវត្ថុនិងគណនេយ្យរបស់អាជ្ញាធរជាតិព្រះវិហារ

**មាត្រា១៦.-**

អាជ្ញាធរជាតិព្រះវិហារ ត្រូវមានគណនេយ្យភាពចំពោះក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

**មាត្រា១៧.-**

អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ជាអាណាប័កផ្ទេរសិទ្ធិនៃថវិការបស់អាជ្ញាធរជាតិព្រះវិហារ ដែលទទួលបានការប្រគល់សិទ្ធិពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដែលជាអាណាប័កដើមខ្សែ មានសិទ្ធិអំណាច ដូចតទៅ ÷

- បញ្ជា និងជម្រះចំណូល
- បញ្ជាចំណាយ ជម្រះបញ្ជី និងចេញអាណត្តិបើកប្រាក់ ។

ក្នុងនាមជាអាណាប័កផ្ទេរសិទ្ធិ អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ អាចផ្ទេរសិទ្ធិនេះបន្តឱ្យអាណាប័កជំនួស ដោយមានការយល់ព្រមពីអាណាប័កដើមខ្សែ ។

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវតែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អាជ្ញាធរជាតិព្រះវិហារ តាមសំណើរបស់អគ្គនាយក និងដោយមានការសម្រេចជាមុនពីក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុនៅអាជ្ញាធរជាតិព្រះវិហារ ។ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម ÷

- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុ
- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ច ឬផ្នែកហិរញ្ញវត្ថុយ៉ាងតិច ០៣ (បី) ឆ្នាំ
- ធ្លាប់បានឆ្លងកាត់វគ្គបណ្ដុះបណ្ដាលផ្នែកហិរញ្ញវត្ថុសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា១៨.-**

កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ និងការកាន់កាប់បញ្ជីគណនេយ្យ ត្រូវអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្រោមការទទួលខុសត្រូវផ្ទាល់របស់គណនេយ្យករ ។

គណនេយ្យករត្រូវមានគុណវុឌ្ឍិ ព្រមទាំងបទពិសោធន៍វិជ្ជាជីវៈច្បាស់លាស់ គ្រប់គ្រាន់និងបំពេញលក្ខខណ្ឌផ្សេងទៀត ដែលស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ គណនេយ្យករ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

គណនេយ្យករ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ ។

គណនេយ្យករមានភារកិច្ច ÷

- គ្រប់គ្រងការប្រមូលចំណូល
- ទូទាត់ចំណាយ
- រក្សាទុកនិងគ្រប់គ្រងការប្រើប្រាស់នូវមូលនិធិ និងវត្ថុមានតម្លៃ
- រក្សាទុកនូវលិខិតយុត្តិការ និងកាន់កាប់បញ្ជីគណនេយ្យ
- ចូលរួមរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់អាជ្ញាធរជាតិព្រះវិហារ ។

គណនេយ្យករ អាចមានមន្ត្រីជំនាញមួយចំនួនជាជំនួយការក្នុងការបំពេញមុខងាររបស់ខ្លួន ។

**មាត្រា១៩.-**

ប្រភពធនធានរបស់អាជ្ញាធរជាតិព្រះវិហារ រួមមាន÷

- ធនធានដំបូងរបស់រដ្ឋផ្តល់ជូនអាជ្ញាធរជាតិព្រះវិហារនៅពេលចាប់ផ្តើមបង្កើតដំបូង ស្របតាមមាត្រា ១៥ នៃព្រះរាជក្រឹត្យនេះ
- ការផ្ទេរក្នុងលក្ខណៈជាអន្តរាគមន៍សាធារណៈដែលមានគ្រោងក្នុងថវិការដ្ឋដូចជា ឧបត្ថម្ភកធនសម្រាប់ដំណើរការ និងឧបត្ថម្ភកធនជាមូលធន
- អំណោយ ជំនួយ និងអច្ច័យទានដែលអាជ្ញាធរជាតិព្រះវិហារបានទទួល
- កម្រៃសេវាសាធារណៈ ឬភាគទានដែលអាជ្ញាធរជាតិព្រះវិហារមានសិទ្ធិប្រមូល ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- កម្រៃពីទ្រព្យសម្បត្តិរបស់អាជ្ញាធរជាតិព្រះវិហារ និងចំណូលពីការលក់ទ្រព្យសម្បត្តិទាំងនោះស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា២០.-**

ចំណូល ចំណាយចរន្ត និងមូលធនរបស់អាជ្ញាធរជាតិព្រះវិហារ ត្រូវគ្រោងក្នុងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ និងត្រូវឆ្លុះបញ្ចាំងជាឧបសម្ពន្ធនៃថវិកាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។ ចំណូលរបស់អាជ្ញាធរជាតិព្រះវិហារ រួមមានការឧបត្ថម្ភពីថវិការដ្ឋ ចំណូលផ្ទាល់ និងចំណូលផ្សេងៗ ស្របតាមមាត្រា១៩ ។

ថវិកាត្រូវរៀបចំដោយអគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ និងអនុម័ត រួចបញ្ជូនទៅក្រសួងវប្បធម៌និងវិចិត្រសិល្បៈពិនិត្យនិងសម្រេច មុននឹងបញ្ជូនបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយអនុលោមតាមប្រតិទិននៃការរៀបចំថវិកាប្រចាំឆ្នាំ ដូចមានចែងក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

ថវិកាត្រូវមានតុល្យភាពរវាងចំណូល និងចំណាយ ។

ចំណូល និងចំណាយរបស់អាជ្ញាធរជាតិព្រះវិហារ ត្រូវគោរពតាមវិធាននៃចំណាត់ថ្នាក់ និងការគ្រប់គ្រងដូចថវិការដ្ឋដែរ ។

ចំណាយត្រូវឆ្លុះបញ្ចាំងនូវគ្រប់មុខសញ្ញានៃការប្រើប្រាស់ពីគ្រប់ប្រភពឥណទាន ។

អាជ្ញាធរជាតិព្រះវិហារមិនអាចបង្កើតលក្ខខណ្ឌដែលនាំឱ្យមានឱនភាពថវិកាឡើយ ក្នុងអំឡុងពេលនៃការអនុវត្តថវិកាប្រចាំឆ្នាំ លើកលែងតែមានការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា២១.-**

គណនេយ្យរបស់អាជ្ញាធរជាតិព្រះវិហារ រួមមាន÷

- គណនេយ្យទូទៅដែលគោរពតាមគោលការណ៍ទ្វេភាគ ដែលឆ្លុះបញ្ចាំងគ្រប់ប្រតិបត្តិការ ថវិកាប្រតិបត្តិការសាច់ប្រាក់ និងប្រតិបត្តិការជាមួយតតិយជន
- គណនេយ្យអចលនទ្រព្យ ទ្រព្យសកម្ម និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើមានការចាំបាច់ ។

កិច្ចបញ្ជិកាគណនេយ្យរបស់អាជ្ញាធរជាតិព្រះវិហារ ត្រូវរៀបចំស្របតាមវិធានទូទៅ និងប្លង់គណនេយ្យសាធារណៈ ។

គោលការណ៍ណែនាំស្តីពីកិច្ចបញ្ជិកាគណនេយ្យទូទៅ គណនេយ្យរដ្ឋទេយ្យបុរេប្រទាន និងគណនេយ្យរដ្ឋទេយ្យចំណូលរបស់អាជ្ញាធរជាតិព្រះវិហារ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**មាត្រា២២.-**

ថវិការបស់អាជ្ញាធរជាតិព្រះវិហារ គឺជាមូលនិធិសាធារណៈរបស់រដ្ឋ ។

ថវិការបស់អាជ្ញាធរជាតិព្រះវិហារ ដែលមានប្រភពឧបត្ថម្ភធនពីថវិការដ្ឋ ត្រូវដាក់ចូលក្នុងគណនីនៅរតនាគារជាតិជាចាំបាច់ លើកលែងតែមានបដិប្បញ្ញត្តិដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាចអនុញ្ញាតឱ្យអាជ្ញាធរជាតិព្រះវិហារប្រើប្រាស់គណនីនៅធនាគារពាណិជ្ជសម្រាប់គ្រប់គ្រងថវិកា ដែលបានមកពីចំណូលផ្ទាល់ និងពីប្រភពផ្សេងៗទៀត ។

អតិរេករបស់អាជ្ញាធរជាតិព្រះវិហារ ត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល ។ អតិរេកនេះត្រូវមានការបញ្ជាក់ទទួលស្គាល់ពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អតិរេកនេះអាចត្រូវបានចាត់ចែង សម្រាប់ធ្វើហិរញ្ញប្បទានដល់ចំណាយប្រតិបត្តិការនាការិយបរិច្ឆេទបន្ទាប់ ឬសម្រាប់ការវិនិយោគជាប្រយោជន៍ដល់ការអភិវឌ្ឍអាជ្ញាធរជាតិព្រះវិហារ ឬជាកម្មវត្ថុនៃការបង់

ចូលថវិកាជាតិ ។ ការចាត់ចែងអតិរេកនេះត្រូវមានការយល់ព្រមពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ផ្នែកទី៦
## របបសារពើពន្ធរបស់អាជ្ញាធរជាតិព្រះវិហារ

**មាត្រា២៣.-**

អាជ្ញាធរជាតិព្រះវិហារ ត្រូវស្ថិតនៅក្រោមនីតិវិធីនៃរបបសារពើពន្ធជាធរមាន លើកលែងតែមានបដិប្បញ្ញត្តិដែលចែងដោយច្បាប់ ។

## ផ្នែកទី៧
## ការងារលទ្ធកម្មរបស់អាជ្ញាធរជាតិព្រះវិហារ

**មាត្រា២៤.-**

ការគ្រប់គ្រង ការអនុវត្ត និងការត្រួតពិនិត្យការងារលទ្ធកម្មនៅអាជ្ញាធរជាតិព្រះវិហារត្រូវអនុលោមតាមច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ។

## ជំពូកទី៣
## អាណាព្យាបាលភាព

**មាត្រា២៥.-**

អាជ្ញាធរជាតិព្រះវិហារមានអាណាព្យាបាល ២ (ពីរ) ដូចខាងក្រោម ÷

១-អាណាព្យាបាលបច្ចេកទេស គឺក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

២-អាណាព្យាបាលហិរញ្ញវត្ថុ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានអគ្គនាយកដ្ឋានថវិកាជាសេនាធិការក្នុងការសម្របសម្រួលគ្រប់គ្រងអាជ្ញាធរជាតិព្រះវិហារ ។

**មាត្រា២៦.-**

អាណាព្យាបាលបច្ចេកទេស និងអាណាព្យាបាលហិរញ្ញវត្ថុ អាចចាត់មន្ត្រីមានសមត្ថកិច្ចឱ្យធ្វើអធិការកិច្ចសវនកម្ម តាមដាន និងត្រួតពិនិត្យលើកិច្ចប្រតិបត្តិការនានារបស់អាជ្ញាធរជាតិព្រះវិហារតាមការចាំបាច់ ។

**មាត្រា២៧.-**

អាជ្ញាធរជាតិព្រះវិហារត្រូវផ្តល់ជូនអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំអាជ្ញាធរជាតិព្រះវិហារក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយការពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាភិបាលនូវឯកសារដូចខាងក្រោម ÷

- កំណត់ហេតុនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល

ROYAUME DU CAMBODGE

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍន៍អាជ្ញាធរជាតិព្រះវិហារ
- គម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ
- របាយការណ៍គ្រប់គ្រងអាជ្ញាធរជាតិព្រះវិហារ របាយការណ៍គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ របាយការណ៍លទ្ធកម្មសាធារណៈ និងរបាយការណ៍ហិរញ្ញវត្ថុ ។

ទទួលបានឯកសារខាងលើ អាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុប្រចាំអាជ្ញាធរជាតិព្រះវិហារ ត្រូវចាត់ការបន្តតាមសមត្ថកិច្ចរៀងៗខ្លួន ស្របតាមបទប្បញ្ញត្តិជាធរមាន ។

## ផ្នែកទី១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា២៨.-**

អាណាព្យាបាលបច្ចេកទេស មានភារកិច្ចដូចខាងក្រោម÷

- កំណត់គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរជាតិព្រះវិហារអនុវត្ត
- ពិនិត្យ និងសម្រេចផែនការអភិវឌ្ឍន៍របស់អាជ្ញាធរជាតិព្រះវិហារ
- ពិនិត្យ និងសម្រេចលើសេចក្តីព្រាងនៃគម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ
- ពិនិត្យ និងសម្រេចលើសំណើចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងជម្រះបញ្ជីសារពើភណ្ឌ
- ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃការអនុវត្តផ្នែកបច្ចេកទេសរបស់អាជ្ញាធរជាតិព្រះវិហារ
- ដាក់ចេញនូវវិធានការកែលម្អនានា ពាក់ព័ន្ធនឹងការអនុវត្តផ្នែកបច្ចេកទេសរបស់អាជ្ញាធរជាតិព្រះវិហារ
- ពិនិត្យ និងសម្រេចអំពីរចនាសម្ព័ន្ធនៃអាជ្ញាធរជាតិព្រះវិហារ
- ស្នើតែងតាំងអគ្គនាយកអាជ្ញាធរជាតិព្រះវិហារ
- តែងតាំងមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលបម្រើការងារនៅអាជ្ញាធរជាតិព្រះវិហារ អនុលោមតាមបទប្បញ្ញត្តិជាធរមាន
- តែងតាំងមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុរបស់អាជ្ញាធរជាតិព្រះវិហារ ។

**មាត្រា២៩.-**

អនុលោមតាមបទប្បញ្ញត្តិជាធរមាន អាណាព្យាបាលបច្ចេកទេស ត្រូវផ្ញើជូនអាណាព្យាបាលហិរញ្ញវត្ថុជាលាយលក្ខណ៍អក្សរ នូវការសម្រេចទាំងឡាយរបស់ខ្លួន និងរបស់ក្រុមប្រឹក្សាភិបាល ដែលពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដើម្បីពិនិត្យនិងសម្រេច មានជាអាទិ៍ ÷

- ផែនការអភិវឌ្ឍន៍អាជ្ញាធរជាតិព្រះវិហារ
- គម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ
- ការចាត់ចែង ការប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ

- សេចក្តីសម្រេចស្តីពីការផ្តល់លាភការ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- សេចក្តីសម្រេចផ្សេងទៀត ដែលអាចមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ ។

**មាត្រា៣០.-**

អាណាព្យាបាលបច្ចេកទេសមានសិទ្ធិលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចពាក់ព័ន្ធនឹងអាជ្ញាធរជាតិព្រះវិហារក្នុងករណីដែល ÷

- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬអគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ផ្ទុយនឹងគោលនយោបាយ ឬយុទ្ធសាស្ត្ររបស់អាជ្ញាធរជាតិព្រះវិហារ ក៏ដូចជារបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬអគ្គនាយកអាជ្ញាធរជាតិព្រះវិហារផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សេចក្តីសម្រេចធ្វើឡើងដោយក្រសួង ស្ថាប័ន អាជ្ញាធរដែលមិនមានសមត្ថកិច្ចតាមផ្លូវច្បាប់ ឬសេចក្តីសម្រេចធ្វើឡើងដោយការប្រជុំក្រុមប្រឹក្សាភិបាល ដែលពុំអនុលោមតាមនីតិវិធី
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេង ដែលពុំទាន់បានដោះស្រាយរួច ។

ការលុបចោល ឬការផ្អាកខាងលើនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ដោយមានបញ្ជាក់ពីមូលហេតុច្បាស់លាស់ ។ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈត្រូវជូនដំណឹងអំពីប្រកាសនេះដល់អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ។ អគ្គនាយកអាជ្ញាធរជាតិព្រះវិហារត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា៣១.-**

ក្នុងករណីដែលក្រុមប្រឹក្សាភិបាល ឬអគ្គនាយកអាជ្ញាធរជាតិព្រះវិហារ មិនប្រតិបត្តិតាមបណ្តាវិធានដែលមានចែងក្នុងច្បាប់ ឬបទប្បញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់អាជ្ញាធរជាតិព្រះវិហារ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈអាចចាត់ចែងការងារចេញសេចក្តីសម្រេច និងអាចប្រើប្រាស់វិធានការចាំបាច់ទាំងអស់ បន្ទាប់ពីបានធ្វើការណែនាំ និងដាក់កំហិតជាលាយលក្ខណ៍អក្សររួចមក ។

## ផ្នែកទី ២
## អាណាព្យាបាលហិរញ្ញវត្ថុ

**មាត្រា៣២.-**

អាណាព្យាបាលហិរញ្ញវត្ថុ មានភារកិច្ច÷

- ពិនិត្យ និងផ្តល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍អាជ្ញាធរជាតិព្រះវិហារ
- ពិនិត្យ និងសម្រេចលើគម្រោងថវិកាប្រចាំឆ្នាំរបស់អាជ្ញាធរជាតិព្រះវិហារ
- ពិនិត្យ និងអនុម័តផែនការលទ្ធកម្មរបស់អាជ្ញាធរជាតិព្រះវិហារ
- ពិនិត្យ និងសម្រេចលើការចាត់ចែង ប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋ និងការជម្រះបញ្ជីសារពើភណ្ឌ
- ពិនិត្យ និងផ្តល់ការយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ពិនិត្យ និងសម្រេចលើសេចក្តីសម្រេចស្តីពីការផ្តល់លាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ
- ពិនិត្យ និងសម្រេច ឬផ្តល់ការយល់ព្រមលើឯកសារផ្សេងទៀត តាមសំណើរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ឬអគ្គនាកដ្ឋានអាជ្ញាធរជាតិព្រះវិហារ ស្របតាមបទប្បញ្ញត្តិជាធរមាន

- រៀបចំ និងដាក់ឱ្យអនុវត្តនូវវិធាននិងនីតិវិធីចំណូល ចំណាយ បទដ្ឋានចំណូល ចំណាយ និងបទដ្ឋានគតិយុត្តទាំងឡាយដទៃទៀត ពាក់ព័ន្ធនឹងហិរញ្ញវត្ថុរបស់អាជ្ញាធរជាតិព្រះវិហារ ។

**មាត្រា៣៣.-**

សេចក្តីសម្រេចរបស់អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ក្រុមប្រឹក្សាភិបាល និងរបស់អាណាព្យាបាលបច្ចេកទេសដែលពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា៣២ នៃព្រះរាជក្រឹត្យនេះ ពុំមានអានុភាពអនុវត្តឡើយ ក្នុងករណីដែលពុំមានការយល់ព្រមពីអាណាព្យាបាលហិរញ្ញវត្ថុ ។

ក្នុងករណីអាណាព្យាបាលហិរញ្ញវត្ថុជំទាស់លើសេចក្តីសម្រេច ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវផ្ញើជូនអាណាព្យាបាលបច្ចេកទេស និងអគ្គនាយកអាជ្ញាធរជាតិព្រះវិហារនូវការជំទាស់របស់ខ្លួន ដោយបញ្ជាក់នូវមូលហេតុច្បាស់លាស់ ។ អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ត្រូវពិនិត្យនិងដោះស្រាយឱ្យបានឆាប់បំផុតនូវករណីដែលបានលើកឡើងនោះ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

**មាត្រា៣៤.-**

អាណាព្យាបាលហិរញ្ញវត្ថុ អាចលុប ឬផ្អាកការអនុវត្តសេចក្តីសម្រេចចិត្តពាក់ព័ន្ធទិដ្ឋភាពហិរញ្ញវត្ថុ របស់អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ក្នុងករណីដែល ÷

- សេចក្តីសម្រេចរបស់អគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ក្រុមប្រឹក្សាភិបាល និងអាណាព្យាបាលបច្ចេកទេស ផ្ទុយនឹងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
- សេចក្តីសម្រេចមានការពាក់ព័ន្ធនឹងបណ្តឹងផ្សេងៗដែលពុំទាន់បានដោះស្រាយរួច ។

ការលុបចោល ឬការផ្អាកទុកនេះត្រូវមានបញ្ជាក់ពីមូលហេតុច្បាស់លាស់ និងត្រូវជូនដំណឹងដល់អាណាព្យាបាលបច្ចេកទេស និងអគ្គនាយកអាជ្ញាធរជាតិព្រះវិហារ ដែលត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាលក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា៣៥.-**

អាណាព្យាបាលហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ១ (មួយ) រូប ប្រចាំអាជ្ញាធរជាតិព្រះវិហារ ដើម្បីបំពេញមុខងារដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធជាធរមាន ។

## ជំពូកទី៤
## ការត្រួតពិនិត្យ

**មាត្រា៣៦.-**

អាជ្ញាធរជាតិព្រះវិហារត្រូវមានអង្គភាពសវនកម្មផ្ទៃក្នុង ដែលត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយអាណាព្យាបាលបច្ចេកទេស តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា៣៧.-**

អាជ្ញាធរជាតិព្រះវិហារត្រូវស្ថិតក្រោមការធ្វើអធិការកិច្ច សវនកម្ម តាមដាន ត្រួតពិនិត្យដោយអាណាព្យាបាលបច្ចេកទេស អាណាព្យាបាលហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិ ស្របតាមច្បាប់ជាធរមាន ។

ក្នុងករណីចាំបាច់ អាជ្ញាធរជាតិព្រះវិហារអាចតម្រូវឱ្យស្ថិតក្រោមការធ្វើសវនកម្មដោយសវនករឯករាជ្យដែលមានការទទួលស្គាល់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**អវសានប្បញ្ញត្តិ**

**មាត្រា៣៨.–**

ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី/០១ ខែមិថុនា ឆ្នាំ២០០៦ ស្ដីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣៩.–**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ថ្ងៃ ព្រហស្បតិ៍ ១២រោច ខែ មាឃ ឆ្នាំ កុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២០

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នស/រកត/០២២០/២១២

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

២១/២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

# អនុក្រឹត្យស្តីពី
# ការរៀបចំ និងប្រព្រឹត្តទៅនៃ
# អាជ្ញាធរជាតិព្រះវិហារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ២៨៧០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិព្រះវិហារ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌

- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១២០/១២៨៨ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៤ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិព្រះវិហារ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/៣១៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ស្តីពីការផ្ទេរអាជ្ញាធរ គណៈកម្មាធិការ គណៈកម្មការ និងក្រុមប្រឹក្សាដែលស្ថិតក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យស្ថិតក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់ក្រសួងមានសមត្ថកិច្ចពាក់ព័ន្ធ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៤១៦ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៦ ស្តីពីការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិ នៃប្រាសាទព្រះវិហារ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានឃើញ អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ៩៨ អនក្រ.បក ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិព្រះវិហារ ដែលសរសេរកាត់ថា **អ.ជ.ព.វ.** ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់នាយកដ្ឋាន និងអង្គភាពនៃ **អ.ជ.ព.វ.** ។

## ជំពូកទី២

## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

### ផ្នែកទី១

### បេសកកម្ម មុខងារ និងភារកិច្ច

**មាត្រា៣ .-**

**អ.ជ.ព.វ.** បំពេញមុខងារជាសេនាធិការឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើបេសកកម្ម ដឹកនាំ គ្រប់គ្រង ចាត់ចែង អភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទព្រះវិហារ និងរមណីយដ្ឋានប្រាសាទកោះកេរ ព្រមទាំងរមណីយដ្ឋានផ្សេងទៀតដែលត្រូវបានប្រគល់ជូន។

**មាត្រា៤ .-**

**អ.ជ.ព.វ.** មានមុខងារនិងភារកិច្ចដូចតទៅ៖

- ការពារ ថែរក្សា អភិរក្ស គ្រប់គ្រង និងលើកតម្លៃបុរាណវិទ្យា វប្បធម៌ បរិស្ថាន និងប្រវត្តិសាស្ត្រនៃរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ ព្រមទាំងរមណីយដ្ឋានផ្សេងទៀតដែលត្រូវបានប្រគល់ជូន
- សិក្សា រៀបចំ និងគ្រប់គ្រងធនធានធម្មជាតិដែលចាំបាច់សម្រាប់អភិវឌ្ឍប្រកបដោយចីរភាព និងរក្សាគុណភាពបរិស្ថាន ទឹក ព្រៃឈើ និងគុណភាពដី
- សិក្សាលើកតម្លៃ និងដាក់ឱ្យដំណើរការឡើងវិញនូវគោលការណ៍ប្រតិបត្តិរមណីយដ្ឋានប្រាសាទព្រះវិហារ ប្រាសាទកោះកេរ និងហេដ្ឋារចនាសម្ព័ន្ធ ដូចជាប្រព័ន្ធទឹកបុរាណ ផ្លូវបុរាណ និងបេតិកភណ្ឌបុរាណ
- សិក្សារៀបចំអនុវត្តឱ្យបានសម្រេចនូវរាល់ផែនការសកម្មភាពរួមមាន កម្មវិធីនៃការរៀបចំមូលដ្ឋាននានាសម្រាប់ការអភិវឌ្ឍ និងកម្មវិធីអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាពក្នុងតំបន់ ដែលមានកំណត់ក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ ដូចជាការគ្រប់គ្រងភ្ញៀវទេសចរ ពង្រឹងគុណភាពសេវាកម្មទេសចរណ៍ ការរៀបចំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងឧបរិចនាសម្ព័ន្ធទេសចរណ៍ចាំបាច់នានា សម្រាប់បម្រើដល់សេវាកម្មទេសចរណ៍
- កំណត់ឱ្យមានសៀវភៅបន្ទុកសម្រាប់អង្គការ និងក្រុមហ៊ុននានា

- ស្វែងរកប្រភពហិរញ្ញប្បទាន ទុនវិនិយោគ និងវាយតម្លៃលើការអនុវត្តតាមដំណាក់កាលនីមួយៗ ដើម្បីធ្វើឱ្យបានសម្រេចនូវរាល់ការងារដែលបានដាក់ចេញដូចជា កម្មវិធីនៃការរៀបចំមូលដ្ឋាននានាសម្រាប់ការអភិវឌ្ឍ និងកម្មវិធីអភិវឌ្ឍទេសចរណ៍ដូចរៀបរាប់ខាងលើ
- ប្រមូលចំណូលពីការអភិរក្ស និងការអភិវឌ្ឍរមណីយដ្ឋានប្រាសាទព្រះវិហារ និងរមណីយដ្ឋានប្រាសាទកោះកេរ និងតំបន់ផ្សេងទៀតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រួមចំណែកក្នុងការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ និងរមណីយដ្ឋានប្រាសាទកោះកេរ ជាពិសេសរៀបចំនិងអនុវត្តឱ្យបានសម្រេចនូវគម្រោងអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមកិច្ច
- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្តល់ការអនុញ្ញាតឱ្យវិនិយោគនូវគម្រោងទាំងឡាយដែលទាក់ទងនឹងបេសកកម្មរបស់ **អ.ជ.ព.វ.** ដើម្បីការពារនិងការអភិវឌ្ឍរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ និងតំបន់ផ្សេងទៀតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ស្របតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន
- ប្រមូលចំណូលបានមកពីរាល់ព្រឹត្តិការណ៍ អាជីវកម្ម ពាណិជ្ជកម្មនៅរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន
- សហការជាមួយអាជ្ញាធរខេត្ត មន្ទីរ/ក្រសួង ស្ថាប័នពាក់ព័ន្ធ គ្រប់វិទ្យាស្ថាន មូលនិធិ អង្គការជាតិ និងអន្តរជាតិនានា ដែលមានគោលបំណងស្របទៅនឹងទិសដៅរបស់ **អ.ជ.ព.វ.**
- ដឹកនាំ សម្របសម្រួល សហការជាមួយនឹងអង្គភាពនានា ដែលបំពេញភារកិច្ចក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ ចំពោះកិច្ចការពារបេតិកភណ្ឌ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព និងការផ្តល់សេវាកម្មទេសចរណ៍នៅក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ និងតំបន់ពាក់ព័ន្ធផ្សេងទៀត។

## ជំពូកទី២
## រចនាសម្ព័ន្ធ

**មាត្រា៥ .-**

អង្គភាព ប្រតិបត្តិរបស់ **អ.ជ.ព.វ.** មានរចនាសម្ព័ន្ធដូចតទៅ៖

១- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច

២- នាយកដ្ឋានអភិរក្ស និងបុរាណវិទ្យា

៣- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍

៤- នាយកដ្ឋានគ្រប់គ្រងដីធ្លី នគរូបនីយកម្ម និងអភិវឌ្ឍន៍សហគមន៍

៥- នាយកដ្ឋានបរិស្ថាន ព្រៃឈើ និងទឹក

៦- នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងតម្កល់ឯកសារ

៧- នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ

**អ.ជ.ព.ឲ.** មានអង្គភាពសវនកម្មផ្ទៃក្នុងមួយ ជាសេនាធិការលើកិច្ចការសវនកម្ម។

**អ.ជ.ព.ឲ.** មានគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ជាសេនាធិការលើការងារលទ្ធកម្មសាធារណៈ និងគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ជាសេនាធិការលើការងារបញ្ជីសារពើភណ្ឌ ដែលត្រូវបង្កើតអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អង្គការលេខរបស់ **អ.ជ.ព.ឲ.** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦ .-**

**អ.ជ.ព.ឲ.** ដឹកនាំដោយអគ្គនាយក ១ (មួយ)រូប និងមានអគ្គនាយករងជាជំនួយការ ចំនួនច្រើនបំផុត ៥ (ប្រាំ)រូប។

នាយកដ្ឋាននីមួយៗ ដឹកនាំដោយប្រធាន ១ (មួយ)រូប និងមានអនុប្រធានជាជំនួយការ ចំនួនច្រើនបំផុត ៥ (ប្រាំ)រូប។

នាយកដ្ឋាននីមួយៗ មានការិយាល័យមួយចំនួនជាសេនាធិការ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យនៃនាយកដ្ឋានចំណុះ **អ.ជ.ព.ឲ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

ប្រធាននាយកដ្ឋាន ត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

អនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យចុះក្រោមត្រូវបានតែងតាំង និងបញ្ចប់ពីមុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈតាមសំណើរបស់អគ្គនាយក **អ.ជ.ព.ឲ.** តាមការឯកភាពរបស់ក្រុមប្រឹក្សាភិបាល។

## ជំពូកទី៣
## នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច

**មាត្រា៧ .-**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញកិច្ច មានមុខងារនិងភារកិច្ចដូចតទៅ៖

- គ្រប់គ្រងការងាររបៀបរួមមាន ការងារទទួលលិខិតចូល ការងារគ្រប់គ្រងចរាចរណ៍លិខិតផ្ទៃក្នុង ការតម្កល់ឯកសារ និងការបែងចែកលិខិតចេញ
- គ្រប់គ្រងលិខិតរដ្ឋបាលរួមមាន ការរៀបចំលិខិតឆ្លើយតបនិងលិខិតអនុញ្ញាតផ្សេងៗ ស្របទៅតាមបទដ្ឋានរដ្ឋបាល និងពិនិត្យអំពីអនុលោមភាពនៃបទដ្ឋានរដ្ឋបាលរបស់លិខិតឬអត្ថបទទាំងឡាយរបស់អាជ្ញាធរជាតិព្រះវិហារមុននឹងផ្ញើចេញទៅបណ្តានាយកដ្ឋានពាក់ព័ន្ធនិងស្ថាប័នខាងក្រៅ
- សិក្សានិងរៀបចំលក្ខខណ្ឌរដ្ឋបាលនិងស្ថាប័ន ដើម្បីជានាការគ្រប់គ្រងត្រាដែលស្ថិតក្រោមការចាត់ចែងផ្ទាល់របស់អគ្គនាយក **អ.ជ.ព.ឲ.** ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងស្របតាមបទដ្ឋានជាធរមានសម្រាប់អំណាចសាធារណៈ
- គ្រប់គ្រងមជ្ឈមណ្ឌលសេវាកម្ម និងសម្របសម្រួលការផ្តល់សេវាកម្មនានារបស់ **អ.ជ.ព.ឲ.**
- គ្រប់គ្រងនិងចាត់ចែងការងារពិធីការ សណ្តាប់ធ្នាប់ និងសន្តិសុខនៅទីស្នាក់ការ **អ.ជ.ព.ឲ.**

- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធរៀបចំប្រជុំជាតិនិងអន្តរជាតិ សិក្ខាសាលា ពិធីសម្ពោធ ពិធីបុណ្យផ្លូវការ និងពិធីផ្សេងៗរបស់ **អ.ជ.ព.វ**.
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធនានា រៀបចំផែនការមេសម្រាប់កិច្ចការអភិរក្សនិងអភិវឌ្ឍន៍ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- គ្រប់គ្រងសំណុំបែបបទ និងនីតិវិធីរដ្ឋបាលដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងមន្ត្រីរាជការ និងបុគ្គលិករបស់ **អ.ជ.ព.វ**.
- រៀបចំកំណត់តំណែងឯកទេស មុខតំណែង ការងារ តួនាទី និងភារកិច្ចរបស់មន្ត្រីរាជការ និងបុគ្គលិក និងការបែងចែកធនធានមនុស្ស
- រៀបចំនិងគ្រប់គ្រងស្ថិតិលើការគ្រប់គ្រងមន្ត្រីរាជការនិងបុគ្គលិក ស្របតាមនីតិវិធីរដ្ឋបាលរបស់ **អ.ជ.ព.វ**.
- រៀបចំការជ្រើសរើសបុគ្គលិកទៅតាមផែនការនិងនីតិវិធី រៀបចំតារាងប្រាក់បៀវត្សរ៍ ប្រាក់ឧបត្ថម្ភ និងប្រាក់កម្រៃផ្សេងៗរបស់មន្ត្រីរាជការ និងបុគ្គលិក
- ទទួលរៀបចំការងារពិធីការនិងមគ្គុទ្ទេសក៍ទេសចរណ៍ សម្រាប់បម្រើដល់គណៈប្រតិភូជាតិ និងអន្តរជាតិ ដែលអញ្ជើញមកទស្សនានៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- គ្រប់គ្រងការប្រើប្រាស់ប្រេងឥន្ធនៈ សម្ភារៈ បរិក្ខា រថយន្ត និងគ្រឿងចក្រគ្រប់ប្រភេទ
- គ្រប់គ្រង ថែទាំ និងជួសជុលរថយន្ត គ្រឿងចក្រ និងអគារក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- ទំនាក់ទំនងនិងសហការជាមួយសមាជិកក្រុមប្រឹក្សាភិបាលរបស់ **អ.ជ.ព.វ**. ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ អន្តរជាតិ និងសមត្ថកិច្ចរបស់សាមីនាយកដ្ឋាននីមួយៗ
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ គម្រោងថវិកាអភិរក្ស និងអភិវឌ្ឍន៍នានា ឬគម្រោងស្នើសុំថវិកាសម្រាប់កិច្ចអន្តរាគមន៍បន្ទាន់ ដោយសហការជាមួយនាយកដ្ឋានជំនាញ និងក្រុមការងារពាក់ព័ន្ធ
- តាមដាននិងត្រួតពិនិត្យប្រាក់ចំណូលគ្រប់ប្រភេទរបស់ **អ.ជ.ព.វ**.
- តាមដាននិងពិនិត្យចំនួនទឹកប្រាក់និងរតនភ័ណ្ឌដែលមានផ្ញើនៅធនាគារ
- អនុវត្តការបើកប្រាក់ឧបត្ថម្ភឬប្រាក់បំណាច់ផ្សេងៗជូនមន្ត្រីរាជការនិងបុគ្គលិកគ្រប់ប្រភេទ
- កាន់កាប់បញ្ជីគណនេយ្យទូទៅរបស់ **អ.ជ.ព.វ**. និងបញ្ជីគណនេយ្យនៃប្រតិបត្តិការហិរញ្ញវត្ថុផ្សេងៗឱ្យមានតម្លាភាព និងគណនេយ្យភាពដោយតម្កល់ទុកនូវឯកសារដើមបញ្ជាក់ពីចំណូលនិងចំណាយ
- គ្រប់គ្រងទ្រព្យសម្ភារៈគ្រប់ប្រភេទ ដែលពាក់ព័ន្ធនឹងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- រៀបចំរបបបេសកកម្មក្នុងនិងក្រៅប្រទេសជូនមន្ត្រីរាជការ បុគ្គលិករបស់ **អ.ជ.ព.វ**.
- ចូលរួមអនុវត្តគ្រប់ការងារលទ្ធកម្មស្របតាមច្បាប់ជាធរមាន
- គ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យា និងគេហទំព័រផ្លូវការរបស់ **អ.ជ.ព.វ**.

- ផ្តល់សេវាគាំទ្រផ្នែកព័ត៌មានវិទ្យា (Software និង Hardware) ដល់នាយកដ្ឋានបច្ចេកទេសនៃ **អ.ជ.ព.វ.**
- គ្រប់គ្រង ផលិតព័ត៌មាន និងត្រួតពិនិត្យការចុះផ្សាយ
- តាមដាន ត្រួតពិនិត្យការចុះផ្សាយពាក់ព័ន្ធរមណីយដ្ឋានស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារ និងធ្វើការឆ្លើយតប
- ស្វែងរកបច្ចេកវិទ្យាថ្មីៗទាក់ទងនឹងព័ត៌មានវិទ្យា
- ជាសេនាធិការអគ្គនាយក **អ.ជ.ព.វ.** ក្នុងការគ្រប់គ្រងការប្រមូលចំណូល និងទូទាត់ចំណាយរបស់ **អ.ជ.ព.វ.**
- ជាសេនាធិការអគ្គនាយក **អ.ជ.ព.វ.** ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ **អ.ជ.ព.វ.** ស្របតាមគោលនយោបាយយុទ្ធសាស្ត្រដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានកំណត់ និងផែនការសកម្មភាពរបស់ **អ.ជ.ព.វ.** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល
- ជាសេនាធិការអគ្គនាយក **អ.ជ.ព.វ.** ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់ **អ.ជ.ព.វ.**
- ធ្វើទំនាក់ទំនងជាមួយក្រសួងអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិការបស់ **អ.ជ.ព.វ.** តាមរយៈអគ្គនាយក **អ.ជ.ព.វ.**
- ជាសេនាធិការអគ្គនាយក **អ.ជ.ព.វ.** ក្នុងការគ្រប់គ្រង និងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- តាមដានលទ្ធផលនៃការអនុវត្តថវិកា
- សម្របសម្រួលក្នុងនាមជាសេនាធិការ របស់អគ្គនាយក **អ.ជ.ព.វ.** សម្រាប់ការតាមដាន ត្រួតពិនិត្យ ការធ្វើអធិការកិច្ច និងសវនកម្ម
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដារគណនេយ្យ របាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយ) និងរបាយការណ៍សមិទ្ធកម្មរបស់ **អ.ជ.ព.វ.** ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ជូនប្រធានក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ អនុម័ត រួចផ្ញើជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយក **អ.ជ.ព.វ.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក **អ.ជ.ព.វ.**។

## ជំពូកទី៤
## នាយកដ្ឋានអភិរក្សនិងបុរាណវិទ្យា

**មាត្រា៩ .-**

នាយកដ្ឋានអភិរក្សនិងបុរាណវិទ្យា មានមុខងារនិងភារកិច្ចដូចតទៅ៖

- កំណត់ទិសដៅនិងរៀបចំផែនការមេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ស្តីពីការគ្រប់គ្រង អភិរក្ស និងថែទាំប្រាសាទក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការអភិរក្សប្រាសាទនិងកិច្ចការបុរាណវិទ្យា
- រៀបចំឯកសារស្តីពីស្ថានភាពប្រាសាទ ផែនទីហានិភ័យប្រាសាទ និងរបាយការណ៍ស្តីពីស្ថានភាពនៃការអភិរក្ស
- សិក្សានិងសម្រង់ប្លង់បច្ចេកទេសរបស់ប្រាសាទនានា
- រៀបចំចុះបញ្ជីស្ថានីយបុរាណវិទ្យានិងវត្ថុសិល្បៈតាមប្រាសាទនិងគ្រប់គ្រងសមុច្ច័យបុរាណប្រាសាទ ព្រមទាំងរចនាសម្ព័ន្ធបុរាណនានាក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- រៀបចំកម្មវិធីនិងអនុវត្តការងារអភិរក្សប្រាសាទនិងរចនាសម្ព័ន្ធបុរាណនានាក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- បង្កើតក្រុមចល័តដែលមានសមត្ថភាពនិងឧបករណ៍សម្ភារៈសមស្របដើម្បីរៀបចំថែទាំនិងតាមដានផ្នែកបុរាណវិទ្យានិងការគ្រប់គ្រងរមណីយដ្ឋាន
- រៀបចំ គ្រប់គ្រង និងដឹកនាំផ្នាំប្រាសាទនិងពលករជំនាញនានា
- ពិនិត្យនិងផ្តល់យោបល់បច្ចេកទេសផ្នែកបុរាណវិទ្យា លើគម្រោងអភិរក្សនិងគម្រោងអភិវឌ្ឍន៍នានា ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- រៀបចំផែនការ ការស្ទង់ពិនិត្យមើល និងកំណាយបុរាណវិទ្យា ព្រមទាំងចាត់វិធានការសម្រាប់បង្ការឬសង្គ្រោះតាមការចាំបាច់
- យកចិត្តទុកដាក់ជាប្រចាំក្នុងកិច្ចការពារ ថែទាំ ទល់ទ្រ យាមកាមប្រាសាទនានាក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- រៀបចំនិងអនុវត្តរាល់កម្មវិធីស្រាវជ្រាវលើវិស័យបុរាណវិទ្យានិងការងារអភិរក្សប្រាសាទនិងវត្ថុបុរាណ
- ធ្វើការតាមដាន ត្រួតពិនិត្យ និងសម្របសម្រួលការដ្ឋានជាតិនិងអន្តរជាតិពាក់ព័ន្ធនឹងការងារអភិរក្សនិងបុរាណវិទ្យា
- ប្រមូល ចងក្រងឯកសារ នូវលទ្ធផលកិច្ចការអភិរក្សនិងស្រាវជ្រាវបុរាណវិទ្យា
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាសប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយក **អ.ជ.ព.វ.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក **អ.ជ.ព.វ.**។

## ជំពូកទី៥
## នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍

**មាត្រា៩ .-**

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ មានមុខងារនិងភារកិច្ចដូចតទៅ៖

- កំណត់ទិសដៅនិងរៀបចំផែនការអភិវឌ្ឍន៍ទេសចរណ៍សម្រាប់រយៈពេលខ្លី មធ្យម និងវែងនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.** ដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ ស្របទៅនឹងគោលនយោបាយទេសចរណ៍របស់រាជរដ្ឋាភិបាល
- រៀបចំកម្មវិធីអនុវត្តផែនការគ្រប់គ្រងទេសចរណ៍ ដោយសហការជាមួយដៃគូពាក់ព័ន្ធជាតិនិងអន្តរជាតិ
- ប្រមូល កសាងប្រព័ន្ធទិន្នន័យ វិភាគស្ថិតិភ្ញៀវទេសចរ និងសិក្សាអំពីភ្ញៀវទេសចរដើម្បីអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព
- សិក្សាបង្កើតគោលដៅទេសចរណ៍ និងផលិតផលទេសចរណ៍ថ្មីៗ
- សិក្សា រៀបចំទីលានចំណតមុខប្រាសាទ "ប៉ារីស" មណ្ឌលបដិសណ្ឋារកិច្ច មណ្ឌលព័ត៌មានសម្ភារបរិក្ខាសម្រាប់សម្រួលដល់ការទស្សនានិងជានាសុវត្ថិភាពដល់ភ្ញៀវទេសចរ ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ
- សិក្សារៀបចំប្លង់ទស្សនាចររបស់ភ្ញៀវទេសចរនៅតាមប្រាសាទដើម្បីបង្កើនការយល់ដឹងអំពីគុណតម្លៃរបស់ប្រាសាទ ជានាសុវត្ថិភាព និងកាត់បន្ថយផលប៉ះពាល់ដោយផ្ទាល់របស់ភ្ញៀវទេសចរទៅលើប្រាសាទ
- រៀបចំនិងកំណត់ទីតាំងដាក់ស្លាកសញ្ញាចរាចរ ស្លាកសញ្ញាព័ត៌មានទេសចរណ៍ និងស្លាកសញ្ញាផ្សេងៗទៀតដែលចាំបាច់ រៀបចំចំណតរថយន្ត មធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចរ កំណត់តូបស្តង់លក់ដូរវត្ថុអនុស្សាវរីយ៍និងភេសជ្ជៈ បង្គន់អនាម័យ និងបន្ទប់ទឹកជាដើម ដើម្បីជានាឱ្យមានសោភណ្ឌភាពល្អក្នុងតំបន់រមណីយដ្ឋានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.** ដោយសហការ ជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ
- សិក្សានិងរៀបចំបទប្បញ្ញត្តិនិងវិធានការពាក់ព័ន្ធក្នុងការផ្តល់សេវាកម្មនិងសកម្មភាពនានា ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.** និងតាមដានការអនុវត្តបទប្បញ្ញត្តិ និងវិធានការទាំងនោះ
- រៀបចំនិងគ្រប់គ្រងការផ្តល់សេវាកម្មទេសចរណ៍នៅតាមប្រាសាទនានា ពិសេសដើម្បីជានាគុណភាពនិងមានចំណូលខ្ពស់ពីព្រឹត្តិការណ៍ វប្បធម៌ សិល្បៈ មហោស្រព និងពិធីនានា ដែលប្រារព្ធធ្វើក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.** ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ
- យកចិត្តទុកដាក់ការពាររូបភាពនៃប្រាសាទព្រះវិហារ និងប្រាសាទនានាក្នុងរមណីយដ្ឋានប្រាសាទកោះកេរ ដោយចូលរួមតាមដានឱ្យបានហ្មត់ចត់លើសកម្មភាពថតរូប ថតវីដេអូ ដ្រូន និងភាពយន្ត
- សហការជាមួយនាយកដ្ឋានជំនាញនិងស្ថាប័នជំនាញពាក់ព័ន្ធរៀបចំបណ្តុះបណ្តាលមគ្គុទេសក៍ទេសចរ
- ពិនិត្យ ផ្តល់យោបល់ និងរៀបចំកិច្ចសន្យាសម្រាប់គម្រោងវិនិយោគ និងអាជីវកម្មទេសចរណ៍ និងរៀបចំលិខិតអនុញ្ញាតចេញ-ចូល ការរៀបចំព្រឹត្តិការណ៍និងសកម្មភាពនានាពាក់ព័ន្ធនឹងការលើកតម្លៃបេតិកភណ្ឌវប្បធម៌

- ចូលរួមផ្សព្វផ្សាយពីវិស័យទេសចរណ៍តាមរយៈការរៀបចំ និងចូលរួមពិព័រណ៍ថ្នាក់ជាតិនិងអន្តរជាតិ និងធ្វើទីផ្សារផលិតផលទេសចរណ៍ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- យកចិត្តទុកដាក់ស្វែងរកដៃគូជាតិ និងដៃគូអន្តរជាតិដើម្បីសហការពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព
- យកចិត្តទុកដាក់ក្នុងការជម្រុញបង្កើតការងារជូនប្រជាពលរដ្ឋក្នុងតំបន់ ដើម្បីចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនិងលើកកម្ពស់ការថែរក្សាបេតិកភណ្ឌ
- រៀបចំបទដ្ឋានសម្រាប់គ្រប់គ្រងបេតិកភណ្ឌវប្បធម៌ និងស្តង់ដារស្តីពីបេតិកភណ្ឌវប្បធម៌ ព្រឹត្តិការណ៍ ឬសកម្មភាពនានា ដែលអនុវត្តនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ដើម្បីលើកកម្ពស់គុណតម្លៃបេតិកភណ្ឌវប្បធម៌និងបង្កើតចំណូលថវិកាជាតិ
- រៀបចំវង់ទស្សនាតាមប្រាសាទ និងក្នុងរមណីយដ្ឋានក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ដើម្បីពង្រឹងគុណភាពសេវាកម្មទេសចរណ៍ ដោយសហការជាមួយស្ថាប័ន/អង្គភាព និងនាយកដ្ឋានពាក់ព័ន្ធ
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយក **អ.ជ.ព.វ.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក**អ.ជ.ព.វ.**។

## ជំពូកទី៦
## នាយកដ្ឋានគ្រប់គ្រងដីធ្លី នគរូបនីយកម្ម និងអភិវឌ្ឍន៍សហគមន៍

**មាត្រា១០ .-**

នាយកដ្ឋានគ្រប់គ្រងដីធ្លី នគរូបនីយកម្ម និងអភិវឌ្ឍសហគមន៍ មានមុខងារនិងភារកិច្ចដូចតទៅ៖

- កំណត់ទិសដៅ និងរៀបចំផែនការមេសម្រាប់រយៈពេលខ្លី មធ្យម និងវែងស្របតាមគោលនយោបាយ របស់រាជរដ្ឋាភិបាលស្តីពីការគ្រប់គ្រងដីធ្លី និងលំនៅឋាន ស្របតាមកិច្ចការពារទេសភាពវប្បធម៌នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- សិក្សា រៀបចំ និងគ្រប់គ្រងប្រព័ន្ធទិន្នន័យដីធ្លី លំនៅឋាន សំណង់ និងប្រជាសាស្ត្រក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ដោយសហការជាមួយស្ថាប័ន/អង្គភាពពាក់ព័ន្ធ
- សិក្សានិងរៀបចំបទប្បញ្ញត្តិនិងវិធានពាក់ព័ន្ធក្នុងការគ្រប់គ្រងដីធ្លី លំនៅឋាន និងសំណង់ ព្រមទាំងតាមដានការអនុវត្តបទប្បញ្ញត្តិនិងវិធានទាំងនោះ
- សិក្សា អង្កេត និងវាស់វែងដីធ្លីគ្រប់ប្រភេទនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ដោយសហការជាមួយស្ថាប័ន/អង្គភាពនិងអាជ្ញាធរដែនដីពាក់ព័ន្ធ
- កំណត់រាល់តំបន់ដែលត្រូវធ្វើការរៀបចំដើម្បីបម្រើផលប្រយោជន៍សាធារណៈស្របតាមបទដ្ឋាននៃអភិរក្ស និងការអភិវឌ្ឍន៍នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**

- ចូលរួមដោះស្រាយផលប៉ះពាល់ក្នុងគម្រោងអភិរក្សនិងអភិវឌ្ឍផ្សេងៗដោយសហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ
- ពិនិត្យសំណើស្នើសុំសាងសង់ និងរៀបចំលិខិតអនុញ្ញាតសាងសង់ស្របទៅតាមបទប្បញ្ញត្តិជាធរមាន ព្រមទាំងតាមដាន និងត្រួតពិនិត្យការសាងសង់ទាំងនោះ
- រៀបចំឱ្យមានក្រុមអង្កេតប្រជាសាស្ត្រដើម្បីតាមដានការប្រែប្រួលនៃកំណើន និងកម្រិតជីវភាពរស់នៅនិងការប្រែប្រួលទីលំនៅរបស់ប្រជាពលរដ្ឋ ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.**
- គិតគូរនិងលើកផែនការអភិវឌ្ឍសហគមន៍ប្រកបដោយនិរន្តរភាព តុល្យភាព និងសមាហរណភាពក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.**
- ជម្រុញឱ្យមានការលើកកម្ពស់វិស័យអប់រំ កសិកម្ម និងមុខរបររបស់ប្រជាជន
- រៀបចំការអនុវត្តគម្រោងលើកកម្ពស់ជីវភាពប្រជាជនក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.** ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្ថាប័នជាតិ និងអន្តរជាតិ
- ចូលរួមសហការពិនិត្យនិងផ្តល់យោបល់លើសំណើរបស់សហគមន៍ក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.**
- រៀបចំគំរូស្ថាបត្យកម្មខ្មែរបុរាណគ្រប់ប្រភេទដើម្បីផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.**
- ពិនិត្យ និងផ្តល់យោបល់ស្តីពីកិច្ចការពារបេតិកភណ្ឌក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.** ជាពិសេសវត្តអារាមដែលមានលក្ខណៈប្រវត្តិសាស្ត្រ លំនៅឋានប្រពៃណី និងអគារស្ថាបត្យកម្មដែលមានតម្លៃបេតិកភណ្ឌតាមការស្នើសុំរបស់អាជ្ញាធរមានសមត្ថកិច្ច
- សិក្សានិងរៀបចំឯកសារស្តីពីវិធានការពាក់ព័ន្ធនឹងការងារនគរូបនីយកម្ម សម្រាប់រក្សាតុល្យភាពរវាងការអភិវឌ្ឍ និងការអភិរក្សបេតិកភណ្ឌវប្បធម៌និងបរិស្ថាន
- អភិរក្សនិងលើកតម្លៃទេសភាពវប្បធម៌ដោយភ្ជាប់ជាមួយប្រពៃណីប្រវត្តិសាស្ត្រខ្មែរនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.**
- សិក្សាស្រាវជ្រាវសំណង់បែបប្រវត្តិសាស្ត្រនិងលក្ខណៈបុរាណដើម្បីចងក្រងនិងបោះពុម្ពផ្សព្វផ្សាយ
- សហការជាមួយក្រសួង ស្ថាប័ន និងនាយកដ្ឋានពាក់ព័ន្ធក្នុងការកសាង ស្តារជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្តនានាក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.**
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយក **អ.ជ.ព.ទ.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក **អ.ជ.ព.ទ.**។

## ជំពូកទី៧
## នាយកដ្ឋានបរិស្ថាន ព្រៃឈើ និងទឹក

**មាត្រា១១ .-**

នាយកដ្ឋានបរិស្ថាន ព្រៃឈើ និងទឹក មានមុខងារនិងភារកិច្ចដូចតទៅ ៖

- កំណត់ទិសដៅ និងរៀបចំផែនការមេសម្រាប់រយៈពេលខ្លី មធ្យម និងវែង ស្តីពីការគ្រប់គ្រងបរិស្ថាន ព្រៃឈើ និងទឹក ព្រមទាំងសំណង់ជាវាសាស្ត្រនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- ចូលរួមអនុវត្តសកម្មភាពដែលមានលក្ខណៈពហុវិស័យនៅក្នុងគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាព
- សិក្សាអំពីរុក្ខជាតិ សត្វ និងប្រព័ន្ធអេកូឡូស៊ីនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- គ្រប់គ្រងព្រៃឈើនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** រួមមានការអភិរក្ស ការថែទាំ និងការដាំកូនឈើឡើងវិញ
- ស្រាវជ្រាវនិងជួសជុលឡើងវិញនូវប្រព័ន្ធជាវាសាស្ត្របុរាណ
- បង្កើតប្រព័ន្ធតាមដានបម្រែបម្រួលទឹកនៅលើដីនិងនៅក្រោមដី
- ស្រាវជ្រាវរកដំណោះស្រាយផ្សេងៗដើម្បីចាត់ចែងប្រើប្រាស់ទឹកនៅលើដីក្នុងគោលដៅជួយកាត់បន្ថយការប្រើប្រាស់ទឹកនៅក្រោមដី
- សិក្សាអំពីបរិស្ថាន បរិយាកាស និងអាកាសធាតុ ដោយរៀបចំឱ្យមានប្រព័ន្ធស្ថានីយឧតុនិយមសម្រាប់ប្រមូលទិន្នន័យ តាមដានបម្រែបម្រួលអាកាសធាតុ ឥទ្ធិពលដែលមានលើជលសាស្ត្រ និងកសិកម្ម និងការបំពុលបរិស្ថាន ការបំពុលទឹក ការបំពុលខ្យល់ ព្រមទាំងការរំខានដោយសំឡេង
- រៀបចំនិងគ្រប់គ្រងបញ្ជីសារពើភណ្ឌព្រៃឈើនិងដីព្រៃ ព្រមទាំងកំណត់ហានិភ័យដើមឈើ
- រៀបចំថ្នាលបណ្ដុះកូនឈើសម្រាប់ការដាំដុះនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់**អ.ជ.ព.វ.**
- ការពារជីវចម្រុះ អភិរក្សសត្វ និងរុក្ខជាតិនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- រៀបចំ គ្រប់គ្រង និងដឹកនាំក្រុមបរិស្ថាននុរក្ស និងពលករជំនាញ
- សហការជាមួយស្ថាប័នជំនាញសិក្សា កំណត់ រៀបចំបង្កើត និងគ្រប់គ្រងតំបន់អេកូទេសចរណ៍
- រៀបចំកម្មវិធីផ្សព្វផ្សាយអំពីបរិស្ថាន សារៈសំខាន់ព្រៃឈើ និងសត្វព្រៃ
- ចាត់វិធានការនានាក្នុងការទប់ស្កាត់រាល់បទល្មើសព្រៃឈើនិងការរានដីព្រៃ
- រៀបចំឯកសារពាក់ព័ន្ធនឹងបទល្មើសព្រៃឈើនិងធនធានធម្មជាតិដោយសហការជាមួយស្ថាប័នអង្គភាពពាក់ព័ន្ធ
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយក **អ.ជ.ព.វ.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក **អ.ជ.ព.វ.**។

## ជំពូកទី៨
## នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងតម្កល់ឯកសារ

**មាត្រា១២ .-**

នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងតម្កល់ឯកសារ មានមុខងារនិងភារកិច្ចដូចតទៅ៖

- រៀបចំផែនការស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ របស់អាជ្ញាធរជាតិព្រះវិហារ សម្រាប់រយៈពេលខ្លី មធ្យម និងវែង ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ និងដៃគូជាតិ និងអន្តរជាតិ
- រៀបចំកម្មវិធីយុទ្ធសាស្ត្រសម្រាប់ការស្រាវជ្រាវប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សង្គម និងប្រជាសាស្ត្រ ដែលទាក់ទងនឹងបេតិកភណ្ឌរូបី និងអរូបី ព្រមទាំងវិស័យផ្សេងៗទៀតពាក់ព័ន្ធនឹងការងារក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.**
- រៀបចំកម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា លើការងារអភិរក្សបេតិកភណ្ឌ និងការអភិវឌ្ឍប្រកបដោយចីរភាព និងការអភិវឌ្ឍធនធានមនុស្សដោយសហការជាមួយនាយកដ្ឋាននានា ស្ថាប័នជាតិ និងអន្តរជាតិ
- តាមដាននិងចាត់វិធានការណ៍លើរាល់លទ្ធផលស្រាវជ្រាវដែលត្រូវបានបោះពុម្ពនិងផ្សព្វផ្សាយជាសាធារណៈដែលពុំមានការអនុញ្ញាតពី **អ.ជ.ព.វ.**
- គ្រប់គ្រងសារមន្ទីរ អភិរក្សដ្ឋាន បណ្ណាល័យ និងមណ្ឌលតម្កល់ឯកសាររបស់ **អ.ជ.ព.វ.**
- បង្កើតប្រព័ន្ធទិន្នន័យដើម្បីចុះបញ្ជីលទ្ធផលស្រាវជ្រាវរបស់ **អ.ជ.ព.វ.** និងរបស់ស្ថាប័នជាតិនិងអន្តរជាតិ
- រៀបចំគ្រប់គ្រងប័ណ្ណចេញ-ចូល តំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ.** ដោយឥតគិតថ្លៃសម្រាប់អ្នកស្រាវជ្រាវអន្តរជាតិ
- សិក្សាចងក្រងនិងផ្សព្វផ្សាយគ្រប់ឯកសារគតិយុត្ត និងវិធាននានាទាក់ទងនឹងកម្មសិទ្ធិបញ្ញាអនុសញ្ញាពាក់ព័ន្ធនឹងបេតិកភណ្ឌរូបី និងអរូបី ព្រមទាំងក្រឹត្យក្រមបទដ្ឋានរបស់អង្គការយូណេស្កូ
- រៀបចំអនុស្សារណៈយោគយល់ កិច្ចព្រមព្រៀង និងឯកសារស្តីពីកិច្ចសហប្រតិបត្តិការរវាង **អ.ជ.ព.វ.** និងដៃគូជាតិ និងអន្តរជាតិ លើវិស័យស្រាវជ្រាវ អភិរក្ស អភិវឌ្ឍន៍នានា ដោយសហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធ
- រៀបចំឱ្យមានកម្លាំងសន្តិសុខ ពលករ និងពលករជំនាញ ដើម្បីថែទាំ ជួសជុល ការពារ សារមន្ទីរ អភិរក្សដ្ឋាន បណ្ណាល័យ និងមណ្ឌលតម្កល់ឯកសារ
- សហការជាមួយនាយកដ្ឋានជំនាញ និងស្ថាប័នពាក់ព័ន្ធក្នុងការប្រមូលវត្ថុសិល្បៈយកមករក្សាទុក ថែទាំ ជួសជុល និងចុះបញ្ជីសារពើភណ្ឌរាល់សមុច្ច័យនៅក្នុងសារមន្ទីរ និងអភិរក្សដ្ឋាន
- លើកគម្រោងរៀបចំយុទ្ធនាការឃោសនា និងផ្សព្វផ្សាយ ដល់សិស្សានុសិស្ស ប្រជាពលរដ្ឋ ដើម្បីបំផុសស្មារតីយល់ដឹងអំពីតម្លៃបេតិកភណ្ឌនិងរមណីយដ្ឋាន

- ចូលរួមសហការស្រាវជ្រាវក្នុងគម្រោងស្រាវជ្រាវជាតិនិងអន្តរជាតិក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- ចងក្រង ផ្សព្វផ្សាយ និងពង្រឹងការអនុវត្តក្រមប្រតិបត្តិសម្រាប់អ្នកស្រាវជ្រាវ
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយក **អ.ជ.ព.វ**.
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក **អ.ជ.ព.វ**.។

## ជំពូកទី៩
## នាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការ

**មាត្រា១៣ .-**

នាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការ មានមុខងារនិងភារកិច្ចដូចតទៅ៖

- ការពារនិងថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- ទប់ស្កាត់រាល់សកម្មភាពខុសច្បាប់និងគ្មានការអនុញ្ញាត ដែលធ្វើឱ្យប៉ះពាល់ដល់តម្លៃបេតិកភណ្ឌបុរាណវិទ្យា វប្បធម៌ អារ្យធម៌ ទំនៀមទំលាប់ ប្រពៃណី ជំនឿ សាសនា ទេសភាពវប្បធម៌ ការស្រាវជ្រាវសកម្មភាពខុសច្បាប់ សណ្តាប់ធ្នាប់ អនាម័យ ការជីកកកាយ ការលុបដី ការរៀបចំព្រឹត្តការណ៍ និងពិធីផ្សេងៗនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- សហការជាមួយនាយកដ្ឋានជំនាញ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ នគរបាល កងរាជអាវុធហត្ថ និងមន្ត្រីមានសមត្ថកិច្ចពាក់ព័ន្ធ ទប់ស្កាត់បទល្មើសព្រៃឈើ ការទន្ទ្រានយកដី ការសាងសង់សំណង់ខុសច្បាប់ និងគ្មានការអនុញ្ញាតនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- សហការជាមួយនគរបាលបេតិកភណ្ឌដើម្បីទប់ស្កាត់និងបង្ក្រាបការគាស់កកាយ ការរុករក ការលួច និងការជួញដូរវត្ថុបុរាណ
- សហការជាមួយនឹងអង្គភាពនគរបាលទេសចរណ៍ដើម្បីរក្សាសណ្តាប់ធ្នាប់ និងសន្តិសុខជូនភ្ញៀវទេសចរ
- រៀបចំផែនការអន្តរាគមន៍ ល្បាត និងវិធានការណ៍ទប់ស្កាត់នៅតាមគោលដៅនានា ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់និងជាមួយបណ្តានាយកដ្ឋាននានារបស់ **អ.ជ.ព.វ**.
- សហការជាមួយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ដើម្បីប្រមូលនិងគ្រប់គ្រងទិន្នន័យមីន និងអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.វ**.
- រៀបចំ គ្រប់គ្រង និងដឹកនាំកម្លាំងសន្តិសុខអភិរក្ស

- សិក្សានិងលើកផែនការដើម្បីបោសសំអាតអាវុធយុទ្ធភណ្ឌមិនទាន់ផ្ទុះនៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់ **អ.ជ.ព.ទ.**
- ធ្វើរបាយការណ៍សរុប ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ប្រចាំឆ្នាំ និងរបាយការណ៍ស្តីពីសភាពការណ៍ចាំបាច់បន្ទាន់ពាក់ព័ន្ធនឹងការងាររបស់ខ្លួនជូនអគ្គនាយក **អ.ជ.ព.ទ.**
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់អគ្គនាយក **អ.ជ.ព.ទ.**។

## ជំពូកទី១០
## អង្គភាពសវនកម្មផ្ទៃក្នុង

**មាត្រា១៤ .-**

អង្គភាពសវនកម្មផ្ទៃក្នុង ត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល។

អង្គភាពសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ និងអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១១
## អន្តរប្បញ្ញត្តិ

**មាត្រា១៥ .-**

លិខិតបទដ្ឋានគតិយុត្ត និងមន្ត្រីរាជការក្របខណ្ឌមុខងារសាធារណៈ បុគ្គលិកអចិន្ត្រៃយ៍ និងបុគ្គលិកកិច្ចសន្យាក្នុងមុខតំណែងបច្ចុប្បន្ន ត្រូវបានរក្សាទុកនូវភារកិច្ច មុខងារ និងតួនាទីរបស់ខ្លួនរហូតដល់មានលិខិតបទដ្ឋានគតិយុត្ត និងការតែងតាំងឬប្រគល់ភារកិច្ចថ្មីមកជំនួស។

## ជំពូកទី១២
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៦ .-**

ចំពោះបុព្វសិទ្ធិ និងសមត្ថកិច្ចរបស់ **អ.ជ.ព.ទ.** ដែលពាក់ព័ន្ធ ឬដែលអាចពាក់ព័ន្ធជាមួយបុព្វសិទ្ធិ និងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នផ្សេងៗទៀត រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនោះ ត្រូវសហការកំណត់ដោយប្រកាសអន្តរក្រសួង។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរជាតិ ដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិប្រាសាទព្រះវិហារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៩ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

បណ្ឌិតសភាចារ្យ **ភឿង សកុណា**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២៧០ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិព្រះវិហារ**



# ព្រះរាជក្រឹត្យស្តីពី
# ការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរឲ្យ
# ស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិ
# ដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌
# ធម្មជាតិនៃប្រាសាទព្រះវិហារ

# ព្រះរាជក្រឹត្យ

នស/រកត/០៤១៦/៤១៦

## ស្តីពី

## ការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកេរ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារនិងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨១១/៧៥២ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១

**មាត្រា១ .-**

ប្រគល់រមណីយដ្ឋានប្រាសាទកោះកេរ ដែលស្ថិតនៅក្នុងភូមិស្រយង់ ឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ។

**មាត្រា២ .-**

អាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទព្រះវិហារ មានសិទ្ធិធ្វើការកំណត់ ការចាត់ចែង ការការពារ ការត្រួតពិនិត្យ ការអភិរក្ស ការអភិវឌ្ឍន៍ និងការលើកតម្លៃបេតិកភណ្ឌវប្បធម៌ធម្មជាតិ ស្របតាមប្លង់កំណត់មួយដែលមានចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៤ ស្ដីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកេរ។

**មាត្រា៣ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៥/៣២៣ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៥ ស្ដីពីការប្រគល់រមណីយដ្ឋានប្រាសាទកោះកេរ ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរ "អប្សរា" និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤ .-**

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០១៦

នរស.១៦០៤.៤២៧

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ: ៤២៧ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

២

សយ សុខា

# ព្រះរាជក្រឹត្យស្តីពី
# ការកំណត់តំបន់រមណីយដ្ឋាន
# ប្រាសាទកោះកេរ

# ព្រះរាជក្រឹត្យ

នស/រកត/១១២០/១៤៥៥

## ស្តីពី

## ការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២០២/២០៤ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិព្រះវិហារជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរជារមណីយដ្ឋានការពារ ស្ថិតនៅក្នុងឃុំស្រយង់ ស្រុកគូលែន ខេត្តព្រះវិហារ ដើម្បីលើកកម្ពស់ការអភិរក្សកេរដំណែលបេតិកភណ្ឌវប្បធម៌ បុរាណវត្ថុវិទ្យា ជាតិពន្ធុវិទ្យា នរវិទ្យា ប្រវត្តិវិទ្យា និងលើកកម្រិតតម្លៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត អភិរក្សទេសភាពវប្បធម៌ អភិវឌ្ឍតំបន់ទេសចរណ៍ប្រកបដោយចីរភាព ព្រមទាំងការការពារបរិស្ថាន ធនធានធម្មជាតិ និងការអភិរក្សជីវៈចម្រុះក្នុងតំបន់តាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង។

## ជំពូកទី២

## ការកំណត់តំបន់

**មាត្រា២ .-**

តំបន់រមណីយដ្ឋានប្រាសាទកោះកេរមានទំហំសរុប ៨ ៧៨៩ហិកតា ៤៣អា (ប្រាំបីពាន់ប្រាំពីររយប៉ែតសិបប្រាំបួនហិកតាសែសិបបីអា) ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| ចំណុច | រយៈទទឹង | រយៈបណ្តោយ |
|---|---|---|
| B1 | 450253.337 | 1516487.188 |
| B2 | 450282.326 | 1516820.772 |
| B3 | 450371.073 | 1517148.194 |
| B4 | 450466.323 | 1517264.61 |
| B5 | 450894.945 | 1517616.504 |
| B6 | 450974.319 | 1517706.461 |
| B7 | 451066.923 | 1517899.606 |
| B8 | 451092.058 | 1518029.251 |
| B9 | 451096.027 | 1518198.584 |
| B10 | 450989.237 | 1518804.395 |
| C1 | 455103.168 | 1527804.144 |
| C2 | 455103.171 | 1518804.395 |
| C3 | 446102.94 | 1518804.394 |
| C4 | 446102.936 | 1527804.142 |
| C5 | 449785.737 | 1527804.143 |
| C6 | 449437.855 | 1528496.43 |
| C7 | 449539.727 | 1528687.091 |
| C8 | 449417.02 | 1528861.334 |
| C9 | 449198.406 | 1528728.471 |
| C10 | 448482.971 | 1529418.108 |
| C11 | 448476.182 | 1529471.828 |
| C12 | 448250.796 | 1529531.364 |
| C13 | 447871.253 | 1529250.494 |
| C14 | 447482.712 | 1529450.123 |
| C15 | 448179.229 | 1530111.384 |
| C16 | 448462.397 | 1529909.022 |

| | | |
|---|---|---|
| C17 | 448683.285 | 1529814.355 |
| C18 | 449223.179 | 1529728.18 |
| C19 | 449657.594 | 1529519.237 |
| C20 | 451115.562 | 1528707.149 |
| C21 | 452687.632 | 1528706.497 |
| C22 | 452685.515 | 1528193.469 |
| C23 | 451394.836 | 1528198.372 |
| C24 | 451397.743 | 1527804.143 |
| B42 | 452016.391 | 1518804.395 |
| B43 | 452141.125 | 1518005.44 |
| B44 | 451865.96 | 1517216.986 |
| B45 | 451651.649 | 1516955.05 |
| B46 | 451440.368 | 1516773.318 |
| B47 | 451273.298 | 1516629.614 |
| B48 | 451255.056 | 1516466.739 |

**មាត្រា៣ .-**

ការកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរតម្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់និងការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ។

**មាត្រា៤ .-**

មេណីយដ្ឋានប្រាសាទកោះកេរត្រូវបានចាត់ជា៣(បី)តំបន់គឺ តំបន់១ តំបន់២ និងតំបន់៣ ហើយត្រូវទទួលកម្រិតការពារនិងអភិវឌ្ឍក្នុងតំបន់ខុសៗគ្នា៖

ក- តំបន់១ ជាតំបន់ប្រាសាទនិងហេដ្ឋារចនាសម្ព័ន្ធបុរាណសំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហៅថាតំបន់ស្នូល ដែលត្រូវការពារកម្រិតខ្ពស់បំផុត។ តំបន់ស្នូលត្រូវបានកំណត់យកក្រុមប្រាសាទសំខាន់ៗមានជាអាទិ៍ប្រាសាទធំ ក្រុមប្រាសាទលិង្គ ប្រាសាទចិន ប្រាសាទប្រាំ និងរចនាសម្ព័ន្ធបុរាណមានជាអាទិ៍ រហាល កសិណ ស្រះបុរាណ ហេដ្ឋារចនាសម្ព័ន្ធជាពាសាស្រ្តបុរាណ។ តំបន់ស្នូលនេះមានផ្ទៃក្រឡា ១ ១៨៧ហិកតា ៦១អា (មួយពាន់មួយរយប៉ែតសិបប្រាំពីរហិកតាហុកសិបមួយអា) ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| ចំណុច | រយៈទទឹង | រយៈបណ្តោយ |
|---|---|---|
| A1 | 450430.146 | 1524926.665 |
| A2 | 451371.284 | 1524975.012 |
| A3 | 452938.255 | 1522661.703 |
| A4 | 452871.845 | 1521223.557 |
| A5 | 452536.193 | 1520773.43 |
| A6 | 451201.795 | 1520171.064 |
| A7 | 450657.211 | 1520035.529 |
| A8 | 450274.623 | 1522393.765 |
| A9 | 449648.488 | 1522245.003 |
| A10 | 448852.55 | 1524721.332 |
| A11 | 449522.411 | 1524900.565 |

| | | |
|---|---|---|
| A12 | 449752.755 | 1524085.616 |
| A13 | 450432.652 | 1524230.941 |

ខ- តំបន់២ ជាតំបន់អភិរក្សឧទ្យានបុរាណវិទ្យា ធនធានធម្មជាតិ និងទេសភាពវប្បធម៌ ដែលសម្បូរដោយប្រាសាទបុរាណ សំណល់ជាតិពន្ធុវិទ្យា ហេដ្ឋារចនាសម្ព័ន្ធបុរាណ ធនធានជីវចម្រុះជាដើម ហៅថាតំបន់ទ្រនាប់។ តំបន់ទ្រនាប់មានផ្ទៃក្រឡា ៣ ៥២៣ហិកតា ៧៧អា(បីពាន់ប្រាំរយម្ភៃបីហិកតាចិតសិបប្រាំពីរអា) ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| ចំណុច | រយៈទទឹង | រយៈបណ្តោយ |
|---|---|---|
| B1 | 450253.337 | 1516487.188 |
| B2 | 450282.326 | 1516820.772 |
| B3 | 450371.073 | 1517148.194 |
| B4 | 450466.323 | 1517264.61 |
| B5 | 450894.945 | 1517616.504 |
| B6 | 450974.319 | 1517706.461 |
| B7 | 451066.923 | 1517899.606 |
| B8 | 451092.058 | 1518029.251 |
| B9 | 451096.027 | 1518198.584 |
| B10 | 450989.237 | 1518804.395 |
| B11 | 450921.296 | 1519249.639 |
| B12 | 448996.527 | 1520313.801 |
| B13 | 447591.837 | 1520313.8 |
| B14 | 447596.509 | 1526341.317 |
| B15 | 450092.754 | 1526339.383 |
| B16 | 450073.358 | 1527007.655 |
| B17 | 450091.085 | 1527397.652 |
| B18 | 449496.698 | 1528488.31 |
| B19 | 449597.769 | 1528691.511 |
| B20 | 449430.982 | 1528928.346 |
| B21 | 449204.762 | 1528790.763 |
| B22 | 448531.396 | 1529440.316 |
| B23 | 448520.813 | 1529511.754 |
| B24 | 448240.354 | 1529585.837 |
| B25 | 447864.351 | 1529307.627 |
| B26 | 447565.373 | 1529462.106 |
| B27 | 448182.361 | 1530045.492 |
| B28 | 448437.863 | 1529865.138 |
| B29 | 448669.374 | 1529765.919 |
| B30 | 449201.702 | 1529683.028 |
| B31 | 449633.603 | 1529475.368 |
| B32 | 451102.498 | 1528657.161 |
| B33 | 452637.11 | 1528655.734 |
| B34 | 452633.258 | 1528245.287 |
| B35 | 451344.464 | 1528248.498 |

| | | |
|---|---|---|
| B36 | 451347.751 | 1527804.143 |
| B37 | 451512.056 | 1526313.756 |
| B38 | 453591.787 | 1526313.757 |
| B39 | 453591.791 | 1520313.804 |
| B40 | 452679.736 | 1520324.464 |
| B41 | 451925.124 | 1520003.31 |
| B42 | 452016.391 | 1518804.395 |
| B43 | 452141.125 | 1518005.44 |
| B44 | 451865.96 | 1517216.986 |
| B45 | 451651.649 | 1516955.05 |
| B46 | 451440.368 | 1516773.318 |
| B47 | 451273.298 | 1516629.614 |
| B48 | 451255.056 | 1516466.739 |

តំបន់២ ដែលជាតំបន់អភិរក្សឧទ្យានបុរាណវិទ្យាធនធានធម្មជាតិនិងទេសភាពវប្បធម៌ដែលត្រូវការពារ ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ រាល់ការលក់ដូរ ដោះដូរ ឬសម្បទានអ្វីមួយនៅលើដីធ្លីដែលស្ថិតក្នុងតំបន់នេះត្រូវចាត់ទុកជាមោឃៈ។ តំបន់នេះមិនត្រូវបានអនុញ្ញាតឱ្យមានសំណង់ឡើយ លើកលែងតែសំណង់លំនៅដ្ឋានប្រជាជនដែលមានស្រាប់ និងលើកលែងចំពោះការសាងសង់ដែលបម្រើឱ្យវិស័យទេសចរណ៍ កិច្ចការពារ និងការអភិរក្ស។ បទដ្ឋាននៃការប្រើប្រាស់ដីធ្លីនៅតំបន់២ ក្នុងតំបន់រមណីយដ្ឋានប្រាសាទកោះកេរ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

គ- តំបន់៣ ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ដោយរក្សាជីវភាព មុខរបរអាជីវកម្មតាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាជនក្នុងតំបន់ហៅថាតំបន់រណប។ តំបន់នេះជាគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌ និងធម្មជាតិ តាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍឱ្យមានចីរភាព និងមានការវាយតម្លៃផលប៉ះពាល់បរិស្ថាន។ តំបន់រណបមានក្រឡាផ្ទៃ ៤ ០៧៨ហិកតា ៥អា (បួនពាន់ចិតសិបប្រាំបីហិកតាសូន្យប្រាំអា) ដែលមានកំណត់ក្នុងនិយាមកាដូចខាងក្រោម៖

| ចំណុច | រយៈទទឹង | រយៈបណ្តោយ |
|---|---|---|
| C1 | 455103.168 | 1527804.144 |
| C2 | 455103.171 | 1518804.395 |
| C3 | 446102.94 | 1518804.394 |
| C4 | 446102.936 | 1527804.142 |
| C5 | 449785.737 | 1527804.143 |
| C6 | 449437.855 | 1528496.43 |
| C7 | 449539.727 | 1528687.091 |
| C8 | 449417.02 | 1528861.334 |
| C9 | 449198.406 | 1528728.471 |
| C10 | 448482.971 | 1529418.108 |
| C11 | 448476.182 | 1529471.828 |
| C12 | 448250.796 | 1529531.364 |
| C13 | 447871.253 | 1529250.494 |
| C14 | 447482.712 | 1529450.123 |

| | | |
|---|---|---|
| C15 | 448179.229 | 1530111.384 |
| C16 | 448462.397 | 1529909.022 |
| C17 | 448683.285 | 1529814.355 |
| C18 | 449223.179 | 1529728.18 |
| C19 | 449657.594 | 1529519.237 |
| C20 | 451115.562 | 1528707.149 |
| C21 | 452687.632 | 1528706.497 |
| C22 | 452685.515 | 1528193.469 |
| C23 | 451394.836 | 1528198.372 |
| C24 | 451397.743 | 1527804.143 |

តំបន់៣នេះ អាជ្ញាធរជាតិព្រះវិហារ និងរដ្ឋបាលខេត្តព្រះវិហារត្រូវកំណត់ប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី សៀវភៅបន្ទុកបទដ្ឋានបច្ចេកទេស គម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នគរូបនីយកម្ម និងសំណង់ស្ថាបត្យកម្មដោយសហការជាមួយនឹងស្ថាប័នពាក់ព័ន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្រៅពីដីដែលប្រជាជនកំពុងតាំងទីលំនៅនិងអាស្រ័យផលជាក់ស្តែងត្រូវចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋស្ថិតក្រោមការគ្រប់គ្រងរបស់អាជ្ញាធរជាតិព្រះវិហារ។ ចំពោះការកាប់ ទន្រ្ទាន ការឈូសឆាយដីព្រៃ ការបរបាញ់សត្វព្រៃគ្រប់ប្រភេទ និងការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ត្រូវបានហាមឃាត់ដាច់ខាត។

ផែនទីកំណត់តំបន់រមណីយដ្ឋានប្រាសាទកោះកេរ ជាឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៣
## ការគ្រប់គ្រង ការថែទាំ និងការការពារ

**មាត្រា៥ .-**

ការអភិរក្សរាល់តំបន់នីមួយៗត្រូវបានគ្រប់គ្រង ថែទាំ និងការពារស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ និងសារៈសំខាន់ជាក់លាក់ដោយឡែកៗ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា នរវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធនធានធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឱ្យមានតម្លៃកាន់តែខ្ពស់ឡើង។

**មាត្រា៦ .-**

បែបបទនិងនីតិវិធីនៃការរៀបចំនិងការគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទកោះកេរ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## ការកែប្រែតំបន់

**មាត្រា៧ .-**

បរិវេណនិងរាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានប្រាសាទកោះកេរ អាចត្រូវបានពិនិត្យឡើងវិញហើយកែប្រែបានដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់អ្នកបុរាណវិទ្យានិងស្ថានភាពជាក់ស្តែងដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ការអភិរក្ស និងការគ្រប់គ្រងប្រកបដោយនិរន្តរភាព ស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ការកែប្រែតំបន់និងរាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទកោះកេរត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរាជរដ្ឋាភិបាល។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា៨ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយដែលបានបង្កើតឡើងដោយអនុលោមតាមព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកែរ ត្រូវមានអានុភាពអនុវត្តបន្តទៅមុខទៀតរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមខ្លឹមសារនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៥០៤/០៧០ ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៤ ស្តីពីការកំណត់រមណីយដ្ឋានប្រាសាទកោះកែរនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សុក្រ ១២កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០២០

ពរស-២០១១.១៣២៥

ន សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**បណ្ឌិតសភាចារ្យ ភឿង សកុណា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**




បានឃើញនិងឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី០៤ ខែតុលា ឆ្នាំ ២០២០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ជា សុផារ៉ា

បានឃើញនិងឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០២០

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

បណ្ឌិតសភាចារ្យ ភឿង សកុណា

# ព្រះរាជក្រឹត្យ
# ស្តីពីការកំណត់រមណីយដ្ឋាន
# ប្រាសាទព្រះវិហារ

# ព្រះរាជក្រឹត្យ

នស/រកត/០៨១១/៧៥២

## ស្តីពី

## ការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្ត ទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស//រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាស ឲ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៤៨ ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិ ដើម្បីការពារ និងអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ធម្មជាតិនៃប្រាសាទ ព្រះវិហារ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## គ្រាស់បន្ទាប់
## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.~**

ត្រូវបានប្រកាសកំណត់យកដីទំហំ ៤៨.០១៨ ហិកតា នៅក្នុងឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៃជួរភ្នំដងរែកជារមណីយដ្ឋានប្រាសាទព្រះវិហារ ដែលត្រូវបានកំណត់និយាមកាតាមបណ្តាចំណុចដែលមានខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយដូចខាងក្រោមៈ

| ចំណុច | ខ្សែរយៈទទឹង | ខ្សែរយៈបណ្តោយ |
|---|---|---|
| A1 | ខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃឡង់ដ៍ (៤៥១៨១៤-១៥៨៦៩៣០) | |
| A2 | ៤៥៤៦៨២ | ១៥៧៧៣៧២ |
| A3 | ៤៥៣៩៥៤ | ១៥៧៦៤០៩ |
| A4 | ៤៥៤៦១១ | ១៥៧៥០៧៥ |
| A5 | ៤៥៥៤៧៣ | ១៥៧៥០៧៨ |
| A6 | ៤៦០៩៥៩ | ១៥៧៤៨៧៧ |
| A7 | ៤៧១២១២ | ១៥៧៣៩៨១ |
| A8 | ៤៧៦៨៨៨ | ១៥៧៧០៣១ |
| A9 | ៤៧៦៨៨៧ | ១៥៧៩៣២០ |
| A10 | ៤៧៨១២០ | ១៥៧៩៣១៨ |
| A11 | ៤៨០៩៥៧ | ១៥៧៩៣១៨ |
| A12 | ៤៧៩៩៨៩ | ១៥៨៨១៨៦ |
| A13 | ខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃឡង់ដ៍(៤៨១៨៨៣-១៥៩៣៨៨២) | |

**មាត្រា ២.~**

ការបង្កើតរមណីយដ្ឋានប្រាសាទព្រះវិហារមានគោលបំណង ៖

- អភិរក្សកេរដំណែលវប្បធម៌ បុរាណវិទ្យា ជាតិពិន្ទុវិទ្យា ប្រវត្តិវិទ្យា និងការពារតម្លៃលេចធ្លោជាសកលនៃរមណីយដ្ឋានប្រាសាទព្រះវិហារ។
- អភិរក្សទេសភាពវប្បធម៌ អភិវឌ្ឍសេដ្ឋកិច្ច និងទេសចរណ៍ប្រកបដោយចីរភាព។
- ការពារបរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង។
- អនុវត្តតាមផែនការមេគ្រប់គ្រងតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ ដែលបានទទួលស្គាល់ដោយគណៈកម្មការបេតិកភ័ណ្ឌពិភពលោក (WHC)

## ជំពូកទី ២
## ការកំណត់តំបន់

**មាត្រា ៣.-**

តម្រូវអោយត្រួតពិនិត្យរាល់ការអភិវឌ្ឍន៍រមណីយដ្ឋានការពារដោយគោរពតាមផែនទីកំណត់តំបន់ និងការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់តំបន់ត្រូវការពារ។

**មាត្រា ៤.-**

រមណីយដ្ឋានប្រាសាទព្រះវិហារត្រូវចាត់ជា ៤ (បួន) តំបន់ ហើយត្រូវទទួលកំរិតការពារអភិរក្ស និងអភិវឌ្ឍក្នុងតំបន់ខុសៗគ្នា ៖

ក- **តំបន់១៖** **ជាតំបន់ប្រាសាទ** សំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហៅថាតំបន់ស្នូលដែលត្រូវការពារកំរិតខ្ពស់បំផុត។ តំបន់ស្នូលត្រូវបានកំណត់យកតួប្រាសាទទាំងមូល រចនាសម្ព័ន្ធប្រាសាទព្រះវិហារដូចជា៖ កសិណ ស្រះបុរាណ បារាយណ៍ ស្ពាន បង្គោលសីមា ល្អាងបុរាណ។ល។ និងតំបន់ ៣០ម៉ែត្រ ចេញពីឃឿនព័ទ្ធជុំវិញប្រាសាទព្រះវិហារ និងខ្សែបន្ទាត់ព្រំដែន កម្ពុជា-ថៃ រាប់បញ្ចូលទាំងជណ្តើរប្រវត្តិសាស្ត្រ ដែលស្ថិតនៅខាងកើតភ្នំព្រះវិហារ ដោយត្រូវរក្សាទុកចំណីជណ្តើរចម្ងាយ ៥០ ម៉ែត្រសងខាង។

ខ- **តំបន់២៖** **ជាតំបន់អភិរក្សឧទ្យានបុរាណវិទ្យា ធនធានធម្មជាតិ និង ទេសភាពវប្បធម៌** ហៅតំបន់ទ្រនាប់។ តំបន់ទ្រនាប់មានចំណុចខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយតាមប្រព័ន្ធ GWS 84 ដូចខាងក្រោម:

| ចំណុច | ខ្សែរយៈទទឹង | ខ្សែរយៈបណ្តោយ |
|---|---|---|
| B1 | ខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃឡង់ដ៍ (៤៧៥៥៥២-១៥៩៩៤៦៥០) | |
| B2 | ៤៧៥៥៥២ | ១៥៨០៣៤៥ |
| B3 | ៤៧០៦៧៩ | ១៥៨០៣៤៥ |
| B4 | ៤៧០១៦១ | ១៥៨៥៥៥៩ |
| B5 | ៤៦៨១៦១ | ១៥៨៥៥៥៩ |
| B6 | ៤៦៨៦៧៦ | ១៥៨០៣៤៥ |
| B7 | ៤៥៩៥៧៥ | ១៥៨០៣៤៥ |
| B8 | ៤៥៥៥៥៧ | ១៥៨០៣៤៥ |
| B9 | ខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃឡង់ដ៍ (៤៥៥៥៥៧-១៥៨៩៧៣៩) | |

**តំបន់ ២** ដែលជាឧទ្យានសំណល់បុរាណវត្ថុត្រូវការពារ ដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ រាល់ការលក់ដូរ ដោះដូរ ឬសម្បទានអ្វីមួយនៅលើដីធ្លី

3/6

ដែលស្ថិតក្នុងតំបន់នេះត្រូវចាត់ទុកជាមោឃៈ។ តំបន់នេះសម្បូរដោយសំណល់បុរាណវត្ថុដែលត្រូវការពារ ទប់ស្កាត់នូវការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍន៍ ដែលមិនសមស្រប។

តំបន់ ២ ជាតំបន់ការពារធនធានធម្មជាតិ និងទេសភាពវប្បធម៌ ដែលកំណត់ដោយព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ។

គ- តំបន់៣៖ ជាតំបន់អភិវឌ្ឍវិស័យ សង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ ស្ថិតនៅក្នុងតំបន់អភិវឌ្ឍភូមិធម្មជាតិសម្តេចតេជោ ហ៊ុន សែន និងតំបន់តាមបណ្តោយផ្លូវពីព្រំប្រទល់ភូមិធម្មជាតិទៅប្រាសាទ ដែលជាច្រកចូលសំខាន់នៃរមណីយដ្ឋានប្រាសាទព្រះវិហារ។ តំបន់នេះជាគោលដៅថែរក្សាបេតិកភណ្ឌវប្បធម៌ និងធម្មជាតិតាមរយៈការចាត់ចែងវិធានការដើម្បីជំរុញការអភិវឌ្ឍន៍ឲ្យមានចីរភាព និងមានការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន និងបុរាណវិទ្យា។

តំបន់៣នេះ អាជ្ញាធរជាតិព្រះវិហារ និងអាជ្ញាធរខេត្តព្រះវិហារ ត្រូវកំណត់ប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី សៀវភៅបន្ទុក បទដ្ឋានបច្ចេកទេស គំរោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នគរូបនីយកម្ម សំណង់ស្ថាបត្យកម្ម ដោយសហការជាមួយស្ថាប័នពាក់ពន្ធ័ ស្របតាមបទប្បញ្ញត្តិ និងច្បាប់ទាំងឡាយជាធរមាន។

តំបន់ ៣ នេះត្រូវបានចែកជា ២ (ពីរ) តំបន់ដាច់ពីគ្នាគឺ ៖

- តំបន់ ៣ក គឺជាដីសម្បទានសង្គមកិច្ច ជាតំបន់អភិវឌ្ឍលំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ និងសេដ្ឋកិច្ច គ្រួសារដែលមានផ្ទៃក្រឡា ៤.៥១២ហិកតា ស្ថិតនៅក្នុងបរិវេណខ្សែបន្ទាត់និយាមកា តាមប្រព័ន្ធ GWS 84 នៃចំណុចដូចខាងក្រោម៖

| ចំណុច | ខ្សែរយៈទទឹង | ខ្សែរយៈបណ្តោយ |
|---|---|---|
| D1 | ៤៦៨៦៧៦ | ១៥៨០៣៤៥ |
| D2 | ៤៦៨៦៧៦ | ១៥៧៥៣៨៩ |
| D7 | ៤៦៥១៤០ | ១៥៧៥៣៨៩ |
| D8 | ៤៦៥១៤០ | ១៥៨០៣៤៥ |

តំបន់ ៣ក ត្រូវបានបែងចែកជា តំបន់ប្រើប្រាស់សំរាប់ដីសម្បទានសង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដីបំរុងវិនិយោគសំរាប់អភិវឌ្ឍវិស័យសេដ្ឋកិច្ច វប្បធម៌ ទេសចរណ៍ និងតំបន់រដ្ឋបាល ដែលត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។

- តំបន់ ៣ខ ជាតំបន់ការពារគម្របព្រៃឈើ និងត្រូវដាំដើមឈើឡើងវិញស្របតាមអ័ក្សផ្លូវជាតិលេខ ៦២។ ចំពោះការប្រើប្រាស់ដីក្នុងគោលបំណងអភិវឌ្ឍសេដ្ឋកិច្ចគ្រួសារត្រូវកំណត់ចម្ងាយមិនលើសពី ១.០០០ម៉ែត្រ អមសងខាង អ័ក្សផ្លូវ ចាប់ពីចំណុច

A3(៤៦៩៩០៣-១៥៧៥៣៥៩) ដល់ចំណុច P6(៤៦៩១៦១-១៥៨៥៥៥៩)។ ដើម្បីរក្សាទេសភាពធម្មជាតិ រាល់សំណង់ទាំងឡាយមិនត្រូវបានអនុញ្ញាតទេ ដោយត្រូវរក្សាគម្របធម្មជាតិ ៥០ម៉ែត្រ ពីសង្ខាងអ័ក្សផ្លូវដែលត្រូវបានចាត់ទុកជាដីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។ ការកំណត់ព្រំកម្មសិទ្ធិ និងព្រំសំណង់ អាចធ្វើទៅបានចាប់ពីចំងាយ ៥០ម៉ែត្រ ពីអ័ក្សផ្លូវ ដោយមានការអនុញ្ញាតិពីអាជ្ញាធរជាតិព្រះវិហារ និងអាជ្ញាធរខេត្តព្រះវិហារ។

ឃ-តំបន់៤៖ ជាតំបន់បំរុងអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាព និងការអភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ។ តំបន់នេះត្រូវបានកំណត់យកផ្ទៃដីដែលនៅសល់ពី តំបន់១ តំបន់២ តំបន់៣ ដែលមានភូមិសាស្ត្រស្ថិត នៅក្នុងឃុំស្រអែម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

រាល់ការប្រើប្រាស់ដីសំរាប់គោលបំណងអភិវឌ្ឍក្នុងតំបន់ ៤ ត្រូវគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី ដែលមានចែងនៅក្នុងបទប្បញ្ញត្តិទាំងឡាយ ដែលកំណត់ដោយអាជ្ញាធរជាតិព្រះវិហារ និងអាជ្ញាធរខេត្តព្រះវិហារ។

ផែនទីកំណត់ព្រំប្រទល់ និងបែងចែកតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារមានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និងការពារ

**មាត្រា ៥.-**

ការអភិរក្សតំបន់និមួយៗ ត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យនេះ និងកំរិតនៃសារៈសំខាន់ដោយឡែកៗ ខាងបុរាណវិទ្យា ជាតិពិន្ទុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ទេសភាពធម្មជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឲ្យមានតម្លៃកាន់តែប្រសើរឡើង។

**មាត្រា ៦.-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការទទួលខុសត្រូវរបស់បណ្ដាស្ថាប័នមានសមត្ថកិច្ចដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់។

យោងមាត្រា ៥ នៃច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ រមណីយដ្ឋានប្រាសាទព្រះវិហារត្រូវប្រគល់ឲ្យអាជ្ញាធរជាតិព្រះវិហារ ដើម្បីការពារថែរក្សា អភិរក្ស និងអភិវឌ្ឍប្រកបដោយចីរភាព។

បែបបទ និងនិតិវិធី នៃការគ្រប់គ្រង ការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍរមណីយដ្ឋានប្រាសាទព្រះវិហារ ក្នុងបណ្ដាមាត្រាខាងលើត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា ៧.-**

បរិវេណ និងរាល់សកម្មភាពនៅក្នុងតំបន់និមួយៗនៃរមណីយដ្ឋានប្រាសាទព្រះវិហារ អាចត្រូវបានពិនិត្យឡើងវិញ ហើយកែប្រែបានដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិរក្ស ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមកិច្ចប្រកបដោយចីរភាព ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ។

ការកែប្រែតំបន់ និងរាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៨៣ ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៩.-**

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១១*

*ពរសល.១១០៧.៧៦៩*

*នរោត្តម សីហមុនី*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ផែនទីកំណត់ព្រំប្រទល់ និងបែងចែកតំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ




និយាមការព្រំដីវាលឃុំស្រអែម

| X | Y | ID |
|---|---|---|
| 451814 | 1586930 | A1 |
| 454682 | 1577372 | A2 |
| 453954 | 1576409 | A3 |
| 454611 | 1575075 | A4 |
| 455473 | 1575078 | A5 |
| 460959 | 1574877 | A6 |
| 471160 | 1574009 | A7 |
| 476888 | 1577031 | A8 |
| 476887 | 1579320 | A9 |
| 478117 | 1579318 | A10 |
| 480955 | 1579322 | A11 |
| 479989 | 1588186 | A12 |
| 481883 | 1593882 | A13 |

និយាមការគោលព្រំរមណីយដ្ឋានប្រាសាទព្រះវិហារ

| X | Y | ID |
|---|---|---|
| 475552 | 1594650 | B1 |
| 475552 | 1580345 | B2 |
| 470679 | 1580345 | B3 |
| 470161 | 1585559 | B4 |
| 468161 | 1585559 | B5 |
| 468676 | 1580345 | B6 |
| 459575 | 1580345 | B7 |
| 455557 | 1580345 | B8 |
| 455557 | 1589739 | B9 |
| 469001 | 1578585 | C1 |
| 469001 | 1579336 | C2 |
| 471358 | 1578585 | C3 |
| 471358 | 1579336 | C4 |
| 468676 | 1580345 | D1 |
| 468676 | 1575389 | D2 |
| 465140 | 1575389 | D3 |
| 465140 | 1580345 | D4 |
| 463035 | 1580345 | D5 |
| 463035 | 1575389 | D6 |
| 459576 | 1580345 | D8 |
| 459576 | 1575389 | D7 |
| 475449 | 1588127 | P1 |
| 469644 | 1580345 | P2 |
| 462418 | 1580345 | P3 |
| 455557 | 1584513 | P4 |
| 455557 | 1585263 | P5 |
| 469161 | 1585559 | P6 |
| 461007 | 1575389 | P7 |

បានឃើញ និង ឯកភាព
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
បណ្ឌិតសភាចារ្យ សុខ អាន

បានឃើញ និង ឯកភាព
ព្រះវិហារ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១
អាជ្ញាធរជាតិ ព្រះវិហារ
ប្រធាន

បានឃើញ និង ឯកភាព
ព្រះវិហារ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១
គណៈអភិបាលខេត្តព្រះវិហារ
អភិបាល
អ៊ុំ ម៉ារ៉ា

បានឃើញ និង ឯកភាព
ព្រះវិហារ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១
ក្រុមការងារពិសេសថ្នាក់ជាតិ តំបន់ព្រះវិហារ
អនុប្រធានប្រចាំការ
សួស យ៉ារ៉ា

បានឃើញ និង ឯកភាព
ព្រះវិហារ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១
លេខាធិការដ្ឋានក្រុមការងារពិសេសថ្នាក់ជាតិ តំបន់ព្រះវិហារ
ស ថាវី
ហង្ស សុត

បានកំណត់និយាមការតាមប្រព័ន្ធ WGS 84
ព្រះវិហារ ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០១១
មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់
ប្រធាន
គង់ សោភ័ណ

# ព្រះរាជក្រម
# ប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពី
# កិច្ចការពារបេតិកភណ្ឌវប្បធម៌

# ព្រះរាជក្រម

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧបភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម**

**ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតេយ្យ**

******************

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ វិច្ឆកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ចុះថ្ងៃទី១០ ខែ សីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំទឹកដីនគរបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែ កុម្ភះ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធមិជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភះ ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតអាជ្ញាធរដើម្បីការពាររមនីយដ្ឋាន និង រៀបចំតំបន់អង្គរ ហៅថា" **អប្សរា**"
- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស/ចុះថ្ងៃទី២៨ ខែ ឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់និង ការចាត់ចែងគ្រប់គ្រងតំបន់សៀមរៀបអង្គរ
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងវប្បធមិនិងវិចិត្រសិល្បៈដែលរដ្ឋសភាបានអនុមត័កាលពីថ្ងៃទី២៥ ខែ តុលា ឆ្នាំ ១៩៩៥
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និង អំពីទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការវប្បធមិ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគររូបនីយកម្មនិង សំណង់

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធមិ ដែលរដ្ឋសភាបានអនុមត័នាសម័យប្រជុំលើកទី៥នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចតទៅ :

# ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិនិងសម្បត្តិវប្បធម៌ទូទៅ ប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីករុករក ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់ ។

**មាត្រា ២.-**

បេតិកភណ្ឌវប្បធម៌ជាតិគឺជាសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើងឬក៏បានរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ ។

**មាត្រា ៣.-**

ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ជាចលនៈនិងអចលនៈ ទោះជាកម្មសិទ្ធិសាធារណៈក្តី ឬក៏ជាឯកជនក្តី ហើយកិច្ចការពារនេះគឺជាផលប្រយោជន៍សាធារណៈ ។

លើកលែងតែមានបទបញ្ញត្តិផ្ទុយពីច្បាប់នេះ ច្បាប់នេះអនុវត្តទៅលើសម្បត្តិវប្បធម៌ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ ។

**មាត្រា ៤.-**

តាមន័យនៃច្បាប់នេះ សម្បត្តិវប្បធម៌គឺរាល់ស្នាដៃរបស់មនុស្សនិងរាល់ផលិតផលរបស់ធម្មជាតិ ដែលមានចរិតវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ដែលឆ្លុះបញ្ចាំងពីដំណាក់កាលនៃការវិវត្តន៍របស់អារ្យធម៌ឬរបស់ធម្មជាតិ ហើយដែលកិច្ចការពារសម្បត្តិវប្បធម៌ទាំងនោះ បំរើផលប្រយោជន៍សាធារណៈ ។

សម្បត្តិវប្បធម៌ដែលបានរៀបរាប់ក្នុងមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

# ជំពូកទី ២

## បទបញ្ញត្តិពិសេស

### ផ្នែកទី ១

### ស្ថាប័នគ្រប់គ្រងនិងប្រតិបត្តិ

**មាត្រា ៥.-**

ការលើកគោលនយោបាយទូទៅ ក្នុងវិស័យសម្បត្តិវប្បធម៌ជាតិជាពិសេសដើម្បីការពារថែរក្សានិងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិ គឺជាភារកិច្ចរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ (ក.ជ.វ.ជ) ដែលមានក្រសួងវប្បធម៌និងវិចិត្រសិល្បៈជាស្ថាប័នប្រតិបត្តិ ។

ដោយឡែកនៅតំបន់សៀមរាបអង្គរ ការការពារថែរក្សានិងលើកតម្លៃបេតិកភណ្ឌវប្បធម៌ជាតិត្រូវប្រគល់អោយអាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរអប្សរា ។

ការសម្របសម្រួលភារកិច្ចរវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងស្ថាប័នពាក់ព័ន្ធដទៃទៀតត្រូវកំណត់ដោយអនុក្រឹត្យ ។

### ផ្នែកទី ២

### រមណីយដ្ឋានដែលត្រូវការពារ

**មាត្រា ៦.-**

រមណីយដ្ឋានដែលត្រូវការពាររួមមាន :

-ឧទ្យានដែលមានបុរាណវត្ថុឬរមណីយដ្ឋានដទៃទៀតដែលមានអត្ថប្រយោជន៍សំរាប់បុរាណវិទ្យា នរវិទ្យាឬប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន ។

-ព្រំដែននៃបរិវេណរមណីយដ្ឋានដែលត្រូវការពារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់ ក.ជ.វ.ជ ។

# ជំពូកទី ៣
## បញ្ជីសារពើភណ្ឌ

**មាត្រា ៧.-**

ការចុះបញ្ជីសារពើភណ្ឌ គឺជាការកត់ត្រាបញ្ចូលនូវសម្បត្តិវប្បធម៌សាធារណៈឬឯកជន ដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ទោះជាសម្បត្តិទាំងនោះមិនត្រូវឱ្យចាត់ថ្នាក់ជាប្រញាប់ក៏ដោយ ។

**មាត្រា ៨.-**

ការចុះបញ្ជីសារពើភណ្ឌនេះ ត្រូវប្រកាសឡើងដោយសេចក្តីសំរេចរបស់អាជ្ញាធរមានសមត្ថកិច្ចដែលមានចែងក្នុងមាត្រា ៥ ។

**មាត្រា ៩.-**

ក្រោយពីបានចុះបញ្ជីសារពើភណ្ឌរួចហើយ ចាំបាច់ត្រូវឱ្យម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់ទ្រព្យសម្បត្តិនោះ ជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចមួយខែមុននឹងខ្លួនធ្វើសកម្មភាពណាមួយក្នុងបំណងនឹងលក់ឬផ្ទេរកម្មសិទ្ធិ ផ្លាស់ប្តូរទី តាំង បំផ្លាញចោល ប្រែក្លាយផ្លាស់ប្តូររូបរាង ជួសជុលឬធ្វើការស្តាបនាឡើងវិញនូវសម្បត្តិវប្បធម៌នោះ ។

អាជ្ញាធរមានសមត្ថកិច្ចអាចប្រឆាំងនឹងសកម្មភាពខាងលើបែបនេះបាន លុះត្រាតែបានចាត់វិធានការសមស្របតាមនីតិក្រមចំណាត់ថ្នាក់ ។

**មាត្រា ១០.-**

ការចុះបញ្ជីសារពើភណ្ឌត្រូវទុកជាមោឃៈបើសិនជាមិនបានបញ្ជូនបន្ថែមនូវសំណើសុំបញ្ចូលចំណាត់ថ្នាក់ជាសម្បត្តិវប្បធម៌ក្នុងរយៈពេលប្រាំមួយខែ ចាប់តាំងពីពេលដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរនោះមក ។

## ជំពូកទី ៤

## ចំណាត់ថ្នាក់

**មាត្រា ១១.-**

ចំណាត់ថ្នាក់គឺការកត់ត្រាសម្បត្តិវប្បធម៌សាធារណៈឬឯកជនទាំងឡាយដែលបានចុះក្នុងបញ្ជីសារពើភណ្ឌ ហើយកិច្ចការពារនោះគឺដើម្បីបំរើផលប្រយោជន៍សាធារណៈក្នុងវិស័យវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈឬសាសនា ។

**មាត្រា ១២.-**

សំណើសុំចំណាត់ថ្នាក់ ត្រូវធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចដែលជាអ្នកជូនដំណឹងឱ្យបានត្រឹមត្រូវជាលាយលក្ខណ៍អក្សរទៅម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ ។

**មាត្រា ១៣.-**

បន្ទាប់ពីការជូនដំណឹងជាលាយល័ក្ខណ៍អក្សររួចមក បើសិនជាគ្មានសេចក្តីសំរេចក្នុងរយៈពេលដប់ពីរខែ សំណើសុំចំណាត់ថ្នាក់នឹងត្រូវទុកជាមោឃៈ។

**មាត្រា ១៤.-**

ចំណាត់ថ្នាក់ ត្រូវប្រកាសឡើងដោយសេចក្តីសំរេចរបស់អាជ្ញាធរមានសមត្ថកិច្ច ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើសេចក្តីសំរេចក្នុងរយៈពេលបីខែ គិតចាប់តាំងពីថ្ងៃដែលម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់បានទទួលលិខិតជូនដំណឹងរបស់អាជ្ញាធរនោះ ។

**មាត្រា ១៥.-**

ចំណាត់ថ្នាក់ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់កម្មសិទ្ធិឬម្ចាស់កាន់កាប់ ក្នុងករណីជាចាំបាច់ ត្រូវជូនដំណឹងទៅមន្ទីររក្សាអចលវត្ថុ (មន្ទីរទទួលបន្ទុកគ្រប់គ្រងបញ្ជីអចលនវត្ថុ)។

**មាត្រា ១៦.-**

ក្នុងករណីដែលម្ចាស់កម្មសិទ្ធិមិនយល់ព្រម ចំណាត់ថ្នាក់សម្បត្តិវប្បធម៌នៅតែត្រូវធ្វើជាដដែល ។

**មាត្រា ១៧.-**

ការបង់ខាតដែលបណ្តាលមកពីចំណាត់ថ្នាក់សម្បត្តិវប្បធម៌នេះ អាចត្រូវទូទាត់ជាប្រាក់បំណាច់ឱ្យដល់ម្ចាស់កម្មសិទ្ធិ ។

ពាក្យសុំទារប្រាក់បំណាច់ត្រូវដាក់មកអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេលបីខែគិតចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីសេចក្តីសំរេចនៃចំណាត់ថ្នាក់នេះ ។

ចំនួនប្រាក់បំណាច់ខាងលើនេះ ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

ការតវ៉ាចំពោះសេចក្តីសំរេចស្តីពីគោលការណ៍ឬពីចំនួនប្រាក់បំណាច់ អាចនឹងធ្វើឡើងនៅចំពោះមុខតុលាការមានសមត្ថកិច្ច ។

**មាត្រា ១៨.-**

អាជ្ញាធរមានសមត្ថកិច្ចធ្វើតារាងសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយជារៀងរាល់ដំណាច់ឆ្នាំ ។

តារាងសម្បត្តិវប្បធម៌ចាត់ថ្នាក់នេះត្រូវធ្វើតាមខេត្តនីមួយៗ ហើយត្រូវចុះក្នុងរាជកិច្ច ។

ប្រការដែលត្រូវចុះមានជាអាទិ៍ :

-ប្រភេទនៃសម្បត្តិវប្បធម៌ដែលត្រូវបានចាត់ថ្នាក់

-ទីកន្លែងដែលសម្បត្តិវប្បធម៌នោះស្ថិតនៅ

-គោត្តនាមនិងនាមរបស់ម្ចាស់កម្មសិទ្ធិ

-កាលបរិច្ឆេទនៃចំណាត់ថ្នាក់ ។

**មាត្រា ១៩.-**

សម្បត្តិវប្បធម៌ដែលចាត់ថ្នាក់រួចហើយ មិនអាចកែប្រែបានឡើយ ។

**មាត្រា ២០.-**

សម្បត្តិវប្បធម៌ដែលចាត់ថ្នាក់រួចហើយ ដែលជាកម្មសិទ្ធិរបស់រដ្ឋឬរបស់នីតិបុគ្គលសាធារណៈមិនអាចលក់ឬផ្ទេរកម្មសិទ្ធិបានឡើយ ។

**មាត្រា ២១.-**

ជនណាក៏ដោយដែលលក់ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដែលបំរុងចាត់ថ្នាក់ឬត្រូវបានចាត់ថ្នាក់រួចហើយ ត្រូវតែ :

-ជូនដំណឹងជាមុនដល់អ្នកទទួល អំពីស្ថានភាពរបស់សម្បត្តិវប្បធម៌ ។

-ជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីចេញប័ណ្ណលក់ឬផ្ទេរ ដោយបញ្ជាក់ពីគោត្តនាម នាមនិងទីលំនៅនៃអ្នកទទួល ព្រមទាំងកាលបរិច្ឆេទនៃការលក់ឬផ្ទេរនោះ។ បើផ្ទុយពីបទបញ្ញត្តិខាងលើនេះ ការលក់ឬផ្ទេរនឹងត្រូវចាត់ទុកជាមោឃៈ ។

**មាត្រា ២២.-**

ការលក់ឬផ្ទេរកម្មសិទ្ធិនូវសម្ភារៈឬបំណែកផ្សេងៗ ដែលផ្តាច់ចេញដោយខុសច្បាប់ពីសម្បត្តិវប្បធម៌ណាមួយដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ក៏ដូចជារាល់អំពើណាដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិឬកាន់កាប់សម្ភារៈឬផ្នែកណាមួយនៃសម្បត្តិវប្បធម៌ទៅឱ្យអ្នកដទៃ ត្រូវទុកជាមោឃៈនិងអសារឥតការ ។

អ្នកដទៃនោះត្រូវរួមទទួលខុសត្រូវជាមួយម្ចាស់កម្មសិទ្ធិក្នុងការរៀបដាក់កន្លែងដើមវិញនូវសម្ភារៈឬបំណែកដែលខ្លួនបានទទួល ។ ជននោះគ្មានសិទ្ធិនឹងទាមទារជំងឺចិត្តពីរដ្ឋឡើយ ។

**មាត្រា ២៣.-**

សម្បត្តិវប្បធម៌ដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ពុំអាចត្រូវទទួលការផ្លាស់ប្តូរទីកន្លែង ការបំផ្លិចបំផ្លាញ ការធ្វើអោយខូចខាត ការប្រែរូបរាង ការទទួល ការជួសជុលឬស្ថាបនាឡើងវិញ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ដែលជាអ្នកកំណត់ល័ក្ខខ័ណ្ឌនិងត្រួតពិនិត្យការអនុវត្តការងារនោះឡើយ ។

**មាត្រា ២៤.-**

ម្ចាស់កម្មសិទ្ធិដែលដាក់ពាក្យសុំការអនុញ្ញាតដើម្បីកែប្រែ ជួសជុលសម្បត្តិវប្បធម៌ណាមួយដែលបំរុងចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ត្រូវដាក់គំរោងប្លង់ព្រមទាំងឯកសារផ្សេងៗទៀតជូនអាជ្ញាធរមានសមត្ថកិច្ចពិនិត្យនិងសំរេច ។

**មាត្រា ២៥.-**

ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ត្រូវបានទទួលការគាំពារសម្បត្តិវប្បធម៌នោះ ដែលបានចាត់ថ្នាក់រួចហើយ ។

ចំណាយទាំងឡាយលើការជួសជុលឬថែទាំសម្បត្តិវប្បធម៌នោះ គឺជាបន្ទុករបស់ម្ចាស់កម្មសិទ្ធិ ។

អាជ្ញាធរមានសមត្ថកិច្ចអាចនឹងចេញសងជាភាគខ្លះ ។ ចំពោះចំណាយទាំងស្រុងជាសមត្ថកិច្ចរបស់គណៈរដ្ឋមន្ត្រី ។

**មាត្រា ២៦.-**

អាជ្ញាធរមានសមត្ថកិច្ចជាអ្នកត្រួតពិនិត្យនូវការងារជាបន្ទាន់ក្នុងការជួសជុលសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយនិងទុកឱ្យគណៈរដ្ឋមន្ត្រីសំរេច ។

ម្ចាស់កម្មសិទ្ធិសម្បត្តិវប្បធម៌ខាងលើ មិនអាចប្រឆាំងនឹងការអនុវត្តទាំងនោះបានឡើយ ។

**មាត្រា ២៧.-**

អនុភាពនៃការចាត់ថ្នាក់នឹងចាប់មានប្រសិទ្ធិភាព ចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីអំពីសំណើសុំចាត់ថ្នាក់ ។

អនុភាពនោះនៅតែមានតំលៃជានិច្ច ទោះបីសម្បត្តិវប្បធម៌នោះត្រូវប្តូរកម្មសិទ្ធិក៏ដោយ ។

## ផ្នែកទី ៥
## សិទ្ធិទិញបានមុនគេនិងសិទ្ធិដកហូតកម្មសិទ្ធិ

**មាត្រា ២៨.-**

អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិទិញបានមុនគេលើរាល់ការលក់ដូរសម្បត្តិវប្បធម៌ដែលចុះបញ្ជីសារពើភណ្ឌរួចហើយ កំពុងស្នើចាត់ថ្នាក់ឬបានចាត់ថ្នាក់រួចហើយ ។

ជនណាដែលមានបំណងនឹងលក់សម្បត្តិវប្បធម៌ដែលចែងក្នុងកថាខណ្ឌខាងលើនេះ ត្រូវតែជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ស្តីពីការលក់នេះក្នុងរយៈពេល ៣០ថ្ងៃជាមុន ។

**មាត្រា ២៩.-**

ក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់តាំងពីកាលបរិច្ឆេទនៃការទទួលដំណឹងដែលមានចែងនៅក្នុងមាត្រា ២៨ កថាខណ្ឌទី ២ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់បញ្ជាក់ជាលាយលក្ខណ៍អក្សរដល់ម្ចាស់កម្មសិទ្ធិ អំពីការសំរេចចិត្តរបស់ខ្លួនដើម្បីទិញយកឬមិនទិញយកសម្បត្តិវប្បធម៌ដែលស្នើលក់តាមលក្ខខណ្ឌនិងតាមថ្លៃកំណត់ ។

ការខកខានមិនបានឆ្លើយតបដោយហួសរយៈពេល ៣០ថ្ងៃ ដូចបានចែងក្នុងកថាខណ្ឌខាងលើនេះ គឺមានន័យថាជាការបោះបង់មិនអនុវត្តសិទ្ធិទិញបានមុនគេ ។

**មាត្រា ៣០.-**

អាជ្ញាធរមានសមត្ថកិច្ចអាចដកហូតកម្មសិទ្ធិអចលនសម្បត្តិវប្បធម៌ ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌដែលត្រូវបានបំរុងឱ្យធ្វើចំណាត់ថ្នាក់ឬបានធ្វើចំណាត់ថ្នាក់រួចហើយ អាចត្រូវបានដកហូតកម្មសិទ្ធិតាមបែបបទដែលចែងដោយច្បាប់ស្តីពីការដកហូតកម្មសិទ្ធិដើម្បីផលប្រយោជន៍សាធារណៈ ។

## ផ្នែកទី ៦
## ការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុ

**មាត្រា ៣១.-**

ការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុផ្សេងៗ អាចអនុញ្ញាតបានក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះក្រោយពីមានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច។ បែបបទនៃការធ្វើពាណិជ្ជកម្មលើបុរាណវត្ថុត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣២.-**

លិខិតអនុញ្ញាតនេះត្រូវចុះជាអាទិ៍ : គោត្តនាម នាម លំនៅឋានពាណិជ្ជករ សមត្ថភាពឯកទេសព្រមទាំងប្រភេទបុរាណវត្ថុនិងមានការបញ្ជាក់ច្បាស់លាស់ពីទីកន្លែងដែលខ្លួនមានបំណងប្រកបអាជីវកម្មនេះ ។ លិខិតអនុញ្ញាតនេះផ្តល់ជូនសំរាប់រយៈពេល ១ឆ្នាំ ព្រមទាំងអាចបន្ត១ឆ្នាំម្តងៗ ហើយពុំអាចបង្វែរទៅឱ្យ ជនដទៃបានឡើយ ។

**មាត្រា ៣៣.–**

រាល់ពាណិជ្ជករដែលមានច្បាប់អនុញ្ញាត ត្រូវប្រកាន់ខ្ជាប់នូវភារកិច្ចដូចតទៅ :

ក-បិទសេចក្តីប្រកាសបញ្ជាក់ថា ខ្លួនបានទទួលច្បាប់អនុញ្ញាតឱ្យធ្វើពាណិជ្ជកម្មបុរាណវត្ថុនៅត្រង់ទ្វារចូលនៃអាគារលក់ដូររបស់ខ្លួន ។

ខ-មិនត្រូវដាក់បុរាណវត្ថុមួយសំរាប់លក់នៅក្រៅអាគារ ដែលខ្លួនបានច្បាប់អនុញ្ញាតឱ្យប្រកបអាជីវកម្ម ។

គ-ចុះជាប្រចាំក្នុងបញ្ជីកត់ត្រាជាលំអិតនូវបុរាណវត្ថុដែលខ្លួនមាននិងសកម្មភាពលក់ចេញនិងទិញចូលរាល់ថ្ងៃ ។

ឃ-ត្រូវបង្ហាញដល់ភ្នាក់ងារត្រួតពិនិត្យនូវសៀវភៅបញ្ជីខាងលើនេះ រាល់ពេលណាដែលភ្នាក់ងារទាំងនោះទាមទារពិនិត្យ ។

ង-ត្រូវបិទបញ្ញត្តិគ្រប់ប្រការស្តីពីការនាំចេញបុរាណវត្ថុ នៅនឹងអាគារលក់ដូររបស់ខ្លួនត្រង់កន្លែងដែលងាយមើលឃើញ ។

ច-បង្ហាញបុរាណវត្ថុទាំងអស់ដែលខ្លួនមានចំពោះភ្នាក់ងារត្រួតពិនិត្យតាមសំណូមពររបស់ភ្នាក់ងារ ។

ឆ-ផ្តល់ទៅភ្នាក់ងារត្រួតពិនិត្យនូវរូបថតបុរាណវត្ថុទាំងឡាយណាក៏ដោយដែលខ្លួនមានឬអនុញ្ញាតឱ្យភ្នាក់ងារនោះ ថតរូបណាមួយដែលគេចង់បាន ។

ជ-បង្កលក្ខណៈងាយស្រួលដល់ភ្នាក់ងារត្រួតពិនិត្យនៅក្នុងពេលធ្វើអធិការកិច្ច ។

ឈ-ជូនពត៌មានដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងករណីដែលមានការប្តូរទីកន្លែងលក់ដូររបស់ខ្លួន។

**មាត្រា ៣៤.–**

ភ្នាក់ងារត្រួតពិនិត្យអាចចូលទៅក្នុងអាគារលក់ដូរ ហើយធ្វើការត្រួតពិនិត្យកត់ត្រាសម្បត្តិវប្បធម៌ដែលមាននៅក្នុងអាគារលក់ទាំងនោះនិងផ្ទៀងផ្ទាត់បញ្ជីនៅគ្រប់ពេលដែលអធិការដ្ឋានយល់ឃើញថាជាការគួរនឹងធ្វើអធិការកិច្ច ។

ភ្នាក់ងារត្រួតពិនិត្យអាចចូលទៅធ្វើការត្រួតពិនិត្យក្នុងលំនៅឋានរបស់ពាណិជ្ជករ បើសិនជាលំនៅឋាននោះត្រូវប្រើធ្វើជាឃ្លាំងឬអាគារលក់ ស្របទៅតាមខ្លឹមសារនៃសេចក្តីអនុញ្ញាតដែលចេញអោយពាណិជ្ជករនោះ ។

**មាត្រា ៣៥.-**

**អាជ្ញាធរមានសមត្ថកិច្ចអាចដកហូតលិខិតអនុញ្ញាតធ្វើពាណិជ្ជកម្មលើបុរាណវត្ថុ ពេលដែលពិនិត្យឃើញម្ចាស់ដែលមានការអនុញ្ញាតនោះធ្វេសប្រហែសឬរំលោភទៅលើកាតព្វកិច្ចណាមួយ ឬដោយសារតែអ្នកនោះបានទទួលការផ្តន្ទាទោសពីតុលាការមានសមត្ថកិច្ចដោយហេតុថា ខ្លួនបានប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃច្បាប់នេះ ។**

**មាត្រា ៣៦.-**

នៅពេលដែលលិខិតអនុញ្ញាតត្រូវបានដកហូត ដូចមានចែងក្នុងបទបញ្ញត្តិនៃមាត្រា ៣៥នោះ ពាណិជ្ជករលែងមានសិទ្ធិទិញបុរាណវត្ថុទៀតហើយ ។

ពាណិជ្ជករនោះនឹងត្រូវអនុញ្ញាតឱ្យលក់បុរាណវត្ថុដែលខ្លួនកំពុងកាន់កាប់នៅឡើយក្នុងរយៈពេលមួយមិនលើសពី ៦ខែ ។

## **ផ្នែកទី ៧**

### ការប្រទះឃើញដោយចៃដន្យ

**មាត្រា ៣៧.-**

នៅពេលកំពុងដំណើរការងារផ្សេងៗឬសកម្មភាពផ្សេងៗទៀត ហើយបានជួបប្រទះសម្បត្តិវប្បធម៌ដូចជាប្រាសាទបាក់បែក វត្ថុបុរាណ សំណល់ផ្ទះសំបែងបុរាណ ទីបញ្ចុះសពបុរាណ សិលាចារឹកឬសម្បត្តិវប្បធម៌ដែលទាក់ទងដល់បុរេប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យា ឬក៏សាខាដទៃទៀតនៃវិទ្យាសាស្ត្រដែលសិក្សាពីអតីតកាលឬមនុស្សសាស្ត្រ អ្នកដែលបានប្រទះឃើញសម្បត្តិទាំងនេះនិងម្ចាស់អចលនវត្ថុ ត្រូវតែបញ្ឈប់ការងារឬសកម្មភាពនោះ រួចរាយការណ៍ជាបន្ទាន់ជូនភ្នាក់ងារនគរបាលក្នុងតំបន់ ។ ភ្នាក់ងារនគរបាលនោះត្រូវបញ្ជូនរបាយការណ៍នេះយ៉ាងប្រញាប់ជូនទៅអភិបាលខេត្ត ក្រុង ។ អភិបាលខេត្ត ក្រុង ត្រូវជូនពត៌មាននេះដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការចាំបាច់ដើម្បីធានាសង្គ្រោះសម្បត្តិវប្បធម៌និងរមណីយដ្ឋានវប្បធម៌នោះ ។

**មាត្រា ៣៨.-**

ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ គិតចាប់តាំងពីថ្ងៃទទួលសេចក្តីរាយការណ៍ដូចមានចែងក្នុងមាត្រា ៣៧ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើកំណត់ជាលាយលក្ខណ៍អក្សរស្តីពីការផ្អាកជាបណ្តោះអាសន្ននូវការងារជួលជុលឬសាងសង់និងស្តីពីវិធានការសង្គ្រោះដែលត្រូវអនុវត្ត ។

បើក្នុងរយៈពេល ៣០ថ្ងៃ អាជ្ញាធរមានសមត្ថកិច្ចមិនបានធ្វើកំណត់ជាលាយលក្ខ័អក្សរជូនជាពត៌មានទៅម្ចាស់អចលនវត្ថុនោះ ការផ្អាកជាបណ្តោះអាសន្នត្រូវទុកជាអាសាបង់ ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវសំរេចជាស្ថាពរនូវវិធានការចំពោះការប្រទះឃើញដោយចៃដន្យ។

**មាត្រា៣៩.-**

សម្បត្តិវប្បធម៌ជាចលនវត្ថុដែលប្រទះឃើញដោយចៃដន្យត្រូវចាត់ទុកជាសម្បត្តិសាធារណៈ។

អាជ្ញាធរមានសមត្ថកិច្ចត្រូវផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកប្រទះឃើញ ដោយចៃដន្យដោយកំណត់តាមការស្រុះស្រួលគ្នាឬតាមការវាយតំលៃរបស់អ្នកជំនាញ ក្នុងរយៈពេលបីសប្តាហ៍ក្រោយពីបានរកឃើញ ។

## ផ្នែកទី ៨

### ការជីករុករកវត្ថុបុរាណ

**មាត្រា ៤០.-**

គ្មានជនណាមួយអាចធ្វើការជីករុករកឬធ្វើការវាស់ស្ទង់លើដីឬក្រោមដី ក្នុងគោលបំណងស្រាវជ្រាវរកសម្បត្តិវប្បធម៌ដែលមានផលប្រយោជន៍ដល់ការសិក្សាខាងបុរេប្រវត្តិវិទ្យា ប្រវត្តិវិទ្យា បុរាណវិទ្យា ជាតិពន្ធុវិទ្យា បាសាណីភូតវិទ្យាឬសាខានៃវិទ្យាសាស្ត្រផ្សេងៗ ដែលសិក្សាពីអតីតកាលឬទាក់ទងដល់មនុស្សសាស្ត្រដោយមិនបានទទួលច្បាប់អនុញ្ញាតិជាមុនពីសមត្ថកិច្ចឡើយ ។

**មាត្រា ៤១.-**

មានតែស្ថាបន័វិទ្យាសាស្ត្រដែលមានជំនាញ មានបទពិសោធន៏និងមានធនធានគ្រប់គ្រាន់ហើយដែលត្រូវបានអាជ្ញាធរមានសមត្ថកិច្ចទទួលស្គាល់ទេ ទើបអាចអនុញ្ញាតិឱ្យធ្វើការរុករកវត្ថុបុរាណបាន ។

ស្ថាប័នវិទ្យាសាស្ត្របរទេសដែលបានទទួលច្បាប់អនុញ្ញាតឱ្យធ្វើការជីករុករក ត្រូវតែសហការជាមួយស្ថាប័នវិទ្យាសាស្ត្រជាតិ ក្នុងការអនុវត្តការងាររបស់ខ្លួន ។

**មាត្រា ៤២.-**

ស្ថាប័នវិទ្យាសាស្ត្រដែលទទួលបានច្បាប់អនុញ្ញាតអោយធ្វើការជីករុករក ត្រូវតែ :

ក-កត់ត្រាសម្បត្តិវប្បធម៌ដែលរកឃើញនៅក្នុងបញ្ជីពិសេសមួយ ហើយត្រូវប្រគល់ជូនដល់អាជ្ញាធរមានសមត្ថកិច្ចនៅពេលបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ខ-ការពារទីលានជីករុករកបុរាណវត្ថុនិងសម្បត្តិវប្បធម៌ដែលរកឃើញ ព្រមទាំងចាត់វិធានការចាំបាច់គ្រប់បែបយ៉ាងដើម្បីថែរក្សានិងការពារ ។

គ-ជូនពត៌មានឱ្យទៀងទាត់ដល់អាជ្ញាធរមានសមត្ថកិច្ច ស្តីពីការប្រព្រឹត្តទៅនៃប្រតិបត្តិការជីករុករកវត្ថុបុរាណ ។

ឃ-ធ្វើរបាយការណ៍សង្ខេបរួមទាំងសៀវភៅរូបថតសម្បត្តិវប្បធម៌ទាំងអស់ដែលបានរកឃើញនៅពេលបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ង-ធ្វើរបាយការណ៍វិទ្យាសាស្ត្រមួយលំអិតស្តីពីលទ្ធផលជីករុករកក្នុងកំណត់មួយមិនហួសពីមួយឆ្នាំ គិតចាប់តាំងពីការបញ្ចប់ដំណាក់កាលជីករុករកនីមួយៗ ។

ច-អនុញ្ញាតឱ្យភ្នាក់ងារនៃអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យមើលការជីករុករកសម្បត្តិវប្បធម៌រាល់តំរូវការរបស់អាជ្ញាធរនោះ ព្រមទាំងពិនិត្យបញ្ជីពិសេសដូចមានចែងក្នុងកថាខ័ណ្ឌ " ក " ។

ឆ-អនុញ្ញាតឱ្យអ្នកស្រាវជ្រាវដទៃទៀតចូលធ្វើការស្រាវជ្រាវ ក្នុងលក្ខខ័ណ្ឌដែលពួកអ្នកស្រាវជ្រាវទាំងនោះសុខចិត្តគោរពសិទ្ធិកម្មសិទ្ធិរបស់ស្ថាប័នវិទ្យាសាស្ត្រនោះ ។

ជ-ជួយអប់រំបណ្តុះបណ្តាលអ្នកបច្ចេកទេស វិទ្យាសាស្ត្រនៅក្នុងស្រុក ។

ឈ-បោះពុម្ពផ្សាយលទ្ធផលវិទ្យាសាស្ត្រស្តីពីការជីករុករកវត្ថុបុរាណដែលធ្វើក្នុងកំឡុងពេលប្រាំឆ្នាំ បន្ទាប់ពីការបញ្ចប់នៃការងារ ។

**មាត្រា ៤៣.-**

ស្ថាប័នវិទ្យាសាស្ត្រដែលបានទទួលការអនុញ្ញាតឱ្យធ្វើការជីករុករកបុរាណវត្ថុ មានសិទ្ធិ

ក-ជាម្ចាស់កម្មសិទ្ធិវិទ្យាសាស្ត្រ ចំពោះវត្ថុដែលបានរកឃើញ ។

ខ-ជាម្ចាស់កម្មសិទ្ធិនៃសម្បត្តិវប្បធម៌ដែលខ្លួនរាចបានទទួលក្នុងល័ក្ខខ័ណ្ឌដែលមានចែង ក្នុងមាត្រា ៤៤ កថាខ័ណ្ឌទី ២ ។

គ-ទទួលអាទិភាពក្នុងការផ្សាយលទ្ធផលវិទ្យាសាស្ត្រនៃការជីករុករកក្នុងល័ក្ខខ័ណ្ឌដែល លទ្ធផលនោះ ត្រូវផ្សាយក្នុងរយៈពេលដូចមានចែងក្នុងមាត្រា ៤២ ចំណុច " ឈ " ។

**មាត្រា ៤៤.-**

សម្បត្តិវប្បធម៌ទាំងចលនវត្ថុនិងអចលនវត្ថុ ដែលបានរកឃើញដោយស្ថាប័នវិទ្យាសាស្ត្រ គឺជាសម្បត្តិសាធារណៈ ។

អាជ្ញាធរមានសមត្ថកិច្ចអាចជូនដល់ស្ថាប័នវិទ្យាសាស្ត្រនេះបាននូវវត្ថុបុរាណមួយដែលដូច គ្នាទាំងស្រុងនិងវត្ថុដែលមានរួចហើយ ព្រមទាំងវត្ថុណាដែលមិនមែនជាវត្ថុចាំបាច់ដោយហេតុថា មាន រក្សាទុករួចហើយនូវវត្ថុដែលមានលក្ខណៈដូចគ្នាបេះបិទនឹងវត្ថុដែលរកឃើញនោះ ទាំងខាងប្រភេទ រចនាបទ វត្ថុធាតុ របៀបផលិត ក៏ដូចជាមានតំលៃខាងវិទ្យាសាស្ត្រឬសិល្បៈ។ ការផ្តល់ជូននេះអាចធ្វើបាន តែក្នុងល័ក្ខខ័ណ្ឌដែលសម្បត្តិវប្បធម៌នេះត្រូវបានយកមកតម្កល់ទុកក្នុងស្ថាប័នវិទ្យាសាស្ត្របច្ចេកទេសសំរាប់ សាធារណជន ។

**មាត្រា ៤៥.-**

អាជ្ញាធរមានសមត្ថកិច្ចធានារ៉ាប់រងត្រួតពិនិត្យការជីករុករកនិងជួយចាត់វិធានការចាំបាច់ ដើម្បីការពារបរិវេណការដ្ឋាននោះ ។

**មាត្រា ៤៦.-**

អាជ្ញាធរមានសមត្ថកិច្ច អាចអនុញ្ញាតអោយធ្វើការជីករុករកនៅលើដីជាកម្មសិទ្ធិឯកជន បន្ទាប់ពីបានជូនដំណឹងជាមុនដល់ម្ចាស់កម្មសិទ្ធិ ។

អ្នកជីករុករកត្រូវធ្វើបញ្ជីសារពើភណ្ឌទីតដីដែលនឹងជីករុករកនោះ ហើយលុះត្រាតែបាន ទទួលការស្រុះស្រួលពីភាគីទាំងអស់ ទើបអាចចាប់ផ្តើមធ្វើការងាររបស់ខ្លួនបាន ។

អ្នកជីករុករកបុរាណវត្ថុត្រូវធ្វើការងារនោះក្នុងរយៈពេលពីរឆ្នាំ ហើយនឹងអាចបន្តទៅ ទៀតបាន ក្រោយរយៈពេលពីរឆ្នាំនេះ ។

**មាត្រា ៤៧.-**

ម្ចាស់កម្មសិទ្ធិ ក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៤៦ មានសិទ្ធិនឹងកាន់កាប់ដីឡើងវិញ និងទទួលបាននូវប្រាក់បំណាច់ចំពោះការខកខានពុំបានស្នាក់អាស្រ័យនៅប្រកបមុខរបរនិងចំពោះការបង់ខាត ឬខូចខាតផ្សេងៗទៀតជាយថាហេតុ ។

**មាត្រា៤៨.-**

ក្នុងករណីដែលប្រទះឃើញសម្បត្តិវប្បធម៌ជាអចលនវត្ថុ អាជ្ញាធរមានសមត្ថកិច្ចអាចប្រើសិទ្ធិដកហូតស្របតាមច្បាប់ស្តីពីការដកហូតកម្មសិទ្ធិ ដោយយោងទៅលើផលប្រយោជន៍សាធារណៈ។

**មាត្រា ៤៩.-**

ក្នុងករណីដែលអ្នកមានច្បាប់អនុញ្ញាតឱ្យធ្វើការជីករុករកបានប្រព្រឹត្តល្មើសនឹងកាតព្វកិច្ចណាមួយដូចមានចែងក្នុងមាត្រា ៤២ អាជ្ញាធរមានសមត្ថកិច្ចអាចសំរេចដកហូតច្បាប់អនុញ្ញាតឬនិងសិទ្ធិលើកម្មសិទ្ធិវិទ្យាសាស្ត្រនោះមកវិញបាន ។

ការជីករុករកត្រូវផ្អាកសកម្មភាពភ្លាម គិតចាប់ពីថ្ងៃដែលបានជូនដំណឹងជាលាយល័ក្ខណ៍អក្សរស្តីពីការដកហូតច្បាប់អនុញ្ញាតមកវិញ ។

**មាត្រា ៥០.-**

នៅពេលដែលច្បាប់អនុញ្ញាតឱ្យធ្វើការជីករុករកត្រូវបានដកហូតមកវិញហើយ អ្នកបានច្បាប់អនុញ្ញាតនោះមិនអាចទាមទារថ្លៃសងជំងឺចិត្តណាមួយ បណ្តាលមកពីការបញ្ឈប់ការរុករកឬសោហ៊ុយដែលខ្លួនបានចំណាយនោះឡើយ ។

## ផ្នែកទី ៩

## ការនាំចេញសម្បត្តិវប្បធម៌

**មាត្រា ៥១.-**

ការនាំចេញសម្បត្តិវប្បធម៌ណាមួយទៅក្រៅដែនដីកម្ពុជាត្រូវហាមឃាត់បើសិនជាគ្មានអាជ្ញាប័ណ្ណពិសេសដើម្បីនាំចេញសម្បត្តិវប្បធម៌ ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចទេនោះ ។

**មាត្រា ៥២.-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញសេចក្តីសំរេចក្នុងរយៈពេលបីខែ គិតចាប់ពីថ្ងៃដែលអ្នកសុំនាំចេញ បានបំពេញទំរង់បែបបទជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់សព្វគ្រប់ហើយ ។

**មាត្រា ៥៣.-**

ការនាំចេញសម្បត្តិវប្បធម៌ត្រូវបង់ពន្ធនិងអាករផ្សេងៗ ។

ការកំរិតប្រាក់ពន្ធនិងអាករលើសម្បត្តិវប្បធម៌ត្រូវកំណត់ដោយច្បាប់ ។

**មាត្រា ៥៤.-**

មុននឹងផ្តល់អាជ្ញាប័ណ្ណនាំចេញណាមួយ អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាអោយបានច្បាស់ថា :

ក-ការនាំចេញនឹងមិនបណ្តាលឱ្យខ្សត់ខ្សោយធនធានបេតិកភណ្ឌវប្បធម៌ជាតិឡើយ។

ខ-សមុច្ច័យសាធារណៈនៅមានសម្បត្តិវប្បធម៌ដែលមានរូបរាងដូចគ្នាទៅនឹងសម្បត្តិ-វប្បធម៌ ដែលត្រូវបានស្នើសុំធ្វើការនាំចេញ ។

គ-សម្បត្តិវប្បធម៌ដែលអនុញ្ញាតឱ្យនាំចេញ មិនមែនជាវត្ថុដែលមានតំលៃខ្ពស់សំរាប់ផ្នែកពិសេសណាមួយនៃការសិក្សាអំពីវិទ្យាសាស្ត្រអតីតកាលឬវិទ្យាសាស្ត្រមនុស្សទូទៅនោះទេ ។ បែបបទនាំចេញសម្បត្តិវប្បធម៌ ប្រភេទសម្បត្តិវប្បធម៌ដែលត្រូវអនុញ្ញាតឱ្យនាំចេញនិងប្រភេទសម្បត្តិវប្បធម៌ដែលមិនអនុញ្ញាតឱ្យនាំចេញ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៥.-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញអាជ្ញាប័ណ្ណសំរាប់ការនាំចេញសម្បត្តិវប្បធម៌ដូចតទៅ :

-សម្បត្តិវប្បធម៌ដែលបានឱ្យដល់ស្ថាប័នវិទ្យាសាស្ត្របរទេស ដែលមានការអនុញ្ញាតឱ្យធ្វើការជីករុករកស្របតាមមាត្រា ៤៤ កថាខ័ណ្ឌទី ២

-សម្បត្តិវប្បធម៌ដែលបញ្ជូនទៅបរទេសសំរាប់មួយរយៈពេល ដើម្បីតាំងពិពរណ៍ឬក្នុងទិសដៅសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ

-សម្បត្តិវប្បធម៌ជាថ្នូរជាមួយសម្បត្តិមកពីសារមន្ទីរឬស្ថាប័នបរទេស

-សម្បត្តិវប្បធម៌នាំចូលស្របច្បាប់មកក្នុងទឹកដីកម្ពុជា

ប៉ុន្តែក្នុងករណីសម្បត្តិវប្បធម៌ដូចរៀបរាប់ក្នុងកថាខ័ណ្ឌទី ១ ត្រង់ចំណុចទី២ នៃមាត្រានេះ ការនាំចេញមួយរយៈពេលត្រូវតែគោរពល័ក្ខខ័ណ្ឌផ្សេងៗ ដើម្បីធានាកុំឱ្យមានការខូចខាតព្រមទាំងការបញ្ជូនមកវិញនូវសម្បត្តិវប្បធម៌ទាំងនោះ ។

**មាត្រា ៥៦.-**

ការប៉ុនប៉ងនាំចេញសម្បត្តិវប្បធម៌ដោយគ្មានអាជ្ញាប័ណ្ណត្រូវឃាត់ទុកនិងរឹបអូសសម្បត្តិ-វប្បធម៌ទាំងនោះ ទុកជាសម្បត្តិសមុច្ច័យសាធារណៈ ។

**មាត្រា ៥៧.-**

អាជ្ញាធរមានសមត្ថកិច្ចអាចទាមទារយករាល់សម្បត្តិវប្បធម៌ដែលមានការទំនាស់មិនឱ្យនាំចេញដោយសារមានហេតុផលសំខាន់ៗផ្សេងធ្វើឱ្យមានការសង្ស័យថាប៉ុនប៉ងនាំចេញដោយខុសច្បាប់។ សម្បត្តិវប្បធម៌ទាំងនេះត្រូវបញ្ចូលជាសម្បត្តិសមុច្ច័យសាធារណៈ ដោយមានការទូទាត់តំលៃតាមការស្រុះស្រួលគ្នា ឬតាមការវាយតំលៃរបស់អ្នកជំនាញការ ។

## ផ្នែកទី ១០

## ការនាំចូលសម្បត្តិវប្បធម៌

**មាត្រា ៥៨.-**

ការនាំចូលសម្បត្តិវប្បធម៌ដែលបាននាំចេញដោយល្មើសនឹងច្បាប់របស់ប្រទេសដើមត្រូវហាមឃាត់ ។ បែបបទនាំចូលសម្បត្តិវប្បធម៌ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥៩.-**

សម្បត្តិវប្បធម៌ដែលនាំចូលដោយខុសច្បាប់ ត្រូវឃាត់ទុកនិងដាក់ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ច ។ ឈរលើគោលការណ៍បដិការ រាជរដ្ឋាភិបាលអាចចេញសេចក្ដីសំរេចប្រគល់សម្បត្តិវប្បធម៌នោះទៅប្រទេសដើមវិញស្របតាមកិច្ចព្រមព្រៀងនិងច្បាប់អន្តរជាតិ ។

**មាត្រា ៦០.-**

ចំណាយដែលពាក់ព័ន្ធទៅនឹងការបញ្ជូនសម្បត្តិវប្បធម៌ទៅវិញ គឺជាបន្ទុករបស់រដ្ឋដែលទាមទារ។

**មាត្រា ៦១.-**

សម្បត្តិវប្បធម៌ដែលនាំចូលស្របច្បាប់ ត្រូវតែប្រកាសជូនដំណឹងដល់ភ្នាក់ងារគយ ។

បង្កាន់ដៃដែលទីចាត់ការគយចេញឱ្យម្ចាស់កម្មសិទ្ធិជាភស្តុតាងនោះ ត្រូវយកមកបង្ហាញភ្នាក់ងារគយឡើងវិញ នៅពេលត្រូវនាំរបស់នោះចេញសាជាថ្មី ។

## ផ្នែកទី ១១

## ទោសប្បញ្ញត្តិ

**មាត្រា ៦២.-**

សេចក្តីសំរេចរបស់រាជ្ជាធរមានសមត្ថកិច្ចដោយយកច្បាប់នេះជាមូលដ្ឋាន អាចបើកលទ្ធភាពឱ្យតវ៉ាបានចំពោះមុខតុលាការ ។

**មាត្រា ៦៣.-**

ក-ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៦ខែ ទៅ ៥ឆ្នាំ ព្រមទាំងពិន័យជាទឹកប្រាក់តាមតម្លៃដែលអ្នកជំនាញបានប៉ាន់ស្មាន ចំពោះជនណាដែលបានប្រព្រឹត្តល្មើសដោយចេតនាឬធ្វេសប្រហែសក្នុងប្រការដូចរៀបរាប់ខាងក្រោមនេះ :

-លក់ឬផ្ទេរកម្មសិទ្ធិ ប្តូរទីតាំង បំផ្លាញចោល ពង្រិចពង្រិល បំផ្លែងរូបរាងឬជួសជុលស្តារឡើងវិញនូវសម្បត្តិវប្បធម៌ដែលបានចុះក្នុងបញ្ជីសារពើភណ្ឌ ដោយមិនបានជូនដំណឹងជាមុន (មាត្រា ២៩ កថាខ័ណ្ឌទី ១) ។

-លក់ឬផ្ទេរកម្មសិទ្ធិសម្បត្តិវប្បធម៌ដែលបានស្នើអោយចាត់ថ្នាក់ឬដែលបានចាត់ថ្នាក់រួចហើយ ( មាត្រា ២១ និង ២៨ កថាខ័ណ្ឌទី ២ ) ។

-ប្តូរទីតាំង បំផ្លាញចោល ពង្រិចពង្រិល បំផ្លែងរូបរាងឬជួសជុលដោយគ្មានការអនុញ្ញាតនូវសម្បត្តិវប្បធម៌ដែលបានស្នើឱ្យចាត់ថ្នាក់ឬដែលបានចាត់ថ្នាក់រួចហើយ(មាត្រា២៣កថាខ័ណ្ឌទី១)។

-មិនបានរក្សាការពារដោយត្រឹមត្រូវនូវសម្បត្តិវប្បធម៌ដែលបានចាត់ថ្នាក់រួចហើយដែលខ្លួនជាម្ចាស់កម្មសិទ្ធិ (មាត្រា ២៥ កថាខ័ណ្ឌទី ១) ។

-ធ្វើឬប៉ុនប៉ងធ្វើដោយគ្មានច្បាប់អនុញ្ញាតនូវការងារទាំងឡាយណាដែលច្បាប់តំរូវឱ្យមានការអនុញ្ញាត ( មាត្រា ៣១ និង ៤០ ) ។

-មិនបានបំពេញកាតព្វកិច្ចដែលត្រូវខ្លួនអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ៣៣ និង ៤២ ។

-មិនបានប្រកាសអំពីការរកឃើញសម្បត្តិវប្បធម៌ នៅក្នុងអំឡុងពេលសាងសង់និងមិនបានបញ្ឈប់ការងារនោះភ្លាម ( មាត្រា ៣៧ ) ។

-នាំចេញឬប៉ុនប៉ងនាំចេញសម្បត្តិវប្បធម៌ដោយគ្មានការអនុញ្ញាត(មាត្រា ៥១ និង ៥៦)។

-មិនអនុវត្តតាមល័ក្ខខ័ណ្ឌកំណត់នៃការនាំចេញមួយរយៈ (មាត្រា ៥៥ កថាខ័ណ្ឌទី ២)។

-នាំចូលសម្បត្តិវប្បធម៌ដោយខុសច្បាប់ ( មាត្រា ៥៨ ) ។

-មិនបានប្រកាសជូនដំណឹងដល់ភ្នាក់ងារគយ អំពីការនាំចូលដោយស្របច្បាប់នូវសម្បត្តិវប្បធម៌ ( មាត្រា ៦១ កថាខ័ណ្ឌទី ១ ) ។

ខ-ជនណាដែលប្រព្រឹត្តបទល្មើសដោយចេតនាដូចចំណុចរៀបរាប់ខាងលើ ត្រូវទទួលទោសជាប់ពន្ធនាគារពី ២ឆ្នាំដល់ ៨ឆ្នាំនិងពិន័យទ្វេគុណនៃតម្លៃសម្បត្តិវប្បធម៌នោះតាមតំលៃដែលអ្នកជំនាញបានប៉ាន់ស្មាន ។

ក្នុងករណីខ្លះដូចមានចែងក្នុងចំណុច(កនិងខ)ខាងលើនេះ ទោសនេះគ្រាន់តែជាប់ពន្ធនាគារឬគ្រាន់តែបង់ប្រាក់ពិន័យ ។

**មាត្រា ៦៤.-**

ទុកបំរុងនៅដែលនូវបទល្មើសពីទោសព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា ៦៣ ពិរុទ្ធបាលដែលបញ្ញត្តិក្នុង មាត្រា ២១ , ២២ , ៣៥ , ៤៩ , ៥៦ , និង ៥៩ ត្រូវតម្កល់ទុកដដែល ។

មាត្រា ៦៥.-

បទល្មើសទាំងឡាយត្រូវចុះក្នុងកំណត់ហេតុដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអាជ្ញាធរមានសមត្ថកិច្ច ជាពិសេសភ្នាក់ងារគយដែលបានធ្វើសម្បថព្រមទាំងដោយមន្ត្រីអភិរក្ស និងបុគ្គលិកដទៃទៀតនៃសារមន្ទីរសាធារណៈ ដែលត្រូវបានចាត់តាំងនិងបានធ្វើសម្បថចំពោះការងារនេះ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

មាត្រា ៦៦.-

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦៧.-

ច្បាប់នេះ ត្រូវប្រកាសជាប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មករា ឆ្នាំ ១៩៩៦

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១និងទី២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ
វប្បធម៌និងវិចិត្រសិល្បៈ រៀបចំ
ទឹកដីនគរូបនីយកម្ម និង សំណង់

**វណ្ណ មូលីវណ្ណ**

# អនុក្រឹត្យ

## ស្តីពីការអនុវត្តកិច្ចការពារ
## បេតិកភណ្ឌវប្បធម៌

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៨ អនក្រ.បក

គណៈកម្មការ APSARA AUTHORITY
នាយកដ្ឋាន ខុទ្ទកាល័យ និង បុគ្គលិក
ចូល លេខៈ 582
ថ្ងៃទី 13-12-02 ម៉ោង 10:15

# អនុក្រឹត្យ

## ស្ដីពី

## ការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌

★★★★★

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១១ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថាអាជ្ញាធរ " អប្សរា "
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩ ស្ដីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរអប្សរា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលក្ខន្តិកគតិយុត្ត

នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល

- បានឃើញព្រះរាជក្រឹត្យលេខ ០០១/នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់ សៀមរាប-អង្គរ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ៩ ខែ សីហា ឆ្នាំ២០០២

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះមានគោលដៅអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដោយកំណត់សម្បត្តិវប្បធម៌ ការជីករុករកវត្ថុបុរាណ បែបបទនៃការធ្វើពាណិជ្ជកម្មលើវត្ថុបុរាណ បែបបទនាំចេញ បែបបទនាំចូល នៃសម្បត្តិវប្បធម៌ ។

## ជំពូកទី ២

## សម្បត្តិវប្បធម៌

**មាត្រា ២.-**

រាប់បញ្ចូលជាបេតិកភណ្ឌវប្បធម៌ផងដែរ គឺជាសម្បត្តិវប្បធម៌ទាំងឡាយ ដែលមានរូបរាង ពិតប្រាកដ ដោយពុំរាប់សម្បត្តិវប្បធម៌ដែលគ្មានរូបរាងពិតប្រាកដនោះទេ ។

**មាត្រា ៣.-**

បេតិកភណ្ឌវប្បធម៌រួមមាន ÷

ក- សម្បត្តិវប្បធម៌កើតមកពីទេពកោសល្យជាបុគ្គល ឬជាសមូហភាពរបស់ជនជាតិខ្មែរ ។

ខ- សម្បត្តិវប្បធម៌ដែលគ្របដណ្តប់សារសំខាន់មួយចំណែករបស់វប្បធម៌ សិល្បៈ ឬប្រវត្តិសាស្ត្រ បង្កបង្កើតឡើងនៅលើទឹកដីជាតិ ដោយជនបរទេស ឬជនគ្មានប្រទេស ពិតប្រាកដ ដែលរស់នៅលើទឹកដីជាតិ ។

គ- សម្បត្តិវប្បធម៌ ដែលរកឃើញនៅក្នុងទឹកដីជាតិ ។

ឃ- សម្បត្តិវប្បធម៌ដែលស្ថាប័នវប្បធម៌ខ្មែរទទួលបាន ដោយមានការយល់ព្រមពីអាជ្ញាធរសមត្ថកិច្ចរបស់ប្រទេសដើមកំណើតរបស់សម្បត្តិនោះ ។

ង- សម្បត្តិវប្បធម៌ដែលជាកម្មវត្ថុនៃការប្តូរគ្នាទៅវិញទៅមក ដោយមានការព្រមព្រៀងគ្នាដោយសេរី ។

ច- សម្បត្តិវប្បធម៌បានមកដោយគ្មានបង់ថ្លៃ ឬមានបង់ថ្លៃ និងមានការយល់ព្រមពីសំណាក់អាជ្ញាធរសមត្ថកិច្ច នៃប្រទេសដើមកំណើតរបស់សម្បត្តិនោះ ។

**មាត្រា ៤.-**

សម្បត្តិវប្បធម៌ គឺជាវត្ថុទាំងឡាយ ជាចលនវត្ថុក្តី ឬអចលនវត្ថុក្តី ដែលចូលក្នុងប្រភេទ ដូចតទៅ៖

ក- សម្បត្តិវប្បធម៌បានមកពីការជីករុករកក្នុងដី និងនៅក្រោមទឹកដែលមានលក្ខណៈស្របច្បាប់ ឬលួចលាក់ហើយ និងវត្ថុបុរាណដែលបានរកឃើញ ។

ខ- សម្បត្តិវប្បធម៌មានលក្ខណបុរេប្រវត្តិ និងប្រវត្តិសាស្ត្រ ដូចជាវិមាន អង្គធាតុចេញមកពីការបំបែកជាផ្នែក១ នៃវិមាន រមណីយដ្ឋាន ទីបញ្ចុះសពបុរាណ សំណល់ភូមិចាស់ រូងភ្នំ និងវត្ថុបុរាណ។

គ- បុរាណវត្ថុដូចជា ឧបករណ៍ប្រើប្រាស់ កុម្ភការភណ្ឌ និងសិលាចារឹក រូបិយវត្ថុបុរាណ ត្រាបុរាណ គ្រឿងអលង្ការបុរាណ អាវុធយុទ្ធភ័ណ្ឌបុរាណ និងសំណល់ឆ្អឹង ។

ឃ- វត្ថុសម្រាប់គោរពបូជា ឬបង្ហាញសារសំខាន់ជាសមូហភាពដែលជាកម្មសិទ្ធិ ឬប្រើប្រាស់ដោយសហគមន៍ជនជាតិ ឬកុលសម្ព័ន្ធ ការប្រើប្រាស់តាមទំនៀមទម្លាប់ ឬប្រពៃណីរបស់សហគមន៍នោះ ។

ង- វត្ថុតាងសម្រាប់នរវិទ្យា និងជាតិពន្ធុវិទ្យា ។

ច- ស្នាដៃសិល្បៈដូចជា :

១- រូបភាព គំនូរ ដែលបង្កើតឡើងដោយដៃទាំងស្រុង នៅលើទម្រទ្រនាប់គ្រប់ប្រភេទ និងធ្វើដោយធាតុផ្សំអ្វីក៏ដោយ លើកលែងតែជាគំនូរឧស្សាហកម្ម និងវត្ថុដែលធ្វើដោយគ្រឿងចក្រ ហើយគូរលំអដោយដៃ ។

២- ច្បាប់ដើមនៃរូបចម្លាក់ ប័ណ្ណប្រកាស និងរូបថតដែលជាមធ្យោបាយនៃការបង្កើតពីដំបូងបង្អស់ ។

៣- ការផ្គុំ និងតម្លើងស្នាដៃសិល្បៈច្បាប់ដើម ធ្វើពីធាតុផ្សំអ្វីក៏ដោយ ។

៤- វត្ថុសិល្បៈអនុវត្តន៍ បញ្ចុះក្នុងធាតុផ្សំ ដូចជា កែវ កុម្ភការភណ្ឌ លោហធាតុ ឬ

ឈើ ។

ឆ- សៀវភៅសរសេរដោយដៃ សៀវភៅបោះពុម្ព ឯកសារ និងឯកសារបោះពុម្ពផ្សាយជាប្រយោជន៍ឯកជន ជាពិសេសដើម្បីវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ និងអក្សរសាស្ត្រ ។

ជ- វត្ថុដែលមានតម្លៃខាងរូបិយវិទ្យា (មេដាយ ឬប្រាក់កាក់) ឬសម្ងហកម្មតែម ។

ឈ-ឯកសាររក្សាទុក រួមទាំងការថតសម្លេងអត្ថបទ ផែនទី និងសម្ភារៈដទៃទៀតដែលទាក់ទងនឹងផែនទី រូបថតហ្វីលកុន ការថតសម្លេង និងឯកសារអានដោយម៉ាស៊ីន (ហ្វូណូក្រាម) ។

ញ- វត្ថុសម្រាប់គ្រឿងតុតាំង គ្រឿងប៉ាក់ កម្រាលព្រំ សាច់ក្រណាត់បុរាណជាសូត្រ សម្លៀកបំពាក់បុរាណ និងឧបករណ៍ភ្លេងបុរាណ ។

ដ- បដិរូបរបស់សត្វ រុក្ខជាតិ និងថ្មបុរាណ ។

## ជំពូកទី ៣
## អំពីពាណិជ្ជកម្មសម្បត្តិវប្បធម៌
### ផ្នែកទី ១
### បែបបទសុំការយល់ព្រម

**មាត្រា ៥.-**

ពាណិជ្ជកម្មសម្បត្តិវប្បធម៌ គឺរាល់សកម្មភាពលក់ ឬដូរ ក្នុងលក្ខណៈជារបស់ខាន់ ឬជំនួញបន្ទាប់បន្សំ និងជាប់លាប់នូវសម្បត្តិវប្បធម៌ ។

ពាណិជ្ជករសម្បត្តិវប្បធម៌ គឺជាបុគ្គលទាំងឡាយណា ទោះជារូបវន្តបុគ្គលក្តី ឬជានីតិបុគ្គលក្តី ដែលប្រកបរបរដូចមានចែងនៅវាក្យខ័ណ្ឌខាងលើ ទោះជាអ្នកនោះ មានគ្រឹះស្ថានសម្រាប់លក់ ឬប្រកបមុខរបរនោះនៅនឹងផ្ទះ និវេសនដ្ឋាន ឬនៅលើដីកម្មសិទ្ធិរបស់រដ្ឋក៏ដោយ ។

រាប់បញ្ចូលជាពាណិជ្ជករដែរ បុគ្គលណាដែលរៀបចំចាត់ចែងពិធីមួយនៅទីសាធារណៈ ឬទីកន្លែងដែលបើកឱ្យសាធារណជនចូល លក់ ឬដូរសម្បត្តិវប្បធម៌ ដូចជា ពិព័រណ៍ ពិព័រណ៍វត្ថុបុរាណ ពិធីផ្សារណាត់ ការលក់ឡាយឡុង ឬផ្សារហ៊ុន ។

**មាត្រា ៦.-**

បុគ្គលទាំងឡាយណាទោះជារូបវន្តបុគ្គលក្តី ឬជានីតិបុគ្គលក្តី ដែលមានបំណងធ្វើពាណិជ្ជកម្មសម្បត្តិវប្បធម៌ ត្រូវដាក់ពាក្យសុំការយល់ព្រមពីក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដែលមានក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាស្ថាប័នប្រតិបត្តិ ។

**មាត្រា ៧.-**

ការដាក់ពាក្យសុំការយល់ព្រម ត្រូវមានភ្ជាប់នូវសេចក្តីចម្លងនៃការចុះបញ្ជីពាណិជ្ជកម្ម និងលិខិតយុត្តិការនានាផ្សេងទៀត។

គំរូនៃពាក្យសុំដែលត្រូវយកទៅប្រើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ៨.-**

ការយល់ព្រម គឺសម្រាប់តែបុគ្គលស្នើសុំ ហើយពុំអាចផ្ទេរទៅឱ្យតតិយជនបានឡើយ ។

ការយល់ព្រមនេះត្រូវបានចេញឱ្យសម្រាប់រយៈពេល១(មួយ)ឆ្នាំ ហើយអាចនឹងចេញឱ្យសារជាថ្មីបាន ។

ពាណិជ្ជករដែលប្រកបរបររកស៊ីទៅតាមករណីយកិច្ចសាស្ត្ររបស់របរ ហើយពុំដែលបានទទួលទណ្ឌកម្មរដ្ឋបាល ឬព្រហ្មទណ្ឌ ពីបទល្មើសទាក់ទងនឹងកិច្ចការពារបេតិកភណ្ឌវប្បធម៌ ក្នុងរយៈពេលយ៉ាង តិច៥ (ប្រាំ)ឆ្នាំ អាចទទួលបានការយល់ព្រមជាស្វ័យប្រវត្តិ ដោយពុំចាំបាច់ដាក់ពាក្យបន្ត សុំពីមួយឆ្នាំទៅ មួយឆ្នាំ ។ ប៉ុន្តែបែបបទរដ្ឋបាលត្រូវតែបំពេញតាមការណែនាំរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ៩.-**

ពាណិជ្ជករអាចចាប់ផ្តើមប្រកបរបររបស់ខ្លួនបាន ក្រោយពេលបានទទួលសេចក្តីជូនដំណឹងស្តីពីការ យល់ព្រម ។

## ផ្នែកទី ២
## ភាតព្វកិច្ចរបស់ពាណិជ្ជករ និងបញ្ជីសម្បត្តិវប្បធម៌

**មាត្រា ១០.-**

ក្រៅពីកាតព្វកិច្ចដូចមានចែងក្នុងមាត្រា៣៣ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ រាល់ពាណិជ្ជករមានកាតព្វកិច្ចដូចតទៅនេះ ÷

ក- ត្រូវធ្វើបញ្ជីប្រចាំថ្ងៃនូវសម្បត្តិវប្បធម៌ ដែលខ្លួនទិញចូល ដូរ ឬត្រូវបានផ្ញើទុកឱ្យលក់ ឬដូរ។ ក្នុងករណីដែលមានគ្រឹះស្ថាន ឬសាខាលក់ច្រើន គ្រឹះស្ថាន ឬសាខានីមួយៗ ត្រូវធ្វើបញ្ជីរបស់ខ្លួនផ្ទាល់ ។

ខ- មិនត្រូវទិញចូល ដើម្បីយកមកលក់ ឬដូរនូវសម្បត្តិវប្បធម៌ណាដែលមកពីប្រភព ឬមនុស្សគួរឱ្យសង្ស័យ ឬក៏ម្ចាស់របស់នោះ ពុំមានអត្តសញ្ញាណពិតប្រាកដ ។

គ- មិនត្រូវទទួលចូល ដោយគ្មានបង់ថ្លៃ ឬដោយបង់ថ្លៃនូវសម្បត្តិវប្បធម៌ពីជន ដែលមានទីតិសម្បទាមិនត្រឹមត្រូវ ដោយគ្មានការយល់ព្រមពីឪពុកម្តាយ ឬពីអ្នកតំណាងស្របច្បាប់

របស់គេឡើយ ។

ឃ- ត្រូវជូនព័ត៌មានដល់អ្នកទិញអំពីលក្ខណសម្បត្តិរបស់វត្ថុនោះ ក្នុងករណីលក់ ឬដូរវត្ថុដែលបានចុះក្នុងបញ្ជីសារពើភណ្ឌ ដោយស្នើឱ្យធ្វើចំណាត់ថ្នាក់ ឬមានចំណាត់ថ្នាក់ និងផ្តល់ឱ្យអាជ្ញាធរត្រួតពិនិត្យនូវអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នកទិញ ព្រមទាំងកាលបរិច្ឆេទនៃការផ្ទេរកម្មសិទ្ធិ ។

ង- ត្រូវធានាចំពោះការបញ្ជាក់របស់ខ្លួន ទាក់ទងទៅនឹងប្រភេទ សមាសភាគ ដើមកំណើត និងអាយុរបស់វត្ថុដែលបានលក់ ឬដូរដោយផ្តល់ឱ្យអ្នកទិញ នូវលិខិតបញ្ជាក់ត្រឹមត្រូវ បើសិនជាគេស្នើសុំ ។

ច- ត្រូវជូនដំណឹងទៅក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អំពីការផ្លាស់ប្តូរទីកន្លែងរបស់គ្រឹះស្ថានលក់ដូររបស់ខ្លួន ។ សម្រាប់គ្រឹះស្ថានដែលប្រកបរបរជានីតិបុគ្គល កាតព្វកិច្ចទាំងឡាយដូចមានរៀបរាប់ខាងលើជាបន្ទុករបស់អ្នកដឹកនាំនីតិបុគ្គលនោះ ។

**មាត្រា ១១.-**

បញ្ជីសម្បត្តិវប្បធម៌ ត្រូវមានចុះព័ត៌មានដូចតទៅ ÷

ក- ការពិពណ៌នាសព្វគ្រប់អំពីវត្ថុនីមួយៗ ដោយមានចុះលក្ខណៈសំខាន់ៗ ដែលមើលឃើញ ព្រមទាំងឈ្មោះ ហត្ថលេខា អក្សរ លេខ បដិរូប និងសញ្ញា គ្រប់យ៉ាងដែលមាននៅលើវត្ថុនោះ ហើយដែលអាចសំគាល់វត្ថុនោះបាន ។

ខ- គោត្តនាម នាម មុខងារ និងអាសយដ្ឋានរបស់អ្នកលក់ ឬអ្នកយកឥវ៉ាន់មកផ្ញើទុកឱ្យលក់ ព្រមទាំង ប្រភេទ លេខ កាលបរិច្ឆេទ ដោយមានការបញ្ជាក់បង្ហាញពី អាជ្ញាធរដែលបានចេញអត្តសញ្ញាណប័ណ្ណ ក្នុងករណីមានការលក់ ការដូរ ឬផ្ញើទុកឱ្យលក់ ។

គ- លេខរៀងរបស់សម្បត្តិវប្បធម៌នីមួយៗ ។

ឃ- ថ្លៃទិញ ឬប៉ាន់ស្មាន ក្នុងករណីការដូរទទួលទុកឱ្យលក់ ឬបានមកដោយឥតបង់ថ្លៃ ។

ង- ចុះបញ្ជីសារពើភណ្ឌ ឬចំណាត់ថ្នាក់ឱ្យបានត្រឹមត្រូវ ។

**មាត្រា ១២.-**

បញ្ជីត្រូវចុះលេខរៀង និងហត្ថលេខាសង្ខេប ដោយមន្ត្រីសមត្ថកិច្ចរបស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ។ បញ្ជីអាចបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យាបាន ក្នុងល័ក្ខខ័ណ្ឌដែលបញ្ជីមានសន្លឹកបន្តបន្ទាប់ មិនអាចដោះចេញបាន ហើយមានការចុះលេខរៀង និងហត្ថលេខាសង្ខេបពីមន្ត្រីសមត្ថកិច្ច នោះជាមុន ។

**មាត្រា ១៣.-**

ព័ត៌មានដែលចុះក្នុងសៀវភៅបញ្ជីនោះ ត្រូវប្រើទឹកខ្មៅដែលលុបចេញមិនបាន គ្មានសល់ ចន្លោះ គ្មានកោសលុប ឬអក្សរកាត់ឡើយ ។

**មាត្រា ១៤.-**

សៀវភៅបញ្ជីត្រូវរក្សាទុកដោយពាណិជ្ជកររយៈពេល៥ ( ប្រាំ ) ឆ្នាំ គិតចាប់ពីថ្ងៃបិទបញ្ជី ។

**មាត្រា ១៥.-**

គំរូសៀវភៅបញ្ជីរបស់សម្បត្តិវប្បធម៌ ដែលបានកាន់កាប់ ឬផ្ញើទុកឱ្យ លក់ ឬដូរមានដាក់ភ្ជាប់មកនៅក្នុងឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៦.-**

ការត្រួតពិនិត្យសៀវភៅបញ្ជី ជាសមត្ថកិច្ចរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

## ជំពូកទី ៤

## ការជីករុករកវត្ថុបុរាណ

### ផ្នែកទី ១

### លក្ខណៈទូទៅនៃការជីករុករក

**មាត្រា ១៧.-**

ការជីករុករកវត្ថុបុរាណ គឺជាការស្រាវជ្រាវទាំងឡាយដែលមានទំនោរទៅរកវត្ថុបុរាណ ឬ សម្រាប់ការសិក្សាសម្បត្តិវប្បធម៌ ឬរមណីយដ្ឋានបុរាណ ទោះជាការស្រាវជ្រាវនោះមានធ្វើកំណាយ ឬការរុករកដោយគ្មានចន្លោះនៃផ្ទៃដីខាងលើ ឬការស្រាវជ្រាវនោះត្រូវធ្វើនៅលើស្រទាប់ដីខាងលើ ឬនៅ ស្រទាប់ដីខាងក្រោមទឹកនៅក្នុងប្រទេស ឬទឹកសមុទ្រ ក្រោមការត្រួតត្រារបស់ប្រទេស ។

មិនរាប់បញ្ចូលជាការរុករកវត្ថុបុរាណ ក្នុងន័យដែលប្រើក្នុងវាក្យខ័ណ្ឌខាងដើម ទម្រ និងជញ្ជាំងការពារដែលបានទទួលស្គាល់ថា ជាការចាំបាច់សម្រាប់សុវត្ថិភាពរបស់សម្បត្តិ និងបុគ្គល ឬក៏សម្រាប់រក្សាទុកកុំឱ្យខូចខាតជាបណ្ដោះអាសន្ន សំណល់ដែលរកឃើញដោយចៃដន្យ និងក្នុងពេលរង់ចាំអន្តរាគមន៍ របស់អង្គភាពទទួលបន្ទុកការពារបេតិកភណ្ឌវប្បធម៌ ។

**មាត្រា ១៨.-**

រាជរដ្ឋាភិបាលកម្ពុជាអាចផ្ដល់ការអនុញ្ញាតបានដល់ស្ថាប័នជាតិ និងអន្តរជាតិ ឱ្យធ្វើការជីករុករកតាមវិធីសាស្ត្រត្រឹមត្រូវ និងស្រទាប់ភូគព្ភសាស្ត្រនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ១៩.-**

ការអនុញ្ញាតឱ្យធ្វើការជីករុករកវត្ថុបុរាណត្រូវបានសម្រេចដោយ ÷

ក- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្នុងនាមក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ សម្រាប់ព្រះរាជាណាចក្រកម្ពុជា លើកលែងតែតំបន់សៀមរាបអង្គរ ។

ខ- អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ( អប្សរា )ចំពោះតំបន់សៀមរាបអង្គរ ។

**មាត្រា ២០.-**

ការអនុញ្ញាតឱ្យធ្វើកំណាយ គឺជាការអនុញ្ញាតផ្ទាល់ ដែលមិនអាចផ្ទេរទៅឱ្យអង្គការវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិណាមួយផ្សេងទៀតបានឡើយ ។

**មាត្រា ២១.-**

ក្នុងកិច្ចការពិនិត្យលិខិតសុំអនុញ្ញាតជីករុករកលើដីឯកជនណាមួយ អាជ្ញាធរសមត្ថកិច្ចមូលដ្ឋាន ត្រូវដឹងឮ ហើយជូនដំណឹងដល់ម្ចាស់ដី ។

**មាត្រា ២២.-**

មិនរាប់បញ្ចូលក្នុងដែនអនុវត្តនៃជំពូកនេះទេ នូវទីតាំងសាសនា ដែលជាកម្មវត្ថុនៃការគោរពបូជាជានិច្ចកាល ដូចជា វត្តអារាម ចេតិយ ដំបូកអ្នកតា ឬដើមពោធិរហូតដល់ចុងបំផុតនៃមែក ។

ការវាស់ស្ទង់អាចនឹងធ្វើទៅបាននៅក្នុងបរិវេណវត្តអារាម ក្រៅព្រំដែននៃទីសក្ការៈបូជា ឬពេលណាមានតម្រុយ និងការសង្កេតឃ៉ានលេខា ឬប្រពៃណីស្របគ្នាប្រាប់ឱ្យដឹងពីភាពត្រួតគ្នានៃវត្តសម័យថ្មីមួយ និងសំណង់បុរាណមួយដោយមានការយល់ព្រមពីអាជ្ញាធរសមត្ថកិច្ច ឬគណៈកម្មការវត្តដោយពុំរាប់បញ្ចូលក្នុងដែនអនុវត្តនៃជំពូកនេះដែរ កន្លែងកប់ខ្មោចសាធារណៈ ឬឯកជនលើកលែងតែព្រៃស្មសាន ។ ក្នុងករណីនេះស្ថាប័នដែលមានការអនុញ្ញាតឱ្យធ្វើការជីករុករកវត្ថុបុរាណ ត្រូវតែមានការស្រុះស្រួលគ្នាជា មុនជាមួយក្រុមគ្រួសារ ឬបើគ្មានក្រុមគ្រួសារទេ ជាមួយនឹងអាជ្ញាធរសមត្ថកិច្ចមូលដ្ឋាន ចំពោះបែបបទ នៃការជីករុករក និងការទូទាត់សងការខូចខាតជាយថាហេតុ ។

## ផ្នែកទី ២
## បែបបទអនុវត្ត

**មាត្រា ២៣.-**

រាល់ពាក្យសុំការអនុញ្ញាតជីករុករកវត្ថុបុរាណ ត្រូវភ្ជាប់មកនូវឯកសារដោយភាគខ្លះ ឬទាំងអស់ ដោយយោលទៅតាមករណីដូចតទៅ–

ក- កម្មវិធីវិទ្យាសាស្ត្រ រាប់បញ្ចូលទាំងរបាយការណ៍ស្តីពីកាលានុវត្តភាពនៃប្រតិបត្តិការ ហើយ និងលទ្ធផលនានាដែលរំពឹងទុកចំនួនមួយច្បាប់ ។

ខ- ការពិពណ៌នាគម្រោងនៃការជីករុករកដែលបង្ហាញ និងបញ្ជាក់ពីវិធីនៃការស្រាវជ្រាវដែលបានគ្រោងទុក ។

គ- ប័ណ្ណហិរញ្ញវត្ថុដែលបញ្ជាក់ចំនួនទឹកប្រាក់សរុបនៃប្រតិបត្តិការ ប្រភពនៃហិរញ្ញប្បទាន និងការធានាដែលទាក់ទងទៅនឹងប្រតិបត្តិការនោះ ។

ឃ- សលាកប័ត្របច្ចេកទេសដែលបញ្ជាក់ពីចំនួនបុគ្គលិកធ្វើការ មធ្យោបាយសម្ភារៈដែលត្រូវប្រើប្រាស់ទីកន្លែងទុកដាក់ នៅពេលបញ្ចប់ការដ្ឋានរយៈពេលរបស់ការដ្ឋាន ។

ង- វិធានការការពារទ្រព្យសម្បត្តិ និងមនុស្សដែលត្រូវភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់នៃការធានាទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ។

ច- ប្រាក់ធានារបស់ស្ថាប័នវិទ្យាសាស្ត្រជាតិ ឬអន្តរជាតិដែលត្រូវបានគេទទួលស្គាល់ ។

ឆ- ប្លង់ដីស្តីពីបរិវេណដែលស្ថិតនៅក្រោមសិទ្ធិជីករុករក ដោយមានព្រំដែនកំណត់ ដោយមានសេចក្តីបញ្ជាក់របស់សុរិយោដីនៃក្បាលដី និងនាមម្ចាស់កម្មសិទ្ធិ និងអ្នកកាន់កាប់ក្បាលដីមួយច្បាប់ ។

ជ- ប្លង់កំណត់បរិវេណសម្រាប់ធ្វើការវាស់ស្ទង់ ហើយនិងគំនូរពំនូសកាត់នៃស្រទាប់ស្តាសាស្ត្រ ឬស្រទាប់ភូគព្ភសាស្ត្រមួយច្បាប់ ។

ឈ- ប្លង់បញ្ជាក់ទីតាំងការដ្ឋានផ្ទៃក្រឡាសម្រាប់ចំណាត់ថ្នាក់ និងទីតាំងស្តុកអាចម៍ដីមួយច្បាប់ ។

**មាត្រា ២៤.-**

ដោយបង្ហាញលិខិតអនុញ្ញាតឱ្យជីករុករកវត្ថុបុរាណ ស្ថាប័នអាចសុំឱ្យអាជ្ញាធរសមត្ថកិច្ចប្រគល់ ឱ្យបាននូវសម្រង់បញ្ជីសុរិយោដី ប្លង់ភូមិបាល និងវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុនៅក្នុងបញ្ជីដីធ្លី សម្រាប់ធ្វើការជីករុករកវត្ថុបុរាណដែលបានគ្រោងទុក ។

**មាត្រា ២៥.-**

អាជ្ញាធរសមត្ថកិច្ច ត្រូវបញ្ជូនសេចក្តីចម្លងនៃលិខិតអនុញ្ញាតឱ្យជីករុករកមួយច្បាប់ជូនទៅ អាជ្ញាធរខេត្ត ក្រុង និងមូលដ្ឋានពាក់ព័ន្ធជ្រាបជាព័ត៌មាន ។ អាជ្ញាធរខេត្ត ក្រុង ត្រូវជូនព័ត៌មាននេះ ទៅម្ចាស់កម្មសិទ្ធិសាធារណៈ ឬឯកជនអំពីអចលនទ្រព្យនោះ ព្រមទាំងធ្វើការផ្សព្វផ្សាយដោយ បិទប្រកាសនូវទីតាំងពាក់ព័ន្ធនេះ ។

ស្ថាប័នត្រូវផ្តល់ឱ្យអាជ្ញាធរខេត្ត ក្រុង និងមូលដ្ឋាននូវបែបបទអនុវត្ត ក្នុងការដ្ឋានដែលបានគ្រោងក្នុងលិខិតអនុញ្ញាតឱ្យជីករុករក ។

**មាត្រា ២៦.-**

ចាប់ពីពេលធ្វើសេចក្តីជូនដំណឹងស្តីពីការអនុញ្ញាតមក ដីដែលស្ថិតនៅក្នុងបរិវេណកំណត់ការងារគ្រប់ប្រភេទធ្វើដោយនីតិបុគ្គល ឬរូបវន្តបុគ្គលក្រៅពីស្ថាប័នដែលបានរៀបរាប់នៅក្នុងលិខិតអនុញ្ញាត ត្រូវបានហាមឃាត់ ។

**មាត្រា ២៧.-**

ស្ថាប័នត្រូវហ៊ុំរបងព័ទ្ធការដ្ឋាន និងសុំឱ្យតំណាងស្វាមិភោគីខេត្ត ក្រុង ធ្វើការស្រង់ស្ថានភាពដី នៅចំពោះមុខតំណាងស្ថាប័ន ។

**មាត្រា ២៨.-**

ដោយមានការយល់ព្រមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្ថាប័នអាចឆ្ការព្រៃគម្លោចកាប់ដើមឈើ បើកផ្លូវថ្មើរជើង ឬផ្លូវចេញចូលសម្រួលការងារការដ្ឋាន បាននៅក្នុងបរិវេណកំណត់ ។

**មាត្រា ២៩.-**

ស្ថាប័នមានភារកិច្ច ធ្វើយុទ្ធនាការជីករុករកឱ្យទាល់តែចប់ ហើយត្រូវបំពេញដីឱ្យដូចដើមវិញ ក្នុងរយៈពេលកំណត់ ។

**មាត្រា ៣០.-**

ក្នុងករណីដែល ការជីករុករកបានប្រទះឃើញវត្ថុដែលមានសារៈសំខាន់ វត្ថុទាំងនោះត្រូវរក្សាឱ្យនៅដូចដើមក្រោយពីធ្វើការសិក្សារួចហើយ ។ មុនការពិនិត្យរកវិធានការការពារដែលត្រូវយកមកប្រើ អនុលោមតាមច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ស្ថាប័នអាចធ្វើការពង្រឹងវត្ថុនោះ ជាបណ្តោះអាសន្នបាន ។ អាជ្ញាធរមូលដ្ឋាន និងខេត្ត ក្រុង ព្រមទាំងម្ចាស់កម្មសិទ្ធិសាធារណៈ ឬឯកជនត្រូវទទួល បន្ទុកថែរក្សាវត្ថុទាំងនោះ រហូតដល់មានការអនុម័តវិធានការការពារ ។

**មាត្រា ៣១.-**

រាល់ការរកឃើញដោយចៃដន្យនូវផ្នូរខ្មោចថ្មី ត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋាន ខេត្ត ក្រុង នៃទីកន្លែងដែលប្រទះឃើញ ។

អាជ្ញាធរមូលដ្ឋានត្រូវប្រគល់សិទ្ធិ នៅក្នុងរយៈពេលសមស្របទៅឱ្យនាយនគរបាលម្នាក់ ដើម្បីទទួលបន្ទុកធ្វើកំណត់ហេតុ ស្វែងរកគ្រួសារជាយថាហេតុ ហើយនិងធ្វើការបញ្ជាក់ពីការបញ្ចុះធាតុ ទៅវិញនៅក្នុងផ្នូរមួយដ៏សមរម្យ ។

## ផ្នែកទី៣
## ភារកិច្ច

**មាត្រា ៣២.-**

មុននឹងចាប់ផ្ដើមប្រតិបត្តិការជីករុករក ស្ថាប័នត្រូវយកព័ត៌មានពីអាជ្ញាធរមូលដ្ឋាន និងយកចិត្តទុកដាក់លើប្រពៃណីទំនៀមទម្លាប់ទាក់ទងទៅនឹងទីកន្លែង និងគោរពទម្លាប់របស់ព្រះរាជាណាចក្រកម្ពុជា ជាពិសេសអ្វីដែលទាក់ទងនឹងសាសនា ។

ស្ថាប័នជាអ្នកទទួលបន្ទុកចំពោះការខូចខាតដែលបង្កដល់មនុស្ស និងទ្រព្យសម្បត្តិ ក្នុងរយៈពេល នៃការអនុញ្ញាតនោះ ។

ស្ថាប័នបរទេសត្រូវរួមជាមួយស្ថាប័នវិទ្យាសាស្ត្រខ្មែរមួយ ឬច្រើនក្នុងដំណើរការរបស់ខ្លួន ។ ស្ថាប័នបរទេសត្រូវបណ្ដុះបណ្ដាលអ្នកបច្ចេកទេស និងអ្នកវិទ្យាសាស្ត្រខ្មែរ ក្នុងក្របខ័ណ្ឌនៃការងារ ជីករុករកហើយដោយមានការយល់ព្រមពីអាជ្ញាធរសមត្ថកិច្ច អាចអញ្ជើញស្ថាប័នវិទ្យាសាស្ត្របរទេស ឬបុគ្គលិកវិទ្យាសាស្ត្រ រដ្ឋបាល ឬបច្ចេកទេសរាប់បញ្ចូលទាំងជំនួយការអាហារូបករណ៍ និងនិស្សិតបរទេស ឱ្យមកជួយបាន ។

**មាត្រា ៣៣.-**

នាយកស្ថាប័នវិទ្យាសាស្ត្រជីករុករក ត្រូវទទួលខុសត្រូវចំពោះការអនុវត្តការជីករុករកទៅតាមវិធានសិល្បៈ និងវិន័យបុគ្គលិកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន ។ មានតែនាយកស្ថាប័នតែមួយគត់ ដែលមានអំណាចផ្ទាល់ទៅលើអ្នកដែលនៅក្រោមឱវាទរបស់ខ្លួនទាំងអស់ ហើយអាចផ្ទេរ សមត្ថកិច្ចនេះ ឱ្យទៅតែសមាជិកនៃបុគ្គលិកវិទ្យាសាស្ត្ររបស់ស្ថាប័នម្នាក់តែប៉ុណ្ណោះ ។

នាយកស្ថាប័ន ត្រូវជូនដំណឹងទៅអាជ្ញាធរសមត្ថកិច្ច ពីការរកឃើញប្រាសាទទាំងមូល រមណីយដ្ឋានបុរេប្រវត្តិសាស្ត្រ ឬទីលានប្រវត្តិសាស្ត្រ ដែលតម្រូវឱ្យមានវិធានការការពារអនុលោម ទៅតាមច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ទោះជាការរុករកនៅក្រោមដី ក្រោមទឹក ឬខាងលើ ផ្ទៃដីក្ដី ។

**មាត្រា ៣៤.-**

អាជ្ញាធរជាតិ ខេត្ត ក្រុង និងមូលដ្ឋានត្រូវជួយ និងផ្ដល់ជំនួយខាងធនធានមនុស្សដល់ស្ថាប័នណា ដែលស្នើសុំជំនួយអន្តរាគមន៍ពីអាជ្ញាធរសមត្ថកិច្ចដទៃទៀត ។

អាជ្ញាធរសមត្ថកិច្ចត្រូវត្រួតពិនិត្យដំណើរការអនុវត្តការជីករុករកទាំងឡាយឱ្យបាន ។ ក្នុងកិច្ចការនេះអាជ្ញាធរត្រូវចាត់តាំងតំណាងម្នាក់ឱ្យនៅអមស្ថាប័ន ។ តំណាងនេះមានសិទ្ធិជួយដល់ រាល់ប្រតិបត្តិការជីករុករក ឬចុះបញ្ជី ហើយនិងធ្វើការត្រួតពិនិត្យកិច្ចការទាំងនោះ នៅក្នុងព្រំដែន កំណត់នៃមុខងាររបស់ខ្លួន។ តំណាងនេះគ្មានសមត្ថកិច្ចណែនាំសមាជិក និងភ្នាក់ងាររបស់ស្ថាប័នទេ ។

## ផ្នែកទី ៤
## កម្មសិទ្ធិវិទ្យាសាស្ត្រ និងការបង់កម្រៃ

**មាត្រា ៣៥.-**

ស្ថាប័នរក្សាកម្មសិទ្ធិវិទ្យាសាស្ត្រនៃកម្មវត្ថុ ដែលខ្លួនរកឃើញក្នុងល័ក្ខខ័ណ្ឌដែលស្ថាប័ននោះ បានធ្វើការផ្សព្វផ្សាយលទ្ធផលវិទ្យាសាស្ត្រនៃការជីករុករកក្នុងរយៈពេល៥( ប្រាំ) ឆ្នាំ បន្ទាប់ពីការបញ្ចប់ការជីក រុករក ។

សិទ្ធិផលិតឡើងវិញតាមបែបទេវកថាធិប្បាយ ឬសិទ្ធិផ្សព្វផ្សាយនៅក្នុងសៀវភៅវិទ្យាសាស្ត្រ អាចធ្វើបានដោយសេរី បន្ទាប់ពីការផ្សព្វផ្សាយលទ្ធផលវិទ្យាសាស្ត្រនៃការជីករុករក ។

**មាត្រា ៣៦.-**

លើសពីរយៈពេល៥( ប្រាំ) ឆ្នាំ ដូចមានចែងនៅក្នុងមាត្រា៣៥នៃអនុក្រឹត្យនេះ អាជ្ញាធរសមត្ថកិច្ចអាចផ្តល់ការអនុញ្ញាតឱ្យធ្វើការផ្សព្វផ្សាយបាន ក្នុងគោលបំណងធ្វើពាណិជ្ជកម្ម ដោយមានការបង់ប្រាក់ កម្រៃដែលគិតទៅតាមចំនួនសៀវភៅដែលបានបោះពុម្ព ។

ក្នុងករណីថតស្នាដៃសោតទស្សន៍ អាជ្ញាធរសមត្ថកិច្ចកំណត់កម្រៃម៉ោសរុបមួយគិតទៅតាមថេរវេលាថត និងរយៈពេលនៃស្នាដៃ ។

ចំនួនទឹកប្រាក់នៃកម្រៃត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៣៧.-**

ហិរញ្ញប្បទាននៃរាល់ប្រតិបត្តិការជីករុករកវត្ថុបុរាណ ដូចជា ការវាស់ស្ទង់សាកល្បង ការរុករក ការជីករុករក ការដឹកជញ្ជូន ប្រាក់បៀវត្សកម្មករ បុគ្គលិកគ្រប់គ្រង ឬការអនុរក្ស ការបណ្តុះបណ្តាល បុគ្គលិកមូលដ្ឋានជាបន្ទុករបស់ស្ថាប័ន ។

## ផ្នែកទី ៥
## ការចុះបញ្ជី និងការប្រគល់ផលិតផលបានមកពីការជីករុករក

**មាត្រា ៣៨.-**

ស្ថាប័នត្រូវកត់ត្រាជាប្រចាំក្នុងបញ្ជីជីករុករក ដែលត្រូវមានបញ្ជីសារពើភណ្ឌជាផ្លូវការនៃវត្ថុ ដោយឡែកឬបណ្តាវត្ថុដែលរកឃើញនៅពេលធ្វើការជីករុករក ។

កាតព្វកិច្ចនេះ មិនសំដៅជាពិសេសទៅលើកាកសំណល់រឹង គំរូសំណាករ៉ែ ឬឈើ គំរូសំណាកដី បំណែកកុម្ភការភណ្ឌ ឬកែវដែលគ្មានលក្ខណៈសំខាន់ និងឆ្អឹងមនុស្ស ឬសត្វ សំបកខ្យងខ្ចៅ ហើយនិងរាល់ សន្ទស្សន៍

ឬវត្ថុតាងទាំងឡាយនៃផ្ទះសម្បែងបុរាណដែលត្រូវពឹងផ្អែកធ្វើពិសោធន៍ ក្នុងករណីដូចគ្នានេះ ការជីករុករកគ្មានគោលបំណងធ្វើការសិក្សាលើវត្ថុនោះទេ ។

**មាត្រា ៣៩.-**

ក្នុងករណីដែលមានការរុករកវត្ថុ ដែលមានសារៈសំខាន់ផ្នែកប្រវត្តិសាស្ត្រ សិល្បៈ វប្បធម៌ វិទ្យាសាស្ត្របុរាណវិទ្យា ឬជាប្រាក់កាស ស្ថាប័នត្រូវធ្វើកំណត់ហេតុភ្ជាប់ជាមួយសៀវភៅបញ្ជីនៃ ការជីករុករក ។

ពុំត្រូវមានការអនុញ្ញាតឱ្យប្រគល់វត្ថុទាំងនោះទៅអ្នកណា ឬកន្លែងណាទេ មុនពេលធ្វើការសិក្សា ផ្នែកវិទ្យាសាស្ត្ររួច ។

**មាត្រា ៤០.-**

ក្នុងករណីការជីករុករកវត្ថុបុរាណជាលក្ខណៈស្រោចស្រង់ ដែលត្រូវបានធ្វើហិរញ្ញប្បទាន ទាំងស្រុង ឬមួយចំណែកដោយម្ចាស់គម្រោង អាជ្ញាធរសមត្ថកិច្ចអាចជូនរង្វាន់ទៅម្ចាស់គម្រោងនោះបាន ។ រង្វាន់ជាទឹកប្រាក់ ឬជាវត្ថុ ត្រូវកំណត់ដោយការយោគយល់គ្នា ឬតាមការវាយតម្លៃរបស់អ្នកឯកទេស ។

**មាត្រា ៤១.-**

អាជ្ញាធរសមត្ថកិច្ចអាចប្រគល់ឱ្យទៅស្ថាប័នបានទទួលផលិតផល នៃការជីករុករកវត្ថុបុរាណ ដែលបានគ្រោងទុកហើយដែលមានពីរដូចគ្នា ឬមានចំនួនច្រើននៅក្នុងសមុច្ច័យសាធារណៈ ។

ស្ថាប័នត្រូវជូនដំណឹងទៅអាជ្ញាធរសមត្ថកិច្ច អំពីការប្រគល់ជាស្ថាពរនូវវត្ថុបុរាណដែលកម្មសិទ្ធិ ត្រូវបានផ្ទេរមកឱ្យខ្លួន ។ ស្ថាប័នអាចផ្ទេរ ឬលក់វត្ថុបុរាណទាំងនោះ ដោយគិតថ្លៃ ឬមិនគិតថ្លៃ តែក្នុងករណីបម្រើប្រយោជន៍ សមុច្ច័យសាធារណៈប៉ុណ្ណោះ ។

**មាត្រា ៤២.-**

ស្ថាប័នអាចបន្តការសិក្សា និងការវិភាគវត្ថុបុរាណ ដែលជាកម្មសិទ្ធិរបស់ព្រះរាជាណាចក្រកម្ពុជា បានទោះជាវត្ថុទាំងនោះទុកនៅកន្លែងណាក៏ដោយ ក្នុងល័ក្ខខ័ណ្ឌមិនធ្វើឱ្យមានការខូចខាតលើវត្ថុ ទាំងនោះ ។

ស្ថាប័នរក្សាសិទ្ធិចាក់ពុម្ព ឬរូបថត ដើម្បីប្រយោជន៍វិទ្យាសាស្ត្រ ។ ក្នុងករណីនេះ អាជ្ញាធរ សមត្ថកិច្ចត្រូវផ្តល់ឱ្យស្ថាប័ននូវលេខយោងនៅក្នុងបញ្ជីសារពើភណ្ឌ ។

## ជំពូកទី ៥

## អំពីការនាំចេញ និងការនាំចូលសម្បត្តិវប្បធម៌

### ផ្នែកទី ១

### បែបបទនៃការនាំចេញ

**មាត្រា ៤៣.-**

ដោយអនុលោមតាមមាត្រា៥១ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ សម្បត្តិវប្បធម៌ ត្រូវបានហាមឃាត់មិនឱ្យធ្វើការនាំចេញ លើកលែងតែមានអាជ្ញាប័ណ្ណពិសេស។ សម្បត្តិវប្បធម៌ទាំងនោះ គឺជាវត្ថុបុរាណទាំងឡាយ ដែលបានរាប់បញ្ចូលក្នុងប្រភេទនៃសម្បត្តិវប្បធម៌ ដែលមានរៀបរាប់ក្នុង មាត្រា៤ នៃអនុក្រឹត្យនេះ នៅក្នុងថ្ងៃដែលដាក់ពាក្យសុំ ។

**មាត្រា ៤៤.-**

អាជ្ញាប័ណ្ណពិសេសជាស្ថាពរ ឬជាបណ្តោះអាសន្ន សម្រាប់ធ្វើការនាំចេញសម្បត្តិវប្បធម៌ ត្រូវចេញដោយរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ៤៥.-**

រាល់ពាក្យសុំអាជ្ញាប័ណ្ណនាំចេញសម្បត្តិវប្បធម៌ ត្រូវដាក់ជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយម្ចាស់សម្បត្តិផ្ទាល់ ឬអាណត្តិគាហក ។

ពាក្យសុំត្រូវធ្វើតាមលំនាំទម្រង់ ដែលមានចែងនៅឧបសម្ព័ន្ធ II ដោយមានភ្ជាប់នូវឯកសារ និងព័ត៌មានដូចតទៅ ÷

ក- ការពិពណ៌នាអំពីសម្បត្តិវប្បធម៌លម្អិតល្មមអាចសម្គាល់បានដោយជាក់លាក់ ។

ខ- រូបថតរបស់សម្បត្តិវប្បធម៌មួយសន្លឹក ឬសំណៅថតចម្លង បើសិនសម្បត្តិវប្បធម៌នោះជាឯកសារ ។

គ- បង្កាន់ដៃចេញឱ្យដោយរដ្ឋាករគយ កាលបើសម្បត្តិវប្បធម៌នោះ ត្រូវបាននាំចូលមកកម្ពុជាដោយស្របច្បាប់ ។

ឃ- តម្លៃលក់សម្បត្តិវប្បធម៌នៅទីផ្សារកម្ពុជា ឬបរទេស ក្នុងករណីនាំចេញជាស្ថាពរ។

ង- ថ្លៃលក់នៃសម្បត្តិវប្បធម៌ បើជាសម្បត្តិដែលត្រូវបានលក់រួចហើយ ហើយត្រូវនាំចេញជាស្ថាពរ ។

ច- គោលបំណងនៃការនាំចេញ ។

ឆ- ទីកន្លែងទទួលសម្បត្តិវប្បធម៌ ។

ជ- ថ្ងៃ ខែ គ្រោងទុកនៃការនាំចេញ។

ឈ- ថ្ងៃ ខែ ប្រហាក់ប្រហែលនៃការវិលត្រឡប់មកកម្ពុជាវិញនៃសម្បត្តិវប្បធម៌ ក្នុងករណីការនាំចេញមិនមែនស្ថាពរ ។

**មាត្រា ៤៦.-**

បើអ្នកដាក់ពាក្យសុំពុំមានផ្តល់ព័ត៌មានទាំងអស់ និងលិខិតយុត្តិការដែលបានតម្រូវនោះទេ រដ្ឋមន្ត្រី

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទាមទារឱ្យបំពេញបន្ថែមនូវឯកសារខ្វះខាត ដោយលិខិតអនុសិដ្ឋ ដែលសុំឱ្យមានការចុះហត្ថលេខាទទួលមុនការផុតកំណត់នៃរយៈពេលបីខែ ដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពី កិច្ចការពារបេតិកភណ្ឌវប្បធម៌ ។ រយៈពេលនោះអាចពន្យាបាន ។ អ្នកដាក់ពាក្យសុំមាន រយៈពេល២(ពីរ)ខែ ចាប់ពីថ្ងៃទទួលលិខិតរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដើម្បីជូនព័ត៌មាន និងលិខិត ដែលត្រូវបានទាមទារ ។ អ្នកដាក់ពាក្យសុំដែលពុំផ្តល់ឯកសារទាំងនោះ ក្នុងរយៈពេលកំណត់នោះទេ ត្រូវបានចាត់ទុកថា បានបោះបង់ពាក្យសុំរបស់ខ្លួន ។

**មាត្រា ៤៧.-**

រយៈពេលដូចមានចែងក្នុងមាត្រា៥២ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ក៏ត្រូវបានពន្យាពេល ក្នុងករណីដូចតទៅ ÷

ក- បើរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយអនុវត្តទៅតាមមាត្រា៤៩នៃអនុក្រឹត្យនេះ ទាមទារឱ្យមានការបង្ហាញសម្បត្តិវប្បធម៌ ដើម្បីធ្វើការពិនិត្យ។ ក្នុងករណីនេះ ការពន្យាចាប់គិតពីថ្ងៃដែលអ្នកដាក់ពាក្យសុំបានទទួលលិខិតអនុសិដ្ឋរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលទាមទារឱ្យបង្ហាញសម្បត្តិវប្បធម៌នោះ។

ខ- បើយថាភាពនៃសម្បត្តិវប្បធម៌ត្រូវបានជំទាស់នៅតុលាការ។ ការពន្យាពេលត្រូវមានរហូតដល់ពេលដែលអ្នកដាក់ពាក្យសុំបញ្ជូនសេចក្តីសម្រេចបញ្ចប់បណ្តឹងរបស់តុលាការទៅរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

គ- បើរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ទាមទាររកភស្តុតាងនៃភាពស្របច្បាប់នៃការនាំចូលសម្បត្តិវប្បធម៌ ការពន្យាពេលចាប់ផ្តើមពីកាលបរិច្ឆេទនៃការទទួលលិខិតអនុសិដ្ឋពីរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈដែលទាមទាររកភស្តុតាងរហូតដល់ថ្ងៃផ្តល់ភស្តុតាងនោះ។

**មាត្រា ៤៨.-**

បើសម្បត្តិវប្បធម៌មានសារសំខាន់ពិសេស ខាងផ្នែកប្រវត្តិសាស្ត្រ សិល្បៈ ឬបុរាណវិទ្យា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចប្រគល់ឱ្យក្រុមការងារឯកទេសដែលមានសមាសភាពយ៉ាង ច្រើន៥(ប្រាំ)នាក់ ទទួលបន្ទុកវាយតម្លៃប៉ះពាល់ដល់បេតិកភណ្ឌវប្បធម៌ជាតិ បើមានការនាំចេញនូវ សម្បត្តិវប្បធម៌នោះ ។ ក្រុមអ្នកឯកទេសត្រូវសម្រេចលើតម្លៃវប្បធម៌របស់សម្បត្តិវប្បធម៌ដោយយកលក្ខណវិនិច្ឆ័យ ដូចមានរៀបរាប់នៅក្នុងមាត្រា៥៤ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌មក ពិចារណា ។ ក្រុមអ្នកឯកទេសត្រូវដាក់របាយការណ៍ ហើយនិងអនុសាសន៍ជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**មាត្រា ៤៩.-**

បើសំណុំរឿងតម្រូវឱ្យមានការសិក្សា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចសុំឱ្យបង្ហាញ សម្បត្តិវប្បធម៌នៅកន្លែងមួយ តាមការកំណត់ដោយរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

**មាត្រា ៥០.-**

អាជ្ញាប័ណ្ណនាំចេញត្រូវប្រគល់ឱ្យអ្នកដាក់ពាក្យសុំ ក្រោយពីមានការបង់ពន្ធដូចមានចែងក្នុង មាត្រា៥៣ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដោយចេញបង្កាន់ដៃឱ្យភ្លាម ឬបញ្ជូនឱ្យទៅតាមលិខិតអនុសិដ្ឋ ដោយមានសុំឱ្យចុះហត្ថលេខាទទួល ។

ការបង់ពន្ធលើការនាំចេញសម្បត្តិវប្បធម៌សម្រាប់ការតាំងពិព័រណ៍ ការជួសជុលឡើងវិញ ឬ សម្រាប់គោលបំណងវិទ្យាសាស្ត្រដទៃទៀត ត្រូវសម្រេចដោយរាជរដ្ឋាភិបាល ។

**មាត្រា ៥១.-**

បើរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មិនយល់ព្រមចេញអាជ្ញាប័ណ្ណឱ្យទេ រដ្ឋមន្ត្រីត្រូវ ជូនដំណឹងពីសេចក្តីសម្រេចនេះ ទៅម្ចាស់របស់សម្បត្តិវប្បធម៌នោះ តាមលិខិតអនុសិដ្ឋដោយមានសុំឱ្យ ចុះហត្ថលេខាទទួល ទោះជាពាក្យសុំត្រូវបានដាក់ជូនដោយអាណត្តិគាហកក៏ដោយ ។

ក្នុងករណីដែលគ្មានអាសយដ្ឋាន និងអត្តសញ្ញាណរបស់ម្ចាស់សម្បត្តិវប្បធម៌ រដ្ឋមន្ត្រីក្រសួង វប្បធម៌ និងវិចិត្រសិល្បៈត្រូវឱ្យគេសុំទៅអាណត្តិគាហក តាមរយៈលិខិតអនុសិដ្ឋដោយសុំឱ្យមានការចុះ ហត្ថលេខាទទួល ។ រយៈពេលដូចមានចែងនៅមាត្រា៥២ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ត្រូវបានព្យួរមួយរយៈពេលចាប់ពីថ្ងៃអាណត្តិគាហកបានទទួលលិខិតពីរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ សិល្បៈរហូតដល់ថ្ងៃផ្តល់ព័ត៌មាន ។

**មាត្រា ៥២.-**

ក្នុងករណីមានការនាំចេញដោយបន្លំនូវសម្បត្តិវប្បធម៌ ហើយដែលការនាំចេញនោះមិនត្រូវបានទទួលការយល់ព្រម រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈអាចទាមទារយកសម្បត្តិវប្បធម៌នោះបានទុកជាប្រយោជន៍របស់សមុច្ច័យសាធារណៈអនុលោមទៅតាមមាត្រា៥៧ នៃច្បាប់ស្តីពីកិច្ចការពារ បេតិកភណ្ឌវប្បធម៌ ។

ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវស្នើតម្លៃទិញមួយទៅម្ចាស់សម្បត្តិវប្បធម៌នោះ ។

**មាត្រា ៥៣.-**

ការស្នើតម្លៃទិញដែលផ្ញើតាមលិខិតអនុសិដ្ឋ ដោយតម្រូវឱ្យមានការចុះហត្ថលេខាទទួលត្រូវសរសេរបញ្ជាក់ក្រៅពីថ្លៃប៉ាន់ស្មាននៃសម្បត្តិវប្បធម៌នោះ ក៏ត្រូវបញ្ជាក់បន្ថែមអំពីព័ត៌មានផ្សេងៗទាក់ទង នឹងថ្លៃប្រៀបធៀបសម្បត្តិវប្បធម៌ប្រហាក់ប្រហែល ដែលមាននៅលើផ្សារជាតិ និងអន្តរជាតិ ប្រសិនជា មាន ឬបើគ្មានទេ លិខិតស្នើតម្លៃទិញត្រូវរៀបរាប់អំពីកត្តាប្រៀបធៀបផ្សេងៗ ដែលអាចបញ្ជាក់ពី ភាពត្រឹមត្រូវនៃថ្លៃប៉ាន់ស្មាន

ក្នុងលិខិតអនុសិដ្ឋស្នើទិញនោះ ។

ម្ចាស់សម្បត្តិវប្បធម៌មានរយៈពេល២(ពីរ)ខែ ដើម្បីនឹងឆ្លើយតប ។ រយៈពេលនេះចាប់ផ្តើមពីពេលបានស្នើទិញ ។ ការពុំមានការឆ្លើយជាលាយលក្ខណ៍អក្សរពីសំណាក់ម្ចាស់សម្បត្តិវប្បធម៌ ក្នុងរយៈពេលកំណត់ត្រូវចាត់ទុកថាពុំយល់ព្រមនឹងសំណើ ។

ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងម្ចាស់សម្បត្តិវប្បធម៌ត្រូវជ្រើសរើសអ្នកឯកទេសម្នាក់ទទួលបន្ទុកប៉ាន់ស្មានតម្លៃសម្បត្តិវប្បធម៌នោះ ។

សម្បត្តិវប្បធម៌នោះត្រូវបង្ហាញដល់អ្នកឯកទេស ។

រដ្ឋជាអ្នកទទួលបន្ទុកលើសោហ៊ុយអ្នកឯកទេស ។

## ផ្នែកទី ២

## ការនាំចេញដោយខុសច្បាប់

### មាត្រា ៥៤.-

បើមានសម្បត្តិវប្បធម៌ណាមួយត្រូវបានធ្វើការនាំចេញដោយខុសច្បាប់ ទោះជាបណ្តោះអាសន្នក្តី ឬស្ថាពរក្តី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានភារកិច្ចចាត់ចែងរាល់ដំណើរការផ្លូវទូត រដ្ឋបាល និងតុលាការ ដើម្បីធ្វើឱ្យ សម្បត្តិវប្បធម៌នោះបានវិលត្រឡប់មកមាតុភូមិវិញ ។

រដ្ឋមន្ត្រីត្រូវបំពេញក្នុងនាមរដ្ឋ ឬម្ចាស់សម្បត្តិវប្បធម៌នូវសកម្មភាពផ្លូវទូត រដ្ឋបាល ឬតុលាការ ផ្សេងទៀត ដែលមានគ្រោងនៅក្នុងសន្ធិសញ្ញាទ្វេភាគី ឬអនុសញ្ញាអន្តរជាតិផ្សេងទៀត រួមទាំងអនុសញ្ញាអ៊ុយនីដ្រូឆ្នាំ១៩៩៥ ស្តីពីសម្បត្តិវប្បធម៌ដែលត្រូវបានគេលួច ឬធ្វើការនាំចេញដោយខុសច្បាប់ ។

### មាត្រា ៥៥.-

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវជូនដំណឹងដល់សាធារណជន អំពីដំណើរការដែលបានធ្វើឱ្យមានការវិលត្រឡប់មកមាតុភូមិវិញនូវសម្បត្តិវប្បធម៌នោះ ។ សាធារណជនក៏ត្រូវដឹងពីលទ្ធផល នៃការដោះស្រាយដែរ ប្រសិនបើមាន ។

### មាត្រា ៥៦.-

បើមានការសម្រេចឱ្យបង្វិលសម្បត្តិវប្បធម៌មកវិញ ហើយសំណងដែលរដ្ឋជាអ្នកទទួលបន្ទុកត្រូវបានចេញឱ្យទៅអ្នកកាន់កាប់ដោយសុទ្ធចិត្តរួចហើយ ការចេញសងនេះគ្មានព្យសនកម្មដល់សិទ្ធិចាប់ឱ្យសងថ្លៃចំណាយរបស់រដ្ឋដោយបុគ្គលផ្សេងទៀតឡើយ ។

**មាត្រា ៥៧.-**

រដ្ឋជាអ្នកតម្កល់ទុកនូវសម្បត្តិវប្បធម៌ដែលទទួលបានមកវិញ ហើយអាចដាក់តាំងនៅសារមន្ទីរជាតិ រហូតដល់ពេលប្រគល់ទៅឱ្យម្ចាស់ដើមវិញ បន្ទាប់ពីមានការសម្រេចលើកម្មសិទ្ធិរបស់សម្បត្តិវប្បធម៌ នោះ ។

**មាត្រា ៥៨.-**

សម្បត្តិវប្បធម៌ដែលទទួលបានមកវិញ នឹងអាចប្រគល់ឱ្យម្ចាស់ដើមវិញបាន លុះត្រាតែ អ្នកនោះ÷

ក- សងសោហ៊ុយដែលរដ្ឋបានចេញទាំងអស់មកវិញ ជាអាទិ៍មានសោហ៊ុយទៅលើសំណងទៅឱ្យអ្នកទិញដោយសុទ្ធចិត្ត សោហ៊ុយលើវិធានការរក្សាទុក សោហ៊ុយលើការអនុវត្តសេចក្តីសម្រេចបង្គាប់ឱ្យបង្វិលសម្បត្តិវប្បធម៌មកវិញ និងសោហ៊ុយលើការតម្កល់ទុកដូចមានចែងនៅមាត្រា៥៦ នៃអនុក្រឹត្យនេះ ។

ខ- ពុំមែនជាអ្នកធ្វើការនាំចេញខុសច្បាប់ដោយខ្លួនឯងនោះទេ ។

បើម្ចាស់សម្បត្តិវប្បធម៌ជាបុគ្គលសាធារណៈ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អាចទាមទារមុននឹងប្រគល់សម្បត្តិវប្បធម៌ជូនវិញបាន ឱ្យមានវិធានការចាំបាច់សម្រាប់រក្សា និងការពារសម្បត្តិ វប្បធម៌នោះសិន ។ បើមិនដូច្នេះទេ ក្រោយពីមានការដាក់កំហិតដែលមិនព្រមធ្វើតាមក្នុងរយៈពេល២(ពីរ)ឆ្នាំ រដ្ឋមន្ត្រីអាចសម្រេចយកសម្បត្តិវប្បធម៌នោះបាន ទៅដាក់នៅកន្លែងមួយ ដែលផ្តល់នូវការធានាសុវត្ថិភាព ចាំបាច់គ្រប់បែបយ៉ាង ។

**មាត្រា ៥៩.-**

កម្មសិទ្ធិសម្បត្តិវប្បធម៌ដែលទទួលបានមកវិញត្រូវធ្លាក់ទៅលើរដ្ឋ ប្រសិនបើអត្តសញ្ញាណរបស់ម្ចាស់នៃទ្រព្យនោះ នៅតែមិនស្គាល់អស់រយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដែលរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រ-សិល្បៈ បានជូនដំណឹងទៅសាធារណជនអនុលោមតាមមាត្រា៥៦ នៃអនុក្រឹត្យនេះ ។

## ផ្នែកទី ៣

## អំពីការនាំចូលសម្បត្តិវប្បធម៌

**មាត្រា ៦០.-**

រាល់សម្បត្តិវប្បធម៌ដែលនាំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែប្រកាសនៅអង្គភាពគយ និងរដ្ឋាករ នាមាត់ច្រកនាំចូលអនុលោមតាមមាត្រា៦១ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ។

សម្បត្តិវប្បធម៌ត្រូវមានភ្ជាប់មកជាមួយនូវលិខិតអនុញ្ញាតនាំចេញ ដែលចេញដោយអាជ្ញាធរ សមត្ថកិច្ចរបស់ប្រទេសដើម ឬឯកសារផ្សេងទៀត ដែលបញ្ជាក់ពីភាពស្របច្បាប់នៃការនាំចេញ ។

ត្រូវចាត់ទុកថាបាននាំចូលដោយខុសច្បាប់នូវសម្បត្តិវប្បធម៌ដែលធ្វើការនាំចូលប្រទេសកម្ពុជា ដោយ

គ្មានការប្រកាសនៅទីចាត់ការគយ និងរដ្ឋាករ ឬសម្បត្តិវប្បធម៌ ដែលត្រូវបានគេលួច ហើយបញ្ចូលមកក្នុងប្រទេសកម្ពុជាដោយបន្លំ ។

**មាត្រា ៦១.-**

នៅពេលមានសំណើសុំច្បាស់លាស់ និងពិស្តារពីប្រទេសដើមកំណើត រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ត្រូវរក ឬឱ្យគេរកសម្បត្តិវប្បធម៌ ដែលនាំចូលដោយខុសច្បាប់នៅក្នុងប្រទេសកម្ពុជា ។

**មាត្រា ៦២.-**

នៅពេលដែលបានស្គាល់ច្បាស់របស់ប្រទេសដើមកំណើតនៃសម្បត្តិវប្បធម៌ ដែលបាននាំចូល ដោយខុសច្បាប់ត្រូវបានស្គាល់ហើយ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវជូនព័ត៌មានទៅប្រទេស ដើមនោះតាមផ្លូវទូតអំពីវត្តមានរបស់សម្បត្តិវប្បធម៌នោះ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៦៣.-**

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងទីចាត់ការគយ និងរដ្ឋាករ ត្រូវចាត់វិធានការចាំបាច់គ្រប់បែបយ៉ាង ដើម្បីឃាត់ទុកសម្បត្តិវប្បធម៌ ដែលធ្វើការនាំចូលដោយខុសច្បាប់ ។

**មាត្រា ៦៤.-**

សម្បត្តិវប្បធម៌ទាំងឡាយ ដែលបានឃាត់ទុកត្រូវតម្កល់ទុកនៅសារមន្ទីរជាតិ ដែលជាអ្នកធានា ការពារ និងមានវិធានការគ្រប់បែបយ៉ាង ដើម្បីរក្សាសម្បត្តិវប្បធម៌នោះ ។

**មាត្រា ៦៥.-**

រដ្ឋជាអ្នកសុំតវ៉ាបញ្ជូនពាក្យសុំបង្វិលសម្បត្តិវប្បធម៌ ដែលធ្វើការនាំចូលខុសច្បាប់តាមផ្លូវទូតមករដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលជាអ្នកមានវិធានការគ្រប់បែបយ៉ាង ដើម្បីធានាការវិលត្រឡប់សម្បត្តិវប្បធម៌មកប្រទេសដើមវិញ ។

សកម្មភាពនេះត្រូវធ្វើឡើងកុំឱ្យមានការប៉ះពាល់ដល់សកម្មភាពរដ្ឋបាល ឬតុលាការផ្សេងទៀត ដែលរដ្ឋអ្នកសុំ ឬម្ចាស់សម្បត្តិវប្បធម៌មានសិទ្ធិធ្វើ ។

**មាត្រា ៦៦.-**

ត្រូវផ្តល់សិទ្ធិឱ្យដូចគ្នាដែរ ចំពោះការសុំវិលត្រឡប់វិញសម្បត្តិវប្បធម៌ ដូចមានចែងក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងទ្វេភាគី ឬអនុសញ្ញាអន្តរជាតិផ្សេងទៀត ជាពិសេសអនុសញ្ញាអ៊ុយនីដ្រូា ឆ្នាំ១៩៩៥ ស្តីពីសម្បត្តិវប្បធម៌ដែលត្រូវគេលួច ឬធ្វើការនាំចេញខុសច្បាប់ ។

**មាត្រា ៦៧.-**

ការវិលត្រឡប់នៃសម្បត្តិវប្បធម៌កើតឡើង នៅពេលមានការចេញសងចំណាយពាក់ព័ន្ធទាំងអស់ ពីរដ្ឋអ្នកសុំរួមបញ្ចូលទាំងចំណាយនៅពេលធ្វើការឃាត់ទុក ការតម្កល់ទុកនៅសារមន្ទីរជាតិ និង វិធានការរក្សាទុក

បើសិនជាមាន ។

**មាត្រា ៦៨.-**

សម្បត្តិវប្បធម៌ដែលត្រូវបានធ្វើការនាំចូលដោយខុសច្បាប់ ហើយគ្មានការទាមទារឱ្យបង្វិលទៅវិញ ក្នុងរយៈពេលកំណត់ដោយច្បាប់ជាតិ ឬអន្តរជាតិត្រូវរឹបអូសទុកទៅជាសម្បត្តិរបស់រដ្ឋ ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**មាត្រា ៦៩.-**

បើពាណិជ្ជករសម្បត្តិវប្បធម៌ណាម្នាក់ មិនគោរពកាតព្វកិច្ចណាមួយរបស់ខ្លួន ដែលមានចែងក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ និងមាត្រា៣៣នៃច្បាប់ការពារបេតិកភណ្ឌ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ មានសិទ្ធិផ្អាកការអនុញ្ញាតនេះជាបណ្តោះអាសន្ន ក្នុងករណីមិនរៀងចាលត្រូវបញ្ឈប់ ការអនុញ្ញាតប្រកបអាជីវកម្មនេះជាស្ថាពរ ។

**មាត្រា ៧០.-**

បើស្ថាប័នជាអ្នកទទួលការអនុញ្ញាតឱ្យជីករុករកវត្ថុបុរាណ បានប្រព្រឹត្តផ្ទុយនឹងកាតព្វកិច្ចរបស់ខ្លួនដូចមានចែងក្នុងជំពូកទី៤នៃអនុក្រឹត្យនេះ អាជ្ញាធរសមត្ថកិច្ចកម្រិតទោសទៅតាមទម្ងន់នៃបទល្មើស÷

ក- ដកសិទ្ធិនៃកម្មសិទ្ធិវិទ្យាសាស្ត្រ នៃផលិតផលការជីករុករកវត្ថុបុរាណ ។

ខ- ដកការអនុញ្ញាតឱ្យជីករុករក ។

គ- មិនចេញការអនុញ្ញាតជាថ្មីឱ្យជីករុករករយៈពេលអតិបរមា៥ ( ប្រាំ) ឆ្នាំ ។

## ជំពូកទី ៧

## ការធានាឱ្យមាននីតិវិធីតវ៉ា

**មាត្រា ៧១.-**

សេចក្តីសម្រេចដែលចែងក្នុងអនុក្រឹត្យនេះ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយត្រូវបង្ហាញហេតុផល និងផ្លូវតវ៉ា ព្រមទាំងរយៈពេលដែលអាចប្តឹងតវ៉ា ។

**មាត្រា ៧២.-**

រាល់សេចក្តីសម្រេចដែលធ្វើឡើងអនុលោមតាមអនុក្រឹត្យនេះ ត្រូវតែជូនដំណឹងទៅបុគ្គលពាក់ព័ន្ធទាំងឡាយ ។

## ជំពូកទី ៨

## អន្តរប្បញ្ញត្តិ

**មាត្រា ៧៣.-**

រាល់ពាណិជ្ជករដែលបានប្រកបរបររបស់ខ្លួនមុនអនុក្រឹត្យចូលជាធរមាន ត្រូវសម្របសម្រួល សកម្មភាពអាជីវកម្ម តាមបទប្បញ្ញត្តិទាំងឡាយនៃអនុក្រឹត្យនេះ ឱ្យបានក្នុងរយៈពេល១២ខែ គិតចាប់តាំងពីថ្ងៃចូលជាធរមាន ។

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៧៤.-**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ អាជ្ញាធរអប្សរា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ដូចមាត្រា ៧៥
- ឯកសារ-កាលប្បវត្តិ

1/3

ឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យលេខ .....៩៨......អនក្រ.បកចុះថ្ងៃទី.១៧......ខែតុលា....ឆ្នាំ២០០២

(មាត្រា ១៦)

## គំរូសៀវភៅចុះបញ្ជី

| លេខរៀង | ថ្ងៃខែទិញ ឬ តម្កល់ទុក ឬ ដោះដូរ | ការពិពណ៌នាច្បាស់លាស់អំពីសម្បត្តិ ( ប្រភេទ ទំហំ រចនាបទ ហត្ថលេខា និង សញ្ញាពិសេស ប្រសិនជាមាន) | នាម គោត្តនាម ឬនាមកររបស់ អ្នកលក់ អ្នកតម្កល់ទុក អ្នកទទួលដោះ - ដូរ ឋានៈ ឬ មុខរបរ អាសយដ្ឋាន ឬ ទីស្នាក់ការ | ប្រភេទ និង លេខរៀង នៃ អត្តសញ្ញាណ-ប័ណ្ណបង្ហាញ ។ ការបង្ហាញ អាជ្ញាធរដែល បានចេញឱ្យ និងថ្ងៃខែការ ចេញឱ្យ | ថ្ងៃទិញ ឬ តម្លៃបាន់ស្មានជា ទឹកប្រាក់ | បើសិនជា មាន សេចក្តី សម្រេចចុះ ក្នុងបញ្ជី សារពើភណ្ឌ សំណើ ឬ សេចក្តីសម្រេច ចំណាត់ថ្នាក់ |
|---|---|---|---|---|---|---|
| | | | | | | |

2/3

ឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យលេខ ..៩៨.........អនក្រ.បក ចុះថ្ងៃទី.១៦......ខែ.កញ្ញា....ឆ្នាំ២០០២
(មាត្រា ៤៥)

**ព្រះរាជាណាចក្រកម្ពុជា**
**ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

## ពាក្យសុំអាជ្ញាប័ណ្ណនិរាករណកម្មសម្បត្តិវប្បធម៌

| |
|---|
| លេខយោង : |
| ថ្ងៃ ខែ : |

| | |
|---|---|
| អ្នកដាក់ពាក្យសុំ | នាម និងគោត្តនាម :<br>អាសយដ្ឋាន :<br>ទូរស័ព្ទ :<br>របៀបទទួលសំបុត្រ : |
| ម្ចាស់ ( បើសិនមិនមែនជាអ្នកដាក់ពាក្យសុំ ) | នាម និងគោត្តនាម :<br>អាសយដ្ឋាន :<br>ទូរស័ព្ទ :<br>របៀបទទួលសំបុត្រ : |

| ព័ត៌មានពាក់ព័ន្ធ នឹងសម្បត្តិវប្បធម៌ | | | |
|---|---|---|---|
| ការពិពណ៌នាលម្អិតនៃសម្បត្តិ ១/ចំនួន ២/ពិពណ៌នា ៣/រូបថត ឬសំណៅចម្លង ៤/តម្លៃពាណិជ្ជកម្ម ឬថ្លៃលក់ | | | |
| ១/ | ២/<br><br>បើចន្លោះនេះមិនគ្រប់គ្រាន់ សូមបន្ថែមមួយ ឬច្រើនសន្លឹកទៀត | ៣/ | ៤/ |

3/3

| |
|---|
| ព័ត៌មានពាក់ព័ន្ធនឹងការនាំចេញ |
| ការនាំចេញជាបណ្តោះអាសន្ន |
| គោលបំណងនៃការនាំចេញ :<br>❑ ការតាំងពិព័រណ៌ ❑ ការស្តាបនាឡើងវិញ ❑ អភិរក្ស<br>❑ ការបញ្ជាក់តាមយថាភូត ❑ នីតិវិធីតុលាការ ❑ គោលបំណងវិទ្យាសាស្ត្រផ្សេងៗ |
| ទីកន្លែងដែលសម្បត្តិវប្បធម៌ត្រូវផ្ញើទៅ |
| ថ្ងៃ ខែ ឆ្នាំ នៃការនាំចេញ |
| ថ្ងៃ ខែ ឆ្នាំប្រហាក់ប្រហែល នៃការវិលត្រឡប់នៃសម្បត្តិវប្បធម៌មកកម្ពុជាវិញ |

| |
|---|
| ការនាំចេញជាស្ថាពរ |
| គោលបំណងនៃការនាំចេញ |
| កន្លែងទទួលសម្បត្តិវប្បធម៌ |
| ថ្ងៃ ខែ ឆ្នាំ ការនាំចេញ |

# ព្រះរាជក្រម

## ប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពី
## តំបន់ការពារធម្មជាតិ

# ព្រះរាជក្រម

នស/រកម/០២០៨/០០៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ត្រពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៧ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# តំបន់ការពារធម្មជាតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–**

ច្បាប់នេះ កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍតំបន់ការពារធម្មជាតិ ។

គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រង ការអភិរក្សជីវៈចម្រុះ និងការធានាប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព ។

**មាត្រា ២.–**

ច្បាប់នេះ មានវិសាលភាពអនុវត្តនៅតំបន់ការពារធម្មជាតិ ដែលកំណត់ដោយបទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស.រកម.១២៩៦-៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប លេខ នស/រកត/០៤០១/០៧០ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០១ និងលិខិតបទដ្ឋានផ្សេងទៀត ។

**មាត្រា ៣.–**

វាក្យស័ព្ទសំខាន់ៗដែលប្រើប្រាស់ និងមានអត្ថន័យសម្រាប់ច្បាប់នេះ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ។

## ជំពូកទី ២
## ស្ថាប័នទទួលខុសត្រូវ

**មាត្រា ៤.–**

ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដូចមានចែងនៅក្នុងមាត្រា ២ នៃច្បាប់នេះ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

ក្រសួងបរិស្ថានមានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិជាសេនាធិការសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលការពារនិងអភិរក្សធម្មជាតិក្នុងតំបន់ការពារធម្មជាតិនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

ការគ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវធានានូវសិទ្ធិរបស់សហគមន៍មូលដ្ឋានជនជាតិដើមភាគតិច និងសាធារណជន ដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង និងការអភិរក្សជីវៈចម្រុះប្រកបដោយនិរន្តរភាព ។

**មាត្រា ៥.-**

រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវបំពេញភារកិច្ចសំខាន់ៗដូចតទៅ :

១-រៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេស សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ

២-លើកការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ តាមតម្រូវការរបស់រាជរដ្ឋាភិបាល ឬ អនុលោមទៅតាមអនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ

៣-រៀបចំបទបញ្ញត្តិ លិខិតបទដ្ឋាននានា ដើម្បីអនុវត្តច្បាប់នេះឱ្យមានប្រសិទ្ធភាព

៤-ចាត់វិធានការដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងកសាងសំណុំបែបបទបញ្ជូនទៅតុលាការ

៥-អប់រំផ្សព្វផ្សាយដល់សាធារណជនក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ

៦-រៀបចំកិច្ចព្រមព្រៀងស្តីពីកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ ។

**មាត្រា ៦.-**

រដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានសិទ្ធិ និងភារកិច្ចសំខាន់ៗដូចខាងក្រោម :

១-ហាមឃាត់ ត្រួតពិនិត្យជាប្រចាំ ទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិគ្រប់ប្រភេទនៅក្នុងតំបន់ការពារធម្មជាតិ

២-ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗ ដែលកំណត់ដោយច្បាប់នេះ

៣-មានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ

៤-ត្រួតពិនិត្យរាល់ការនាំចេញ ការនាំចូលនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ និងសំណាកក្នុងតំបន់ការពារធម្មជាតិ

៥-ធ្វើការអប់រំផ្សព្វផ្សាយ និងសម្របសម្រួលជាមួយសហគមន៍មូលដ្ឋានជនជាតិដើមភាគតិចក្នុងដំណើរការរៀបចំ និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ ។

សិទ្ធិនិងភារកិច្ចលំអិតរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៣

## ការរៀបចំកែប្រែតំបន់ការពារធម្មជាតិ

**មាត្រា ៧.-**

តំបន់ការពារធម្មជាតិ ត្រូវបែកចេញជាប្រភេទដូចខាងក្រោម:

១-តំបន់ឧទ្យានជាតិ

២-តំបន់ដែនជម្រកសត្វព្រៃ

៣-តំបន់ការពារទេសភាព

៤-តំបន់ប្រើប្រាស់ច្រើនយ៉ាង

៥-តំបន់រ៉ាមសារ

៦-តំបន់ស្នូលនៃឋបនីយជីវមណ្ឌល

៧-តំបន់បេតិកភណ្ឌធម្មជាតិ

៨-តំបន់ឧទ្យានជាតិសមុទ្រ ។

តំបន់ការពារធម្មជាតិខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៨.–**

ការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវផ្អែកតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ លក្ខណៈវិនិច្ឆ័យ គោលបំណងនៃការគ្រប់គ្រង សិទ្ធិប្រើប្រាស់ធនធានធម្មជាតិ សិទ្ធិកាន់កាប់ដីធ្លី និងកត្តាពាក់ព័ន្ធផ្សេងទៀត ។

ការស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវភ្ជាប់មកជាមួយនូវ :

១-ការអធិប្បាយអំពីសារៈសំខាន់ខាងផ្នែកជីវៈចម្រុះ សណ្ឋានដី ភូគព្ភសាស្ត្រ ប្រវត្តិសាស្ត្រ វប្បធម៌ និងការអភិរក្សតំបន់ ដែលស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិនោះ

២-ការអធិប្បាយអំពីលក្ខណៈច្បាប់នៃតំបន់ ដែលស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិភ្ជាប់ជាមួយនូវផែនទីមានមាត្រដ្ឋានកំណត់ច្បាស់លាស់ ដែលបង្ហាញយ៉ាងច្បាស់អំពីទីតាំង ព្រំប្រទល់ និងទំហំនៃតំបន់ការពារធម្មជាតិនោះ

៣-ការបញ្ជាក់ពីគោលបំណងនៃការគ្រប់គ្រងតំបន់ស្នើរៀបចំ និងការគម្រោងកំហែងចំពោះមុខ

៤-ការសិក្សាលើការប្រើប្រាស់ធនធានធម្មជាតិ និងដីធ្លី នៅក្នុងតំបន់ការពារធម្មជាតិ

៥-របាយការណ៍អំពីលទ្ធផលនៃការពិគ្រោះយោបល់ជាមួយស្ថាប័នភាគីពាក់ព័ន្ធ និងតំណាងអាជ្ញាធរមូលដ្ឋានដែលមានទីតាំងនៅក្នុង ឬ ក្បែរតំបន់ស្នើសុំរៀបចំកែប្រែតំបន់ការពារធម្មជាតិ ។

ការរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩.–**

រាជរដ្ឋាភិបាល អាចរៀបចំកែប្រែតំបន់ការពារធម្មជាតិណាមួយ ដែលមានសារៈសំខាន់ចំពោះជាតិ និងអន្តរជាតិ ដើម្បីស្នើសុំចូលជាបេតិកភណ្ឌធម្មជាតិពិភពលោក ឬ ថ្នាក់តំបន់ស្របតាមលក្ខណៈវិនិច្ឆ័យ អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងអន្តរជាតិ ឬ ថ្នាក់តំបន់ ។

តំបន់ការពារធម្មជាតិណាមួយ ដែលត្រូវបានចាត់បញ្ចូលជាតំបន់បេតិកភណ្ឌធម្មជាតិពិភពលោក ឬ បេតិកភណ្ឌធម្មជាតិថ្នាក់តំបន់រួចហើយ រាជរដ្ឋាភិបាលត្រូវមានវិធានការចាំបាច់ ដើម្បីធានានូវការគ្រប់គ្រងអភិរក្សតំបន់ទាំងនោះ ដោយអនុលោមតាមសន្ធិសញ្ញា ឬអនុសញ្ញាបេតិកភណ្ឌធម្មជាតិពិភពលោក ឬ បេតិកភណ្ឌធម្មជាតិថ្នាក់តំបន់ ។

តំបន់ការពារធម្មជាតិណាមួយ ដែលមានការទទួលស្គាល់ដោយសន្ធិសញ្ញា អនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់អន្តរជាតិ ឬ ថ្នាក់តំបន់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១០.-**

រាជរដ្ឋាភិបាល អាចបង្កើតតំបន់ការពារធម្មជាតិថ្នាក់ខេត្ត ក្រុងបាន ។

ការបង្កើតតំបន់ការពារធម្មជាតិថ្នាក់ខេត្ត ក្រុង ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៤

## ការកំណត់ និងការបែងចែកតំបន់គ្រប់គ្រង

**មាត្រា ១១.-**

តំបន់ការពារធម្មជាតិនីមួយៗ បែងចែកចេញជាបួន(៤)តំបន់គ្រប់គ្រង ៖

**១-តំបន់ស្នូល** ៖ ជាតំបន់គ្រប់គ្រងដែលមានតម្លៃខ្ពស់សម្រាប់ការអភិរក្សប្រភេទសត្វ រុក្ខជាតិ ដែលកម្រជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ ។

ការចេញ ចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានភារកិច្ច និងអ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិក្នុងគោលបំណងការពារ និងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ដែលត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន លើកលែងតែក្នុងវិស័យសន្តិសុខ និងការពារជាតិ ។

**២ - តំបន់អភិរក្ស** ៖ ជាតំបន់គ្រប់គ្រងស្ថិតនៅជាប់នឹងតំបន់ស្នូលដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី តំបន់ទឹកជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ ។

ការចេញ ចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ ។

ការប្រើប្រាស់អនុផលធនធានធម្មជាតិក្នុងតំបន់នេះ សម្រាប់ជីវភាពសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលមិនប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុតរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

៣- **តំបន់ប្រើប្រាស់ដោយចីរភាព** : ជាតំបន់គ្រប់គ្រងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ បម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការគ្រប់គ្រង ការអភិរក្សតំបន់ការពារធម្មជាតិផ្ទាល់និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចអនុញ្ញាតឱ្យមានការអភិវឌ្ឍ និងការវិនិយោគនៅក្នុងតំបន់នេះ តាមការស្នើសុំរបស់ក្រសួងបរិស្ថាន ក្រោយពីមានការពិគ្រោះយោបល់ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដី និងសហគមន៍មូលដ្ឋាន ដោយអនុលោមតាមច្បាប់ និងនីតិវិធីជាធរមាន ។

៤- **តំបន់សហគមន៍** : ជាតំបន់គ្រប់គ្រងបម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់សហគមន៍ និងជនជាតិដើមភាគតិច ដែលមានសកម្មភាពស្រាប់ រួមមានលំនៅដ្ឋាន ស្រែ និងចំការ ។

ការចេញប័ណ្ណដីធ្លី ឬ ការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ដោយអនុលោមតាមច្បាប់ភូមិបាល ។

តំបន់ការពារធម្មជាតិនេះ មិនគ្របដណ្តប់ទៅលើការកំណត់ និងការចាត់ចែងគ្រប់គ្រងរបស់អាជ្ញាធរអប្សរា និងអាជ្ញាធរដទៃទៀត ដែលរាជរដ្ឋាភិបាលប្រគល់ភារកិច្ចឱ្យ ។

**មាត្រា ១២.-**

ការបែងចែកតំបន់គ្រប់គ្រងទាំងបួនប្រភេទ ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

-គោលបំណងនៃការគ្រប់គ្រងតំបន់

-តម្លៃមានសក្តានុពលធនធានធម្មជាតិនៅក្នុងតំបន់នីមួយៗ

-សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលប៉ះពាល់ទៅលើតំបន់នោះ

-លទ្ធភាពទ្រទ្រង់នៃធនធានធម្មជាតិ

-ទីតាំងភូមិសាស្ត្រនៃតំបន់ ។

គោលការណ៍នៃការបែងចែកតំបន់គ្រប់គ្រងនីមួយៗ ក្នុងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៣.-**

ការកែប្រែព្រំប្រទល់តំបន់គ្រប់គ្រងបែងចែកនីមួយៗ ដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះធ្វើទៅបាន អាស្រ័យដោយ ៖

-មានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់ និងប្រពន្ធ័អេកូឡូស៊ី រួមទាំងប្រភេទសត្វរុក្ខជាតិ ធនធានជីវៈចម្រុះ សេនេទិច សេដ្ឋកិច្ចសង្គម និងវប្បធម៌ ដែលមានការប្រែប្រួល ឬ មានការគម្រាមកំហែង ។

-អនុលោមតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។

**មាត្រា ១៤.-**

ក្រសួងបរិស្ថាន ត្រូវរៀបចំធ្វើផែនទីតំបន់ការពារធម្មជាតិនីមួយៗជាផ្លូវការ និងកំណត់លើផែនទី ដែលមានមាត្រដ្ឋានច្បាស់លាស់ ដោយមានការចូលរួមពីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ អាជ្ញាធរដែនដី សហគមន៍មូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធ ។

រដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ត្រូវសិក្សា រៀបចំបែងចែក និងកំណត់តំបន់គ្រប់គ្រងដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ទៅតាមគោលការណ៍របស់ក្រសួងបរិស្ថាន និងបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិនីមួយៗ ទៅតាមចំណុចដៅលើផែនទីដែលនឹងកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៥
## ផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព
## សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ

**មាត្រា ១៥.-**

ក្រសួងបរិស្ថានត្រូវធ្វើផែនការយុទ្ធសាស្ត្រជាតិ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ។ ផែនការយុទ្ធសាស្ត្រនេះ មានលក្ខណៈស្របគ្នាជាមួយផែនការនានារបស់ជាតិ ដូចជាផែនការបរិស្ថានជាតិ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពជាតិ ស្តីពីជីវៈចម្រុះ និងផែនការតំបន់ដីសើមជាតិ ។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវសម្រេចដោយរាជរដ្ឋាភិបាលតាមការស្នើសុំរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១៦.-**

ផែនការយុទ្ធសាស្ត្រជាតិ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ ត្រូវមានចែងអំពី :

១-គោលបំណងនៃការអភិរក្ស ការស្តារ ការទប់ស្កាត់ ការបង្ក្រាបបទល្មើស និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានធម្មជាតិ និងប្រពន្ធ័អេកូឡូស៊ីរបស់តំបន់ការ-ពារធម្មជាតិនីមួយៗ

២-ស្ថានភាពបច្ចុប្បន្ននៃធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីរបស់តំបន់នីមួយៗ រួមទាំងប្រភេទសត្វ រុក្ខជាតិ សេនេទិច សេដ្ឋកិច្ចសង្គម និងវប្បធម៌

៣-សក្តានុពលនៃតំបន់ការពារធម្មជាតិនីមួយៗ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃកិច្ចការពារ អភិរក្ស ជីវៈចម្រុះ និងធនធានធម្មជាតិ

៤-អនុសាសន៍អំពីវិធានការធ្វើឱ្យសម្រេចបាននូវគោលបំណងនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ ។

ជំហាននៃការអនុវត្តផែនការ ត្រូវធ្វើឡើងចំពោះតំបន់ការពារធម្មជាតិដែលជាអាទិ-ភាព ។

**មាត្រា ១៧.-**

ក្រសួងបរិស្ថានត្រូវរៀបចំការស្នើសុំពិនិត្យ និងកែសម្រួលឡើងវិញនូវផែនការយុទ្ធ-សាស្ត្រជាតិ សម្រាប់តំបន់ការពារធម្មជាតិយ៉ាងយូរប្រាំឆ្នាំម្តង ។ ផែនការយុទ្ធសាស្ត្រជាតិ សម្រាប់តំបន់ការពារធម្មជាតិ អាចត្រូវកែប្រែបាន ក្នុងករណីចាំបាច់ដូចខាងក្រោម :

១-មានព័ត៌មានវិទ្យាសាស្ត្រច្បាស់លាស់ និងមានការយល់ដឹងអំពីធនធានធម្មជាតិ និងប្រព័ន្ធអេកូឡូស៊ី ក្នុងប្រទេសកម្ពុជា រួមទាំងប្រភេទសត្វ រុក្ខជាតិ ធនធានជីវ-សាស្ត្រ សេនេទិច សេដ្ឋកិច្ចសង្គម និងវប្បធម៌

២-មានការគម្រាមកំហែងចំពោះមុខ ទៅលើប្រព័ន្ធតំបន់ការពារធម្មជាតិ

៣-អនុវត្តស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

ផែនការយុទ្ធសាស្ត្រជាតិសម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនឹងត្រូវរៀបចំ និងកែសម្រួលដោយមានការពិគ្រោះយោបល់ជាសាធារណៈ ។

**មាត្រា ១៨.–**

រដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ត្រូវរៀបចំផែនការសកម្មភាព សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ ដែលសម្រេចដោយក្រសួងបរិស្ថាន និងអនុលោមតាមផែនការយុទ្ធសាស្ត្រជាតិ ។

កិច្ចដំណើរការរៀបចំផែនការសកម្មភាព សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗ ត្រូវមានការសម្របសម្រួល និងពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី សហគមន៍មូលដ្ឋានជនជាតិដើមភាគតិច និងអ្នកពាក់ព័ន្ធ ។

**មាត្រា ១៩.–**

ក្រសួងបរិស្ថានត្រូវចេញប្រកាសស្តីពីគោលការណ៍ណែនាំនៃការកសាងផែនការសកម្មភាព សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗដែលមានខ្លឹមសារសំខាន់ៗដូចខាងក្រោម ៖

១-គោលបំណងនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ

២-សេចក្តីអធិប្បាយអំពីសកម្មភាពក្នុងតំបន់គ្រប់គ្រងនីមួយៗ ដោយភ្ជាប់ផែនទីនៃការបែងចែកតំបន់គ្រប់គ្រង

៣-សេចក្តីអធិប្បាយអំពីធនធានធម្មជាតិ ការប្រើប្រាស់ធនធានទាំងនោះ និងការប្រើប្រាស់ដីធ្លី ក្នុងតំបន់ការពារធម្មជាតិ

៤-សេចក្តីអធិប្បាយអំពីសកម្មភាពហាមឃាត់ ដែលផ្ទុយទៅនឹងគោលបំណងនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ

៥-គំរូកិច្ចព្រមព្រៀងស្តីពីការចូលរួមគ្រប់គ្រងតំបន់ការពារធម្មជាតិរវាងរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ ជាមួយនឹងសហគមន៍តំបន់ការពារធម្មជាតិ និងរូបវន្តបុគ្គល ឬ នីតិបុគ្គល

៦-ផែនការ និងវិធានការជាក់ស្តែងក្នុងការគ្រប់គ្រងភ្លើងឆេះព្រៃ ការការពារ ការអភិរក្សសត្វព្រៃ និងដែនជម្រករបស់វា

៧-ផែនការគ្រប់គ្រងកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ និងធនធានធម្មជាតិ

៨-ការសិក្សា និងប៉ាន់ប្រមាណតម្រូវការថវិកា និងប្រភពផ្តល់មូលនិធិ

៩-សេចក្តីអធិប្បាយអំពីឈ្មោះ ទួនាទី និងរចនាសម្ព័ន្ធតំបន់ការពារធម្មជាតិ ។

**មាត្រា ២០.-**

ដើម្បីជាជំនួយក្នុងការពិភាក្សា ផ្តល់យោបល់ និងដោះស្រាយបាតុភាពក្នុងតំបន់ការពារធម្មជាតិ ក្រសួងបរិស្ថានអាចស្នើសុំរាជរដ្ឋាភិបាលបង្កើតគណៈកម្មាធិការជាតិសម្រាប់ដោះស្រាយបាតុភាពលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ ដែលមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន និងមានក្រសួង ស្ថាប័នពាក់ព័ន្ធជាសមាជិក ។

## ជំពូកទី ៦
## ការចូលរួម និងសិទ្ធិប្រើប្រាស់របស់សហគមន៍មូលដ្ឋាន និង សហគមន៍ជនជាតិដើមភាគតិច

**មាត្រា ២១.-**

សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច សាធារណជន និងសង្គមស៊ីវិល ត្រូវបានលើកទឹកចិត្តឱ្យមានការចូលរួមយ៉ាងពេញលេញក្នុងការផ្តល់ និងការទទួលយកព័ត៌មានទាក់ទងនឹងការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍក្នុងតំបន់ការពារធម្មជាតិ ។

**មាត្រា ២២.-**

រដ្ឋទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនារបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលរស់នៅក្នុងតំបន់ការពារធម្មជាតិ ។

សិទ្ធិប្រើប្រាស់ធនធានធម្មជាតិជាលក្ខណៈប្រពៃណី ទំនៀមទម្លាប់ តាមតម្រូវការរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចជាលក្ខណៈគ្រួសារអាចប្រព្រឹត្តទៅបាននៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់អភិរក្ស ដោយអនុវត្តទៅតាមគោលការណ៍ណែនាំដែលកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៣.-**

ការប្រើប្រាស់ធនធានធម្មជាតិ ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ប្រព្រឹត្តទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ដែលបានរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ។

ការប្រើប្រាស់ធនធានធម្មជាតិ ត្រូវអនុវត្តតាមផែនការគ្រប់គ្រង និងបែបបទបច្ចេកទេស ដើម្បីធានានិរន្តរភាពនៃធនធានធម្មជាតិ នៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ ។

**មាត្រា ២៤.-**

ការអនុវត្តមុខរបរចំការពនេចរ ត្រូវហាមឃាត់ចំពោះតំបន់ស្នូល និងតំបន់អភិរក្ស ក្នុងតំបន់ការពារធម្មជាតិ ។

**មាត្រា ២៥.-**

ក្រសួងបរិស្ថានមានសិទ្ធិប្រគល់ផ្នែកណាមួយនៃតំបន់ប្រើប្រាស់ដោយចីរភាពឱ្យទៅសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចដែលរស់នៅក្នុង ឬ ជាប់តំបន់ការពារធម្មជាតិ ដើម្បីរៀបចំជាសហគមន៍តំបន់ការពារធម្មជាតិ ។

សហគមន៍តំបន់ការពារធម្មជាតិ ត្រូវចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ហើយកិច្ចព្រមព្រៀងនេះ មានសុពលភាពមិនលើសពីរយៈពេលដប់ប្រាំ (១៥) ឆ្នាំម្តង ។

ក្នុងករណីដែលសហគមន៍តំបន់ការពារធម្មជាតិ មិនអនុវត្តតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងឱ្យបានហ្មត់ចត់នោះ រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ មានសិទ្ធិផ្អាកដំណើរការរបស់សហគមន៍តំបន់ការពារធម្មជាតិ ដើម្បីធ្វើការពិនិត្យនិងវាយតម្លៃឡើងវិញ ។

ក្រសួងបរិស្ថាន មានសិទ្ធិលុបកិច្ចព្រមព្រៀងសហគមន៍តំបន់ការពារធម្មជាតិ ក្នុងករណីដែលសហគមន៍អនុវត្តផ្ទុយពីកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រង ។

គោលការណ៍ណែនាំស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ២៦.–**

សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ពុំមានសិទ្ធិកាប់គាស់ ឬ ឈូសឆាយដីព្រៃក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដែលបានចុះកិច្ចព្រមព្រៀងជាមួយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន និងបង្វែរធ្វើជាដីកសិកម្ម ឬ ធ្វើជាកម្មសិទ្ធិបុគ្គល ឬ លក់ ប្តូរ ជួល បញ្ចាំ ធ្វើអំណោយ ប្រវាស់ បែងចែក ដោះដូរ ឬ ធ្វើការផ្ទេរតំបន់គ្រប់គ្រងរបស់សហគមន៍តំបន់ការពារធម្មជាតិឱ្យទៅរូបវន្តបុគ្គល ឬ នីតិបុគ្គលណាមួយបានឡើយ ។

លក្ខន្តិកៈរបស់សហគមន៍តំបន់ការពារធម្មជាតិ ត្រូវរៀបចំឡើងដោយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដោយមានការទទួលស្គាល់ពីអាជ្ញាធរដែនដី និងរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ។

ការផ្តល់ដីសម្រាប់បង្កបង្កើនផលបន្ថែមជូនដល់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ២៧.–**

រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវសិក្សាពីលទ្ធភាពរៀបចំសហគមន៍តំបន់ការពារធម្មជាតិ កំណត់ទីតាំងច្បាស់លាស់ និងទំហំឱ្យបានសមស្របដោយមានការពិគ្រោះយោបល់ និងការសម្របសម្រួលជាមួយអាជ្ញាធរដែនដី សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច ។

អង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ និងសង្គមស៊ីវិល ត្រូវបានលើកទឹកចិត្តឱ្យចូលរួមគាំទ្រ និងសម្របសម្រួលក្នុងដំណើរការរៀបចំ និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ ។

**មាត្រា ២៨.–**

សហគមន៍តំបន់ការពារធម្មជាតិត្រូវរៀបចំផែនការគ្រប់គ្រងធនធានធម្មជាតិដោយមានការទទួលស្គាល់ពីអាជ្ញាធរដែនដី និងមានការឯកភាពពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។ ផែនការនេះត្រូវធ្វើការពិនិត្យឡើងវិញរៀងរាល់បីឆ្នាំ (៣ឆ្នាំ) ម្តង ឬ មុនពេល ... ក្នុងករណីចាំបាច់ ។ ផែនការគ្រប់គ្រងធនធានធម្មជាតិ និងការអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ ត្រូវធ្វើសមាហរណកម្មជាមួយផែនការអភិវឌ្ឍឃុំ សង្កាត់ ។

## ជំពូកទី ៧
## ការអប់រំ ការផ្សព្វផ្សាយ ការស្តារ ការកែលំអ និងមូលនិធិតំបន់ការពារធម្មជាតិ

**មាត្រា ២៩.-**

ប្រជាពលរដ្ឋ ព្រះសង្ឃ សិស្សានុសិស្ស មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរមូលដ្ឋាន មានករណីយកិច្ចចូលរួមការពារ អភិរក្ស និងស្តារធនធានធម្មជាតិឡើងវិញក្នុងតំបន់ការពារធម្មជាតិ ។

**មាត្រា ៣០.-**

ក្រសួងបរិស្ថានត្រូវរៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយតាមគ្រប់រូបភាពឱ្យបានទូលំទូលាយស្តីពីកិច្ចការពារ អភិរក្សធនធានធម្មជាតិ ការស្តារ ការកែលំអធនធានជីវៈចម្រុះឡើងវិញ និងប្រព័ន្ធអេកូឡូស៊ីដែលបានរេចរិល និងបាត់បង់ ។

រៀងរាល់ឆ្នាំ ក្នុងទិវាបរិស្ថានជាតិ បរិស្ថានពិភពលោក និងទិវាអនុសញ្ញាជាតិ អន្តរជាតិនានា ក្រសួងបរិស្ថានត្រូវរៀបចំសកម្មភាពស្តារឡើងវិញនូវធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ សំដៅអប់រំ ផ្សព្វផ្សាយដល់សាធារណជនឱ្យបានយល់ដឹងពីតម្លៃនៃតំបន់ការពារធម្មជាតិ និងលើកកម្ពស់ការចូលរួមក្នុងកិច្ចការពារអភិរក្សធនធានធម្មជាតិ ។

**មាត្រា ៣១.-**

ក្រសួងបរិស្ថានត្រូវធ្វើការស្តារ និងការកែលំអបរិស្ថានឡើងវិញលើតំបន់រេចរិលក្នុងតំបន់ការពារធម្មជាតិ ដោយមានកិច្ចសហការជាមួយសហគមន៍មូលដ្ឋានជនជាតិដើមភាគតិច សហគមន៍តំបន់ការពារធម្មជាតិ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ អង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ។

**មាត្រា ៣២.–**

រាជរដ្ឋាភិបាលត្រូវបង្កើតមូលនិធិមួយហៅថា មូលនិធិតំបន់ការពារធម្មជាតិដែលគ្រប់គ្រង ចាត់ចែង និងទទួលខុសត្រូវដោយគណៈកម្មាធិការតំបន់ការពារធម្មជាតិ ដែលមានរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាសហប្រធាន ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៣៣.–**

មូលនិធិសម្រាប់ស្តារ កែលំអតំបន់ការពារធម្មជាតិ និងជីវៈចម្រុះបានមកពី :

១-ថវិកាជាតិ

២-ការលក់សំបុត្រចូលទស្សនាតំបន់ការពារធម្មជាតិ និងសេវាកម្មផ្សេងៗ

៣-មូលនិធិទាយជ្ជទានបរិស្ថាន

៤-អំណោយពីសប្បុរសជន

៥-ជំនួយផ្សេងៗបានមកពីអង្គការជាតិ អន្តរជាតិ និងបណ្តាប្រទេសជាមិត្ត

៦-ជំនួយបានមកពីមូលនិធិបរិស្ថានអន្តរជាតិ ។

**មាត្រា ៣៤.–**

ថវិកា និងមូលនិធិដែលបានមកពីប្រភពចំណូល ដូចមានចែងក្នុងមាត្រា ៣៣ នៃច្បាប់នេះ នៅក្នុងតំបន់ការពារធម្មជាតិ សម្រាប់ទ្រទ្រង់សកម្មភាពដូចខាងក្រោម :

-កិច្ចការពារ អភិរក្សធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

-ការស្តារ និងការកែលំអធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

-ការសិក្សាស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រ ជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី

-ការថែរក្សា និងពង្រីកសេវាទេសចរណ៍ធម្មជាតិ

-ការបណ្តុះបណ្តាល ការអភិវឌ្ឍធនធានមនុស្ស និងការកសាងសមត្ថភាពមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិសម្រាប់ការអភិរក្ស ការការពារជីវៈចម្រុះ និងប្រព័ន្ធ

-ការទ្រទ្រង់កម្មវិធីបង្កើតសហគមន៍តំបន់ការពារធម្មជាតិ

-ការផ្សព្វផ្សាយ ការអប់រំអំពីតំបន់ការពារធម្មជាតិ

-ការសាងសង់ ការស្តារ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ ។

## ជំពូកទី ៨
## ការអនុញ្ញាត ការហាមឃាត់
## និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

**មាត្រា ៣៥.–**

រដ្ឋមន្ត្រីក្រសួងបរិស្ថាន មានសិទ្ធិចេញលិខិតអនុញ្ញាត កិច្ចព្រមព្រៀង ឬ កិច្ចសន្យា ដែលពុំមានគោលដៅរកប្រាក់ចំណេញក្នុងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ។

នីតិវិធីនៃការស្នើសុំ និងគំរូបែបបទនៃលិខិតអនុញ្ញាត កិច្ចសន្យា ឬ កិច្ចព្រមព្រៀងក្នុងការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៣៦.–**

ការកាប់គាស់ ការឈូសឆាយដីព្រៃក្នុងតំបន់ការពារធម្មជាតិ ដើម្បីស្ថាបនា និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈគ្រប់ប្រភេទ ដែលកាត់តាមតំបន់ស្នូល និងតំបន់អភិរក្ស ត្រូវហាមឃាត់ ។

ករណីនេះ អាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ដោយមានការសម្រេចពីរាជរដ្ឋាភិបាល តាមការស្នើរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៣៧.–**

ការបោះ ឬ ការផ្ទេរទីតាំងឈរជើងអចិន្ត្រៃយ៍ ឬ បណ្តោះអាសន្នរបស់កងកម្លាំងប្រដាប់អាវុធក្នុងតំបន់ការពារធម្មជាតិ ស្ថាប័នកងកម្លាំងប្រដាប់អាវុធត្រូវសហការជាមួយក្រសួងបរិស្ថានធ្វើការសិក្សា លើកការស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល ។

ទីតាំងមូលដ្ឋានកងកម្លាំងប្រដាប់អាវុធដែលមាន និងកំពុងឈរជើងនៅក្នុងតំបន់ការពារធម្មជាតិ ហើយត្រូវរំសាយ ឬ ប្តូរទីតាំងទៅកន្លែងផ្សេងទៀត អង្គភាពកងកម្លាំងប្រដាប់អាវុធនេះ ត្រូវប្រគល់ទីតាំងមូលដ្ឋាននោះឱ្យមកក្រសួងបរិស្ថានគ្រប់គ្រង ។

ហាមដាច់ខាតការធ្វើសមយុទ្ធ ការហ្វឹកហាត់ និងការបោះជំរំកងកម្លាំងប្រដាប់អាវុធនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្សនៃតំបន់ការពារធម្មជាតិ លើកលែងតែមានការចាំបាច់ក្នុងវិស័យសន្តិសុខ និងការពារជាតិ ។ សកម្មភាពទាំងនេះអាចធ្វើទៅបានតែក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ដោយមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ៣៨.-**

រាល់ការនាំចេញ ការនាំចូលគ្រាប់ពូជរុក្ខជាតិ ការបង្កាត់ពូជប្រភេទសត្វព្រៃ និងពូជមច្ឆាជាតិគ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិ ត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិទិតថ្ម័យ វាយតម្លៃឱ្យបានច្បាស់លាស់ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ៣៩.-**

រាល់ការនាំចេញ ការនាំចូល ឬ ការដោះដូរ ដែលពុំមានលក្ខណៈពាណិជ្ជកម្មនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ ការបង្កាត់ពូជ និងសំណាករបស់ប្រភេទទាំងនោះដែលមានដើមកំណើតនៅក្នុងតំបន់ការពារធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសដទៃត្រូវធ្វើការសិក្សាស្រាវជ្រាវ វិភាគវិទិតថ្ម័យ និងវាយតម្លៃឱ្យបានច្បាស់លាស់ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ។

**មាត្រា ៤០.-**

ហាមបង្កឱ្យភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ ។ ការប្រើប្រាស់ភ្លើងអាចអនុគ្រោះបាន ចំពោះរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីផលប្រយោជន៍រុក្ខវប្បកម្ម ផ្លូវភ្លើង ឬ អគ្គីភ័យព្រៃ ។

ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់មានកាតព្វ-កិច្ចធ្វើសហការក្នុងការថែរក្សា ការពារព្រៃឈើក្នុងការប្រយុទ្ធទប់ស្កាត់ភ្លើងឆេះព្រៃ ។

**មាត្រា ៥១.-**

តំបន់ការពារធម្មជាតិនីមួយៗ ត្រូវការពារ និងទប់ស្កាត់នូវរាល់សកម្មភាព ដែលធ្វើឱ្យខូចខាត ឬ ប៉ះពាល់អវិជ្ជមានក្នុងតំបន់ការពារធម្មជាតិ បណ្ដាលមកពីការកាប់គាស់ រុករាន ទន្ទ្រានដីព្រៃដោយរំលោភ ការធ្វើអាជីវកម្ម ការបំពុលមជ្ឈដ្ឋានធនធានជីវៈចម្រុះ ភ្លើងឆេះព្រៃ ការធ្វើកសិកម្មពនេចរ ការនាំចូលជម្ងឺ សត្វល្អិតចង្រៃ និងប្រភេទរុក្ខជាតិ ឬ សត្វរាតត្បាត ។

សកម្មភាពដែលនាំឱ្យខូចខាត ឬ ប៉ះពាល់អវិជ្ជមាន ដែលត្រូវហាមឃាត់ក្នុងតំបន់ការពារធម្មជាតិមាន :

១-រំកិល ដកចេញ ឬ បំផ្លាញគោលសីមា ឬ សញ្ញាសម្គាល់ព្រំប្រទល់តំបន់ការពារធម្មជាតិ

២-ប្រើសិទ្ធិប្រើប្រាស់ធនធានធម្មជាតិខុសពីសិទ្ធិដែលបានទទួលស្គាល់ ឬ បានអនុញ្ញាតដោយច្បាប់

៣-កាប់ ផ្ដួលរំលំ គ្រៀរ កាប់បំផ្លាញដើមឈើ ឬ បំពុល ឬ គាស់រម្លើងគល់ឈើ

៤-ការចាប់ ប្រមាញ់ ប្រមូលពង កូនសត្វព្រៃ និងសត្វស្លាបតាមគ្រប់រូបភាព

៥-ការបំផ្លាញគុណភាពទឹកតាមគ្រប់រូបភាព ការដាក់ថ្នាំបំពុល ការប្រើសារធាតុគីមី ការចោលសំណល់រឹង រាវ ចូលក្នុងទឹក ឬ លើដី ការប្រើប្រាស់ឧបករណ៍ឆក់

៦-ការស្ដុក ការទិញ និងការតាំងលក់សត្វព្រៃ សំណាកសត្វព្រៃគ្រប់ប្រភេទ

៧-ការបំផ្លាញវាលស្មៅធម្មជាតិ រុក្ខជាតិនានា និងទីជម្រកសត្វព្រៃ

៨-ការលែងសត្វពាហនៈ និងបពេក្ខីវត្ថុប្រមាញ់

៩-ការនេសាទដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ ការធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ

១០-ការបង្កើតមូលដ្ឋាន និងកែច្នៃខ្ទឹមបំពង់ ដើមម្រះព្រៅ វល្លិរមៀត ឬ អនុផលព្រៃឈើផ្សេងទៀត និងការធ្វើវារីវប្បកម្មទឹកសាប ទឹកប្រៃ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់ [illegible]ទេស ដែលនាំដល់ការបំពុល ឬ បំផ្លាញមជ្ឈដ្ឋានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ។

ROYAUME DU CAMBODGE

**មាត្រា ៤២.-**

ហាមឃាត់ការកែច្នៃផល អនុផលធនធានធម្មជាតិ ការបង្កើត និងដំណើរការម៉ាស៊ីនរោងអារ ជ្រៀកឈើ រោងចក្រកែច្នៃឈើ សិប្បកម្មកែច្នៃផល អនុផលធនធានធម្មជាតិ និងឡគ្រប់ប្រភេទក្នុងតំបន់ការពារធម្មជាតិ ។

**មាត្រា ៤៣.-**

រូបវន្តបុគ្គល ឬ នីតិបុគ្គលណាក៏ដោយ ពុំមានសិទ្ធិផ្តល់ការអនុញ្ញាត ទោះដោយផ្ទាល់ក្តី ឬ ប្រយោលក្តី ឱ្យរានដីព្រៃ កាន់កាប់ដី កាប់ដើមឈើ ចាប់សត្វព្រៃគ្រប់ប្រភេទ ឬ ធ្វើសកម្មភាពគ្រប់យ៉ាង ដើម្បីប្រមូលផល អនុផលព្រៃឈើធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ដែលផ្ទុយនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ៤៤.-**

ដើម្បីកាត់បន្ថយជាអតិបរិមានូវហេតុប៉ះពាល់បរិស្ថាន និងសង្គម និងសម្រេចឱ្យបាននូវគោលបំណងយុទ្ធសាស្ត្រនៃការគ្រប់គ្រងតំបន់ការពារធម្មជាតិ រាល់គម្រោងអភិវឌ្ឍន៍ ឬ វិនិយោគក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក្រសួងបរិស្ថានត្រូវធ្វើការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមជាមុន ដោយសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ។

នីតិវិធីនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម សម្រាប់គម្រោង ឬ សកម្មភាពណាមួយ ត្រូវអនុលោមតាមបទប្បញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ។

## ជំពូកទី ៩
## ការអនុវត្តច្បាប់ និងនីតិវិធីដោះស្រាយបទល្មើស

**មាត្រា ៤៥.-**

បទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ជាបទល្មើសព្រហ្មទណ្ឌដែលមានចែងពិសេសដូចបានចែងក្នុងច្បាប់នេះ ។

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ បំពេញភារកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាលយុត្តិធម៌ មានសមត្ថកិច្ចស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប ទប់ស្កាត់ បទល្មើសធនធានធម្មជាតិ នៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ។

ប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ដែលបានទទួលនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងជាភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

បន្ទាប់ពីសាលក្រម ឬ សាលដីកាចូលជាស្ថាពរ វត្ថុតាងដែលបានរឹបអូសទុកជាសម្បត្តិរដ្ឋ ត្រូវចាត់ចែងតាមនីតិវិធី ដោយរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថាន ។

**មាត្រា ៤៦.–**

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ស្ថាប័នពាក់ព័ន្ធដទៃទៀត និងសាធារណជន ត្រូវបង្កភាពងាយស្រួល ផ្តល់ព័ត៌មាន និងជួយសហការផ្តល់កម្លាំងក្នុងការចុះធ្វើការស្រាវជ្រាវ ការស៊ើបអង្កេត ការទប់ស្កាត់ ការបង្ក្រាបបទល្មើសលើធនធានធម្មជាតិ ឬ ការថែរក្សាវត្ថុតាងបទល្មើសជាបណ្តោះអាសន្ន ក្នុងករណីមានការស្នើសុំពីមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

ក្នុងករណីមានពាក្យបណ្តឹង ឬ សេចក្តីរាយការណ៍ស្តីពីបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ដោយសហការជាមួយអាជ្ញាធរដែនដី ដើម្បីការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់បំផុត ។

**មាត្រា ៤៧.–**

នៅពេលបំពេញភារកិច្ចចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិនៅក្នុងរង្វង់ដែនសមត្ថកិច្ចរបស់ខ្លួន និងនៅពេលចូលបំភ្លឺក្នុងសវនាការរបស់តុលាការ មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវមានសម្លៀកបំពាក់ឯកសណ្ឋាន និងពាក់ផ្លាកសញ្ញាឲ្យបានត្រឹមត្រូវ ។

**មាត្រា ៤៨.-**

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្នុងតួនាទីជាមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ មានសិទ្ធិប្រើប្រាស់អាវុធស្របតាមបទប្បញ្ញត្តិនៃច្បាប់ជាធរមាន។

អាវុធត្រូវបំពាក់ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ។

**មាត្រា ៤៩.-**

ការកសាងសំណុំរឿងនៃបទល្មើសក្នុងតំបន់ការពារធម្មជាតិ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ទម្រង់បែបបទនៃការធ្វើកំណត់ហេតុបទល្មើសក្នុងតំបន់ការពារធម្មជាតិ ត្រូវកំណត់ដោយប្រកាសរួមរបស់ក្រសួងបរិស្ថាន និងក្រសួងយុត្តិធម៌ ។

**មាត្រា ៥០.-**

វត្ថុតាងនៃបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ត្រូវបានកំណត់ដូចខាងក្រោម :

១-ផល អនុផលធនធានធម្មជាតិ ដែលជាវត្ថុតាងពិតប្រាកដនៃបទល្មើស

២-សម្ភារៈបរិក្ខារ និងមធ្យោបាយដឹកជញ្ជូន ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

វត្ថុតាងដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវឃាត់ទុកជាបណ្តោះអាសន្នរហូតដល់សំណុំរឿងនៃបទល្មើស ត្រូវបានដោះស្រាយរួចជាស្ថាពរ តាមការបង់ពិន័យអន្តរការណ៍ ឬ តាមការជំនុំជម្រះរបស់តុលាការ ។

ក្នុងខណៈពេលកំពុងដឹកជញ្ជូនផល អនុផលធនធានធម្មជាតិល្មើស ដែលគ្មានម្ចាស់នៅជាមួយនោះ អ្នកបើកបរមធ្យោបាយដឹកជញ្ជូនត្រូវឃាត់ខ្លួនជាបណ្តោះអាសន្ន ស្របតាមបទប្បញ្ញត្តិក្រមនីតិវិធីព្រហ្មទណ្ឌ ដើម្បីជាប្រយោជន៍នៃការស៊ើបអង្កេតរកជនល្មើសនិងអ្នកសមគំនិត ។



ផល អនុផលធនធានធម្មជាតិដែលបានឃាត់ទុក ហើយងាយខូចខាត រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ មានសិទ្ធិលែង ឬ បំផ្លាញចោល ឬ រក្សាទុកជាប្រយោជន៍សាធារណៈ ដោយមានកំណត់ហេតុត្រឹមត្រូវ ។

**មាត្រា ៥១.–**

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានសមត្ថកិច្ចមានសិទ្ធិផ្អាកសកម្មភាពទាំងមូល ឬ មួយផ្នែកជាបណ្ដោះអាសន្នរបស់បុគ្គលណា ដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬ បំពានលើកិច្ចសន្យា រហូតដល់ដំណោះស្រាយនៃវិវាទត្រូវបានបញ្ចប់ ។

**មាត្រា ៥២.–**

បុគ្គលណាមិនពេញចិត្តចំពោះការសម្រេចណាមួយ ដែលធ្វើឡើងដោយមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដូចមានចែងក្នុងច្បាប់នេះ លើកលែងការសម្រេចពាក់ព័ន្ធនឹងការពិន័យអន្តរការណ៍ ដូចមានចែងក្នុងមាត្រា ៥៤ មាត្រា ៥៦ ចំណុច ១ នៃមាត្រា ៥៧ មានសិទ្ធិធ្វើពាក្យប្ដឹងតវ៉ាមកប្រធានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិថ្នាក់កណ្ដាលក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេចរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងតំបន់កើតហេតុ ឬ ប្ដឹងទៅតុលាការ ។

ប្រធានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិថ្នាក់កណ្ដាល ត្រូវសម្រេចលើបណ្ដឹងតវ៉ានេះ ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃយ៉ាងយូរ គិតពីថ្ងៃបានទទួលពាក្យបណ្ដឹង ។

ក្រោយពីបានទទួលសេចក្ដីសម្រេចចុងក្រោយ លើការពិនិត្យឡើងវិញដោយប្រធានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិថ្នាក់កណ្ដាល ក្នុងករណីនៅតែមិនអាចទទួលយកបាន បុគ្គលនោះអាចធ្វើបណ្ដឹងតវ៉ាទៅតុលាការបាន ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ យ៉ាងយូរ ។

ការតវ៉ាក្រោមមាត្រានេះ មិនធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអំណាច និងដំណើរការអនុវត្តរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានសមត្ថកិច្ចក្រោមច្បាប់នេះឡើយ ។



# ជំពូកទី ១០

# បទល្មើសធនធានធម្មជាតិ និងទោសប្បញ្ញត្តិ

**មាត្រា ៥៣.-**

ទណ្ឌកម្មនៃបទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិមាន : ទោសដាក់ពន្ធនាគារ ទោសពិន័យដោយតុលាការ ពិន័យអន្តរការណ៍ រឹបអូសវត្ថុតាង ជួសជុលស្តារការខូចខាត ព្រមាន ព្យួរ ដកហូតលិខិតអនុញ្ញាត ឬ លុបកិច្ចសន្យា ។

ការព្យួរ ការដកហូតលិខិតអនុញ្ញាត ឬ ការលុបកិច្ចសន្យា ជាសិទ្ធិរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន ។

ការពិន័យអន្តរការណ៍លើបទល្មើសធនធានធម្មជាតិ ការជួសជុលស្តារការខូចខាត និងការព្រមាន ជាសមត្ថកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ឬ ធ្វើការជួសជុលស្តារការខូចខាត មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវកសាងសំណុំរឿងបទល្មើសបញ្ជូនទៅតុលាការ ។

ការរឹបអូសវត្ថុតាង ជាសមត្ថកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឬ តុលាការ អាស្រ័យទៅតាមករណីនីមួយៗដែលបានកំណត់ក្នុងច្បាប់នេះ ។

**មាត្រា ៥៤.-**

ការពិន័យអន្តរការណ៍លើបទល្មើសធនធានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិអាចធ្វើបាន ក្នុងករណីជនល្មើសសារភាពទោសកំហុស យល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ គិតចាប់ពីថ្ងៃទទួលសេចក្តីសម្រេចរបស់រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ។

បែបបទ និងសិទ្ធិសម្រេចលើការពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

ការកំណត់បរិមាណប្រាក់ពិន័យអន្តរការណ៍ ត្រូវពិចារណាលើកត្តាដូចតទៅ :

១-ផលប្រយោជន៍ឥតម្លៃសេដ្ឋកិច្ច ជីវៈចម្រុះ លើការប្រព្រឹត្តជាក់ស្តែង

២-ទំហំនៃការខូចខាតធនធានធម្មជាតិ និងបរិស្ថាន

៣-ការប្រព្រឹត្តបទល្មើសនៅក្នុងតំបន់គ្រប់គ្រងនីមួយៗ

៤-ចំនួននៃការប្រព្រឹត្តបទល្មើស

៥-បរិមាណប្រាក់ពិន័យដែលធ្វើឱ្យរាងចាល

៦-កំហុសនៃការប្រព្រឹត្តបទល្មើស

៧-ស្ថានភាពនៃជនល្មើស

ករណីសាមីខ្លួនមិនបង់ប្រាក់ពិន័យ ក្នុងអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌខាងលើនេះទេ មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិត្រូវបញ្ជូនសំណុំរឿងទៅតុលាការ ។

**មាត្រា ៥៥.-**

ប្រាក់ពិន័យអន្តរការណ៍ ប្រាក់ពិន័យតាមសាលក្រម ឬ សាលដីកាតុលាការ និងប្រាក់បានមកពីការលក់វត្ថុតាង ត្រូវបង់ចូលថវិការដ្ឋ ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តតាមសំណើរបស់ក្រសួងបរិស្ថានដល់ប្រជាពលរដ្ឋ និងមន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសលើធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ។

**មាត្រា ៥៦.-**

បុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទោសដូចតទៅ :

**១-បទល្មើសធនធានធម្មជាតិថ្នាក់ទី ១**

-ការព្រមាន ការដួសដុល ការខូចខាត ការពិន័យអន្តរការណ៍ ការដកហូត ឬការព្យួរកិច្ចព្រមព្រៀង ឬ លិខិតអនុញ្ញាត

**២-បទល្មើសធនធានធម្មជាតិថ្នាក់ទី ២**

-ទោសដាក់ពន្ធនាគារពីមួយ(១)ខែ ទៅមួយ(១)ឆ្នាំ និង/ឬ ទោសពិន័យជាប្រាក់ពីមួយលានប្រាំសែន(១.៥០០.០០០)រៀល ដល់ដប់ប្រាំលាន(១៥.០០០.០០០) រៀល ។

**៣-បទល្មើសធនធានធម្មជាតិថ្នាក់ទី ៣**

-ទោសដាក់ពន្ធនាគារពីមួយ(១)ឆ្នាំ ទៅប្រាំ(៥)ឆ្នាំ និង/ឬ ទោសពិន័យជាប្រាក់ពីដប់ប្រាំលាន(១៥.០០០.០០០)រៀល ដល់មួយរយហាសិបលាន(១៥០.០០០.០០០)រៀល ។

**៤-បទល្មើសធនធានធម្មជាតិថ្នាក់ទី ៤**

-ទោសដាក់ពន្ធនាគារពីប្រាំ(៥)ឆ្នាំ ទៅដប់(១០)ឆ្នាំ និងទោសពិន័យជាប្រាក់ពីដប់ប្រាំលាន (១៥.០០០.០០០)រៀល ដល់មួយរយហាសិបលាន (១៥០.០០០.០០០)រៀល ។

ករណីបុគ្គលប្រព្រឹត្តល្មើសជានីតិបុគ្គល នោះទោសពិន័យជាប្រាក់ពីមួយរយហាសិបលាន(១៥០.០០០.០០០)រៀល ដល់ពីររយហាសិបលាន(២៥០.០០០.០០០)រៀល ។

វត្ថុតាងត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

**មាត្រា ៥៧.-**

ត្រូវទទួលការព្រមានជាបទល្មើសធនធានធម្មជាតិថ្នាក់ទី ១ ចំពោះបុគ្គលណាប្រព្រឹត្តបទល្មើសក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម :

១-លែងសត្វពាហនៈ លើកលែងករណីដូចមានចែងនៅក្នុងជំពូកទី ៦នៃច្បាប់នេះ

២-នាំចូលឧបករណ៍ សម្ភារៈ និងសារធាតុងាយឆេះដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃ

៣-សិក្សាស្រាវជ្រាវពីធម្មជាតិ និងវិទ្យាសាស្ត្រ ការធ្វើទេសចរណ៍ ដោយគ្មានការអនុញ្ញាត

៤-នាំចូលផលិតកែច្នៃឧបករណ៍បម្រើឱ្យសកម្មភាពល្មើសធនធានធម្មជាតិគ្រប់ប្រភេទ

៥-នាំចូលមធ្យោបាយគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត ក្នុងគោលបំណងស្រាវជ្រាវ និងដឹកជញ្ជូនធនធានធម្មជាតិ ។

ROYAUME DU CAMBODGE

**មាត្រា ៥៨.-**

ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី ដប់ម៉ឺន(១០០.០០០)រៀល ដល់មួយលាន(១.០០០.០០០)រៀលបន្ថែមលើសំណងនៃការខូចខាតធនធានធម្មជាតិ ឬ ធ្វើការជួសជុលស្តារការខូចខាត និងរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះបទល្មើសក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

១-បង្កើតឡគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាត

២-នាំចូល នាំចេញនូវប្រភេទសត្វ គ្រាប់រុក្ខជាតិ និងរុក្ខជាតិគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត

៣-បណ្តើរឆ្កែប្រមាញ់ ក្នុងគោលបំណងប្រមាញ់

៤-បន្សល់ទុកនូវដើមហេតុដែលបង្កឱ្យមានភ្លើងឆេះព្រៃ

៥-ចាប់ ដាក់អន្ទាក់ ប្រមាញ់ បំពុល ប្រមូលពង កូនសត្វព្រៃគ្រប់ប្រភេទ

៦-នាំចូលនូវរណារយន្ត និងគ្រឿងចក្រផ្សេងៗ ដោយគ្មានការអនុញ្ញាត ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មានតម្លៃទ្វេដង និងជួសជុលការខូចខាតឡើងវិញ ។

**មាត្រា ៥៩.-**

ត្រូវទទួលការពិន័យអន្តរការណ៍ជាប្រាក់ចំនួនពី មួយលាន(១.០០០.០០០)រៀលដល់ដប់លាន(១០.០០០.០០០)រៀល ឬ ត្រូវធ្វើការជួសជុលស្តារការខូចខាត និងរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះបទល្មើសក្នុងតំបន់ការពារធម្មជាតិដូចខាងក្រោម៖

១-កាប់ គាស់រម្លើង កាប់រំលំ រុករានដីព្រៃ គៀរ ចងរឹត ប្រមូល បំផ្លាញធនធានធម្មជាតិ

២-ធ្វើឱ្យរបួស ឬ ខូចខាតដល់រុក្ខជាតិ សត្វព្រៃ

៣-ដឹកជញ្ជូន និងប្រមូលផល អនុផលធនធានធម្មជាតិ ដោយគ្មានការអនុញ្ញាត

៤-ប្រមូលសន្និធិផល អនុផលធនធានធម្មជាតិ ដោយគ្មានការអនុញ្ញាត

៥-ជួញដូរសត្វព្រៃ សំណាកសត្វព្រៃ និងចិញ្ចឹមសត្វព្រៃគ្រប់ប្រភេទ

៦-នេសាទដែលផ្ទុយនឹងបញ្ញត្តិនៃច្បាប់ ធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិទាំងក្នុងដែនសមុទ្រ និងដែនទឹកសាប ព្រៃលិចទឹក ព្រៃកោងកាង ផ្កាថ្ម និងស្មៅសមុទ្រ ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់មានតម្លៃទ្វេដង និងជួសជុលការខូចខាតឡើងវិញ ។

**មាត្រា ៦០.–**

ត្រូវផ្តន្ទាទោសជាបទល្មើសធនធានធម្មជាតិថ្នាក់ទី ២ និងត្រូវរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះជនដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ប្រើប្រាស់សារធាតុពុលគ្រប់ប្រភេទ ដែលធ្វើឱ្យប៉ះពាល់ដល់ធនធានធម្មជាតិ

២-ធ្វេសប្រហែសបង្កឱ្យមានភ្លើងឆេះព្រៃ

៣-យាយី បំផ្លាញជម្រកពង កូន កន្លែងបន្តពូជសត្វព្រៃ និងមច្ឆាជាតិ

៤-កាប់បំផ្លាញរុក្ខជាតិក្នុងតំបន់ស្តារប្រពន្ធ័អេកូឡូស៊ីឡើងវិញ

៥-ប្រើប្រាស់ឧបករណ៍នានា ដែលបង្កការរំខានដោយសំឡេង រំញ័រ រលកនិងផ្សែង

៦-លាក់ចាំង ធ្វើឱ្យបាត់បង់ ឬ ធ្វើឱ្យខូចខាតវត្ថុតាងនៃបទល្មើស

៧-ប្រមូលផ្លែឈើព្រៃ តាមវិធីកាប់រំលំដើម

៨-កម្ទេច ផ្លាស់ប្តូរ លុបបំបាត់ ឬ ធ្វើឱ្យខូចខាតផ្លាកសញ្ញាគ្រប់ប្រភេទ

៩-បោះបង្គោលហ៊ុមព័ទ្ធ ដាក់សញ្ញាសម្គាល់ក្នុងគោលបំណងកាន់កាប់ជាកម្មសិទ្ធិ ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៦១.–**

ត្រូវផ្តន្ទាទោស ជាបទល្មើសធនធានធម្មជាតិថ្នាក់ទី ៣ និងរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះជនដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-ធ្វើឱ្យខូចខាត ឬ ប្រែប្រួលសភាពដើមរំកិល ឬ បន្ទិតបង្គោលព្រំប្រទល់និងហេដ្ឋារចនាសម្ព័ន្ធ សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ

២-បង្កើតមូលដ្ឋានកែច្នៃ ផល អនុផលធនធានធម្មជាតិគ្រប់ប្រភេទ

៣-កែច្នៃខ្ទឹមចំនួន៍ ម្រះព្រៅ វល្លិរមៀត និងបម្រាញ់រុក្ខជាតិផ្សេងទៀត

៤-កាប់ គៀរ ចងរឹត តាស់រមើង កាប់រំលំ ប្រមូល បំផ្លាញ រុករាន និងធ្វើសន្ធិ-
ធិរុក្ខជាតិ ដែលកំពុងរងគ្រោះថ្នាក់ ឬ មានដោយកម្រ និងជិតផុតពូជ ដែលបានកំណត់ដោយប្រកាសក្រសួងបរិស្ថាន

៥-ចាប់ដោយដាក់អន្ទាក់ ខ្លារ អង្គប់ បន្ទឹង លប់ ដោយបង្កៃ ឬ ដោយប្រមាញ់ ដែលធ្វើឱ្យរបួស បំពុល សម្លាប់ នាំចេញ ប្រមូលពង និងកូនសត្វព្រៃគ្រប់ប្រភេទ ដែលកំពុងរងគ្រោះថ្នាក់ មានដោយកម្រ និងជិតផុតពូជ ដែលបានកំណត់ដោយប្រកាសក្រសួងបរិស្ថាន

៦-ប្រើប្រាស់អាវុធជាតិផ្ទុះ ជាតិគីមី ថ្នាំពុល គ្រឿងឆក់ធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ

៧-រារាំង បង្កគ្រោះថ្នាក់ របួសស្នាម ដល់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងការចុះអនុវត្តមុខនាទី និងភារកិច្ចរបស់ខ្លួន

៨-ក្លែងបន្លំដោយប្រើប្រាស់ឯកសណ្ឋាន ផ្លាកសញ្ញាសម្គាល់ ឬ ឋានន្តរសក្តិរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដើម្បីធ្វើសកម្មភាពល្មើស

៩-ក្លែងបន្លំលិខិតបទដ្ឋានរបស់ស្ថាប័នមានសមត្ថកិច្ច ដើម្បីធ្វើសកម្មភាពល្មើស

១០-បំផ្លិចបំផ្លាញបង្គោលព្រំប្រទល់ ស្ពាន លូ ផ្លូវ អគារ ទីស្នាក់ការ ហេដ្ឋា-រចនាសម្ព័ន្ធសាធារណៈ ។

ក្នុងករណីមិនរាងចាលត្រូវទទួលផ្ដន្ទាទោសទ្វេដង ។

**មាត្រា ៦២.-**

ត្រូវផ្ដន្ទាទោសជាបទល្មើសធនធានធម្មជាតិថ្នាក់ទី ៤ និងត្រូវរឹបអូសវត្ថុតាងជាសម្បត្តិរដ្ឋ ចំពោះជនដែលបានប្រព្រឹត្តបទល្មើសណាមួយដូចខាងក្រោម :

១-កាប់តាស់ រុករានដីព្រៃ ឆ្ការ ដុត និងឈូសឆាយដីព្រៃ ដើម្បីយកដីធ្វើជាកម្មសិទ្ធិ

២-កាប់ ប្រមូល និងកែច្នៃឈើប្រណីតគ្រប់ប្រភេទ

៣-នាំចូល និងរក្សាទុកសំណល់គ្រោះថ្នាក់គ្រប់ប្រភេទ ដែលធ្វើឱ្យខូចខាត ឬ អាចបណ្ដាលឱ្យខូចខាតដល់ធនធានធម្មជាតិ

៤-បង្កឱ្យមានភ្លើងឆេះព្រៃដោយចេតនា

ROYAUME DU CAMBODGE

៥-យកថ្ម គ្រួស ខ្សាច់ រ៉ែ ការគាស់ ឈូសឆាយ កកាយយកដី ដោយគ្មានការអនុញ្ញាត

៦-ចាក់លុប ឬ ចាក់បំពេញដី ឬ ចាក់បំពេញដែនទឹក ដោយគ្មានការអនុញ្ញាត ។

ក្នុងករណីមិនរាងចាលត្រូវផ្តន្ទាទោសទ្វេដង ។

**មាត្រា ៦៣.-**

ជនណាដែលធ្វើការគម្រាមកំហែង ដល់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិធ្វើឱ្យរាំងស្ទះដល់ការបំពេញភារកិច្ចរបស់មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពីមួយ(១)ឆ្នាំ ទៅប្រាំ(៥)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់ប្រាំលាន(១៥.០០០.០០០)រៀល ទៅមួយរយហាសិបលាន(១៥០.០០០.០០០)រៀល ។

ជនណាដែលសមគំនិត ឬ ជួយសម្រួលដល់ការប្រព្រឹត្តបទល្មើស ត្រូវផ្តន្ទាទោសដូចៗដែរ ។

**មាត្រា ៦៤.-**

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឬ ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីបរិស្ថានរូបណាដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាល និង/ ឬ ត្រូវចោទប្រកាន់ចំពោះមុខតុលាការ ។

មន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ឬ ភ្នាក់ងារអធិការកិច្ច ឬ មន្ត្រីបរិស្ថានរូបណា ដែលសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលការប្រព្រឹត្តបទល្មើសនេះ ត្រូវផ្តន្ទាទោសដូចៗដែរ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**មាត្រា ៦៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦៦.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ ២០០៨

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០២០៨.១៣៤ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

**ហត្ថលេខា**

**ម៉ុក ម៉ារ៉េត**

លេខ: ១៣៨ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០០៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចិនកេន**

**ឧបសម្ព័ន្ធ :**

## វាក្យស័ព្ទ

**ជីវៈចម្រុះ** : សំដៅដល់បណ្តាសារពាង្គកាយខុសគ្នានៅក្នុងប្រភេទតែមួយ ឬ ប្រភេទផ្សេងគ្នា និងបណ្តាសារពាង្គកាយរស់នៃគ្រប់លំដាប់ថ្នាក់ និងប្រភពទាំងអស់ រួមទាំងប្រព័ន្ធអេកូ-ឡូស៊ីដែនដីគោក ដែនសមុទ្រ ដែនទឹកសាប និងបណ្តាទំនាក់ទំនងអេកូឡូស៊ី ដែលនៅក្នុងនោះមានប្រពន្ធ័អេកូឡូស៊ីទាំងនេះ ។

**ធនធានធម្មជាតិ** : សំដៅដល់ចំណែកមួយនៃបរិស្ថានធម្មជាតិ មានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូតគាម ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ។

**ប្រភេទកម្រ** : សំដៅដល់ប្រភេទទាំងឡាយណាដែលមានចំនួនតិចតួច ប៉ុន្តែវាពុំស្ថិតនៅក្នុងភាពគ្រោះថ្នាក់ផុតពូជភ្លាមៗទេ ។ ជាទូទៅប្រភេទទាំងនោះ គេតែងជួបប្រទះក្នុងបណ្តាភាវៈប្រចាំទីក្នុងជម្រកពិសេសណាមួយ ឬ ស្ថិតនៅរាយប៉ាយយ៉ាងរង្វើលនៅលើតំបន់ដីធំល្វឹងល្វើយ ។

**ប្រភេទជិតផុតពូជ** : សំដៅដល់ពពួកសត្វ ឬ រុក្ខជាតិ ដែលអាចវិនាសសាបសូន្យបណ្តាលមកពីការប្រែប្រួលបរិស្ថានដោយធម្មជាតិ ឬ ការធ្វើអាជីវកម្មផ្ទាល់របស់មនុស្ស ការខូចខាតហិនហោចជម្រក ការគម្រាមកំហែងពីប្រភេទដទៃទៀត ការប្រែប្រួលបណ្តាញអាហារ ការបំពុល ឬ បណ្តាលមកពីបន្សំនៃកត្តាទាំងនេះ ។

**ប្រពន្ធ័អេកូឡូស៊ី** : សំដៅដល់សំណុំអន្តរអំពើចម្រុះនៅលើផ្ទៃដីមួយជាក់លាក់រវាងបណ្តាភាវៈមានជីវិត (សារព័ន្ធរុក្ខជាតិ សត្វមីក្រូសរីរាង្គ) ជាមួយនឹងមជ្ឈដ្ឋានគ្មានជីវិត(អាកាសធាតុ មីក្រូអាកាសធាតុ ដី ទឹក) ដែលបង្កនូវស្ថាបនកម្មរបស់បរិស្ថាន និងជាឯកតាបំពេញមុខងារមួយនៅលើសំបកផែនដី ។ មនុស្សរួមជាមួយសំបកផែនដី ។ មនុស្សរួមជាមួយតម្រូវការផ្នែកសេដ្ឋកិច្ច ប្រពៃណី វប្បធម៌ និងបរិស្ថាន ក៏ជាផ្នែកចម្រុះរួមមួយនៃបណ្តាប្រព័ន្ធបរិស្ថានព្រៃឈើដែរ ។

**តំបន់ស្នូល** : សំដៅដល់តំបន់ដែលមានតម្លៃខ្ពស់ សម្រាប់ការអភិរក្ស ប្រភេទសត្វ និងរុក្ខជាតិដែលកម្រ ជិតផុតពូជ ទទួលរងគ្រោះថ្នាក់ គម្រាមកំហែងហើយនិងប្រព័ន្ធអេកូឡូស៊ីងាយស្រួយ ។

-ការចេញ ចូលតំបន់នេះត្រូវហាមឃាត់ លើកលែងតែមន្ត្រីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ដែលមានភារកិច្ច ។

-អ្នកសិក្សាស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រធម្មជាតិក្នុងគោលបំណងការពារនិងអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងបរិស្ថាន ត្រូវមានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន ។

**តំបន់អភិរក្ស** : សំដៅដល់តំបន់ស្ថិតនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃខាងការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ីតំបន់ជីជម្រាល និងតំបន់ដែលមានលក្ខណៈទេសភាពធម្មជាតិ ។

-ការចេញ ចូលតំបន់នេះ ត្រូវមានការអនុញ្ញាតជាមុនពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិនៅនឹងកន្លែង ។

-ការប្រើប្រាស់អនុផលធនធានធម្មជាតិ សម្រាប់ជីវភាពរបស់សហគមន៍មូលដ្ឋានជនជាតិដើមភាគតិច និងមិនធ្វើឱ្យប៉ះពាល់ខ្លាំងដល់ជីវៈចម្រុះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់បំផុត ។

**តំបន់ប្រើប្រាស់ដោយចីរភាព** : សំដៅដល់តំបន់ដែលមានតម្លៃផ្នែកសេដ្ឋកិច្ចជាតិខ្ពស់បម្រើដល់ការគ្រប់គ្រង និងអភិរក្សតំបន់ ការពារធម្មជាតិផ្ទាល់ និងចូលរួមលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។ តំបន់ប្រើប្រាស់ដោយចីរភាពរួមមាន :

-តំបន់អភិរក្សវប្បធម៌ធម្មជាតិ និងបេតិកភណ្ឌ

-តំបន់ទេសចរណ៍ធម្មជាតិ

-តំបន់អភិរក្សសត្វព្រៃ និងសេវាកំសាន្ត

-តំបន់ស្តារធនធានជីវៈចម្រុះ

-សហគមន៍តំបន់ការពារធម្មជាតិ

-តំបន់រុក្ខឧទ្យាន



-តំបន់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រួមមានៈ ប្រព័ន្ធធារាសាស្ត្រ អាងស្តុកទឹកភារីអគ្គីសនី បង្គោលចរន្តអគ្គីសនី

-តំបន់ភូគព្ភសាស្ត្រ

-តំបន់អាជីវកម្មធំរុក្ខជាតិ រនុគ្រោះដល់បរិស្ថានធម្មជាតិ ក្នុងតំបន់ការពារធម្មជាតិ និងតំបន់ជុំវិញ ។

**តំបន់សហគមន៍មូលដ្ឋាន :** សំដៅដល់តំបន់បម្រើឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ដែលមានសក្តានុពលស្រាប់រួមមានលំនៅដ្ឋាន ស្រែ និងចំការ ។ ការចេញលិខិត ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លី ឬ ការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លីនៅក្នុងតំបន់នេះ ត្រូវមានការបញ្ជាក់យល់ព្រមជាមុនពីក្រសួងបរិស្ថាន ។

**សហគមន៍តំបន់ការពារធម្មជាតិ** : សំដៅដល់ការចូលរួមរបស់ប្រជាសហគមន៍មូលដ្ឋាន ឬជនជាតិដើមភាគតិចក្រោមរូបភាពរចនាសម្ព័ន្ធជ្រើសតាំងរដ្ឋបាលមួយ ដែលមានការទទួលស្គាល់ពីរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ ក្នុងគោលបំណងចូលរួមរៀបចំគ្រប់គ្រង និងប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ជាក់លាក់ណាមួយនៃតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព សំដៅចូលរួមលើកកម្ពស់ជីវភាពរបស់ប្រជាសហគមន៍មូលដ្ឋាន ឬ ជនជាតិដើមភាគតិច ។

**តំបន់ការពារធម្មជាតិ** : សំដៅដល់តំបន់នៃដែនដីសម្បត្តិសាធារណៈរបស់រដ្ឋ រួមមាន : ដែនដីគោក ឬ ដែនទឹក រួមទាំងឆ្នេរសមុទ្រ និងសមុទ្រស្ថិតនៅក្នុងតំបន់ដែលទទួលស្គាល់ដោយបញ្ញត្តិនៃច្បាប់ ឬ តំបន់ដែលបង្កើតថ្មី ក្នុងដែនសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។ តំបន់ទាំងនោះមានសារៈសំខាន់ទាំងផ្នែករូបសាស្ត្រ និងផ្នែកជីវសាស្ត្រ ដែលតម្រូវឱ្យមានការគ្រប់គ្រងតាមច្បាប់ក្នុងបំណងការពារ និងថែទាំ ជីវៈចម្រុះ ធនធានធម្មជាតិនិងធនធានវប្បធម៌ហើយត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពគ្រប់ជំនាន់ ដើម្បីផលប្រយោជន៍បរិស្ថាន សង្គម និងសេដ្ឋកិច្ច ។

**ឧទ្យានជាតិ** : សំដៅដល់តំបន់ធម្មជាតិក្នុងដែនដីគោក និង/ឬ ដែនទឹក ដែលត្រូវបានកំណត់

ក-ការពារតួនាទីខាងផ្នែកប្រព័ន្ធអេកូឡូស៊ីមួយ ឬ ច្រើន របស់តំបន់ដែលបានកំណត់ សម្រាប់ជាប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់។

ខ-កំរិតដល់ការប្រើប្រាស់ ដែលអាចធ្វើឱ្យខូចខាត ឬ បំផ្លិចបំផ្លាញដល់ធនធានជីវៈចម្រុះ ធនធានធម្មជាតិ ធនធានវប្បធម៌ និងមុខងារតួនាទីរបស់តំបន់នោះជាមួយនឹងគោលបំណងនៃការកំណត់តំបន់ ។

គ-ផ្តល់ជាមូលដ្ឋានសម្រាប់ការកំសាន្ត ការទស្សនា ការអប់រំ ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងជំនឿ ដែលគ្រប់សកម្មភាពទាំងនេះ ពុំបង្កការគម្រាមកំហែងដល់បរិស្ថានធម្មជាតិ និងវប្បធម៌ នៅក្នុងមូលដ្ឋាន ។

**ដែនជម្រកសត្វព្រៃ** : សំដៅដល់តំបន់ក្នុងដែនដីគោក ឬ ដែនទឹក ដែលតម្រូវឱ្យមានការធ្វើអន្តរាគមន៍យ៉ាងសកម្មសម្រាប់បំពេញគោលបំណងគ្រប់គ្រង ដើម្បីធានាឱ្យមានការថែទាំទីជម្រក និង/ឬ ដើម្បីបំពេញល័ក្ខខ័ណ្ឌចាំបាច់សម្រាប់ប្រភេទណាមួយនៃសត្វ ឬ រុក្ខជាតិ ។

**តំបន់ប្រើប្រាស់ច្រើនយ៉ាង** : សំដៅដល់តំបន់ក្នុងដែនដីគោក និង/ ឬ ដែនទឹក ដែលក្នុងនោះមានសម្បូណ៌ដោយប្រព័ន្ធធម្មជាតិ ដែលពុំទាន់រងការបំផ្លិចបំផ្លាញ និងដែលតម្រូវឱ្យមានសកម្មភាពគ្រប់គ្រង ដើម្បីធានាការការពារ និងការថែទាំធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូ-ឡូស៊ីសម្រាប់ពេលយូរអង្វែង ។ ទន្ទឹមនឹងនោះដែរអាចផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់តាមតម្រូវការរបស់សហគមន៍ ។

**តំបន់ការពារទេសភាព** : សំដៅដល់តំបន់នៃដែនដីគោក និង/ ឬ ដែនទឹក ដែលតំបន់នោះទទួលរងអន្តរអំពើរបស់មនុស្ស ទៅលើធម្មជាតិ ដោយបង្កើតបានជាតំបន់ ដែលមានលក្ខណៈប្លែកខាងផ្នែកសោភ័ណភាពធម្មជាតិ ឬ កេរ្តិ៍អេកូឡូស៊ី ឬ វប្បធម៌ និងជាទូទៅសម្បូណ៌ដោយជីវៈចម្រុះ ។ ការថែរក្សាអន្តរអំពើជាប្រពៃណីបែបនេះ មានសារៈសំខាន់ជាអាយុជីវិតចំពោះកិច្ចការពារ ថែរក្សា និងការវិវឌ្ឍតំបន់បែបនេះ ។

**តំបន់បេតិកភណ្ឌធម្មជាតិ** : សំដៅដល់តំបន់ក្នុងដែនដីគោក និង/ឬ ដែនទឹកដែលតំបន់នោះមានលក្ខណៈពិសេសពីធម្មជាតិ ឬ ពាក់កណ្តាលកែច្នៃធម្មជាតិ និងមានតម្លៃលេចធ្លោ ឬ ប្លែកពីគេ ដោយសារតំបន់នោះមានដោយកម្រមានគុណភាពជាតំណាងឱ្យប្រព័ន្ធធម្មជាតិនានា ឬ មានគុណភាពខាងផ្នែកសោភ័ណភាព ឬ សារៈសំខាន់ខាងផ្នែកវប្បធម៌ ។

**តំបន់ជីវមណ្ឌលឬតំបន់ស្នូល** : សំដៅដល់តំបន់តំណាងឱ្យប្រព័ន្ធអេកូឡូស៊ីមានសារៈសំខាន់និងពុំរងនូវការខូចខាតខ្លាំង ហើយពទ្ធ័ជុំវិញទៅដោយតំបន់ប្រើប្រាស់ដោយនិរន្តរភាព ដែលអនុញ្ញាតឱ្យមានសកម្មភាពមនុស្ស ក្នុងកម្រិតមួយជាកំណត់ ។

**តំបន់រ៉ាមសារ** : សំដៅដល់តំបន់ដីសើម ដែលគេចាត់ទុកថា ជាតំបន់មានសារៈសំខាន់ផ្នែកអេកូឡូស៊ី ឬ ជីវៈចម្រុះជាលក្ខណៈអន្តរជាតិ ។

**តំបន់ដីសើម** : សំដៅដល់តំបន់មានលក្ខណៈជាវាលភក់ វាលល្បាប់ តំបន់មានរុក្ខជាតិពុករលួយ ទីដែលមានទឹកក្នុងលក្ខណៈធម្មជាតិ ឬ សិប្បនិម្មិត តំបន់មានទឹកលិចជាអចិន្ត្រៃយ៍ ឬ តាមរដូវ ឬ ទឹកនឹង ឬ ទឹកហូរ ឬ ទឹកភ្សារ រួមទាំងតំបន់សមុទ្រដែលមានជម្រៅមិនលើសពី៦ម៉ែត្រ ក្នុងពេលទឹកនាចទាបបំផុត ។

**ឧទ្យានជាតិសមុទ្រ** : សំដៅដល់តំបន់ឆ្នេរសមុទ្រទទួលឥទ្ធិពលជំនោរសមុទ្រលាយឡំជាមួយនឹងទឹកពីព្រៃភ្នំ រួមទាំងកោះ គ្របដណ្តប់ដោយព្រៃឈើ រុក្ខជាតិ សត្វព្រៃ និងមច្ឆាជាតិគ្រប់ប្រភេទមានលក្ខណៈប្រវត្តិសាស្ត្រ និងតម្លៃវប្បធម៌ ហើយតំបន់នេះត្រូវបានទទួលស្គាល់ដោយច្បាប់ និងគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ។

**តំបន់ការពារធម្មជាតិថ្នាក់ខេត្ត-ក្រុង** : សំដៅដល់តំបន់ដីគោក ទឹកសាប សមុទ្រ កោះដែលត្រូវបានការពារ គ្រប់គ្រងក្នុងគោលបំណងការពារ និងអភិរក្សធនធានជីវៈចម្រុះ ប្រពៃណី វប្បធម៌ ជំនឿ សាសនា ដែលមាននៅក្នុងតំបន់នោះ និងប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព ។ សហគមន៍មូលដ្ឋាននឹងទទួលផលប្រយោជន៍ជាចម្បងពីការគ្រប់គ្រងតំបន់ការពារធម្មជាតិថ្នាក់ខេត្ត ក្រុងនេះ ។

ROYAUME DU CAMBODGE

**តំបន់ឆ្នេរសមុទ្រ** ៖ សំដៅដល់តំបន់ដីគោកដែលស្ថិតនៅជាប់សមុទ្រ និងទទួលរងឥទ្ធិពលនៃសមុទ្រមាននៅខេត្តកំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប ដោយរួមបញ្ចូលទាំងបូរណភាពដែនសមុទ្រ ដែលលាតសន្ធឹងដល់ព្រំប្រទល់តំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា ។

**ជនជាតិដើមភាគតិច** ៖ សំដៅដល់អ្នកស្រុកដើមដែលរស់នៅតំបន់ភ្នំភាគច្រើនចិញ្ចឹមជីវិតដោយប្រព័ន្ធកសិកម្មពនេចរ និងប្រកបរបរបន្ថែមផ្សេងទៀត ដូចជាការបរបាញ់ ការនេសាទ និងការប្រមូលផល អនុផលធនធានធម្មជាតិជាដើម ។

**និរន្តរភាព** ៖ សំដៅដល់ការមិនបង្កឱ្យមានភាពវេចរិលជាអចិន្ត្រៃយ៍ ឬ ជាបន្តបន្ទាប់ ឬ ការថយចុះនូវគុណភាពនៃប្រភេទសារពាង្គកាយរស់ ឬ គុណភាពនៃធនធានដទៃទៀតដែលស្ថិតនៅក្រោមរូបភាពនៃការប្រើប្រាស់ជាទ្រង់ទ្រាយតូចក្តី ធំក្តី ។

**ទេសចរណ៍ធម្មជាតិ** ៖ សំដៅដល់សេវាកម្មទេសចរណ៍នានា ដែលមិនធ្វើឱ្យប៉ះពាល់ដល់បរិស្ថានធម្មជាតិជុំវិញតំបន់ទេសចរណ៍ និងមានរូបភាពទិន្នាការបម្រើឱ្យសកម្មភាពអភិរក្ស ។

**ការប្រើប្រាស់ជាលក្ខណៈប្រពៃណី** ៖ សំដៅដល់ការប្រមូលឈើងាប់ដោយធម្មជាតិ អនុផលធនធានធម្មជាតិជាឱសថបុរាណ បន្លែ ផ្លែឈើ ការបរបាញ់សត្វព្រៃ ដែលច្បាប់អនុញ្ញាតដើម្បីបំពេញតម្រូវការផ្ទងម្ហូបក្នុងរង្វង់គ្រួសារតែប៉ុណ្ណោះ ។ ៕

